00301939

E1/6.1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី**

ចៅក្រមសាលាដំបូង៖

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

ក្រឡាបញ្ជីសាលាដំបូង៖

លោក លឹម សួយហុង

លោក ម៉ាត្ទូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូបឺត ពេទីត *(Mr. Robert Petit)*

លោក យ៉េត ចរិយា

លោក វាល្លៀម ស្មីត *(Mr. William Smith)*

លោក តាន់ សេណារ៉ុង

លោក សេង ប៊ុនឃាង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ជឺហ្គិន អាស្មាន*(M.r Jurgen Assmann)*

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យ៉ុង ផានិត

លោក គីម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

កញ្ញា ទី ស្រ៊ុនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ព្យែរ អូលីវីយេ ស័រ

*(Mr. Pierre Olivier Sur)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក សាន់ រ៉ាដា

# កិច្ចដំណើរការនីតិវិធី

[០៩:00:00]

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**លោកស្រី សែ កុលវណ្ណី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ក្រឡាបញ្ជី, បញ្ជីត្រួតពិនិត្យវត្តមាន អវត្តមាន អ្នកត្រូវចូលរួមក្នុងនីតិវិធីសវនការសម្រាប់ព្រឹកនេះ សូមចាត់បញ្ចូលទៅក្នុងប្រតិចារឹក ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាំងរង្វង់ក្រចកសេះ ដែលទុកបម្រុងទុកសម្រាប់ជនជាប់ចោទនៅទីនោះ ។

អនុញ្ញាតអង្គុយចុះ ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមជម្រាបសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាអាចឡើងធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទបាននាពេលនេះ ដោយអនុលោមតាមវិធាន ៨៩ស្ទួន(២) ។ បើសហព្រះរាជអាជ្ញាឡើងធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់អង្គជំនុំជម្រះកំណត់នៅថិរវេលា២ម៉ោង សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីបទចោទប្រកាន់នេះ ។ សូមអញ្ជើសហព្រះរាជអាជ្ញា ។

[០៩:០៥:៣០]

**លោកស្រី ជាង លាង៖**

សូមគោរពអង្គសវនាការទាំងមូល!

យើងសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់ជនជាប់ចោទ ឌុច ដែលជាប្រធានមន្ទីរសន្តិសុខស-២១ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌរបស់ការិយាល័យសហព្រះរាជអាជ្ញា លេខ០០២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ ។

បានឃើញនិងពិនិត្យឡើងវិញ នូវសំណុំរឿងស៊ើបសួរលេខ០០១ ចុះថ្ងៃទី១៨ ខែ៧ ឆ្នាំ២០០៧

របស់សហចៅក្រមស៊ើបអង្កេត ដែលបានចាប់ផ្តើមនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដោយសហចៅក្រមស៊ើបអង្កេត ។

ដោយពិចារណាលើមាត្រា១នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយពិចារណាឃើញថា វិធាន៦៦.៥ នៃវិធានផ្ទៃក្នុង សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយពិចារណាឃើញថាការស៊ើបសួរខាងលើត្រូវបានបញ្ចប់សព្វគ្រប់ហើយ ។

បានឃើញដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ។

បានរកឃើញ នូវអង្គហេតុទាំងឡាយដូចខាងក្រោម៖

អស់រយៈពេល៣០ឆ្នាំហើយ ដែលជនរងគ្រោះនៃរបបខ្មែរក្រហមជាង១លាន៥សែននាក់ បានកំពុងតែទាមទាររកយុត្តិធម៌សម្រាប់ការឈឺចាប់របស់ពួកគេ ។ អស់រយៈពេល៣០ឆ្នាំហើយ ដែលអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាប្រជាធិបតេយ្យបានកំពុងរង់ចាំឲ្យមានការទទួលខុសត្រូវនេះ ។

អស់រយៈពេល៣០ឆ្នាំហើយ ដែលប្រជាជនកម្ពុជាជំនាន់នេះទាំងមូលកំពុងតែតស៊ូ ដើម្បីទទួលបាននូវចម្លើយអំពីវាសនារបស់ក្រុមគ្រួសាររបស់ពួកគេ ។

[០៩:០៧:៣៥]

ពិតណាស់នៅថ្ងៃនេះ សវនាការនេះ នៅចំពោះមុខប្រជាជនកម្ពុជានិងពិភពលោក ជាយូរមកហើយដែលនៅទីបំផុត ដំណើរការនេះបានចាប់ផ្តើមឡើង ហើយយុត្តិធម៌នឹងត្រូវធ្វើបានសម្រេច ។ រដ្ឋាភិបាលខ្លួនឯងផ្ទាល់កំពុងតែតស៊ូជាមួយនឹងកេរដំណែលដែលខ្មែរក្រហមបានបន្សល់ទុក ហើយសហគមន៍អន្តរជាតិ ដែលបានធ្វើឲ្យប្រជាជនកម្ពុជាបានខកចិត្តជាយូរមក ។ តែចុងក្រោយបានទទួលស្គាល់ថាយុត្តិធម៌ត្រូវតែមានអស្ថិរភាព និងមិនត្រូវឲ្យមាននិទ្ទណ្ឌភាពចំពោះភាពដ៏សាហាវយង់ឃ្នងនៃឧក្រិដ្ឋកម្មទាំងនេះឡាយ ទោះបីរយៈកាលបានកន្លងផុតទៅ៣០ឆ្នាំក៏ដោយ ។

កាលៈទេសៈបានបង្ខំឲ្យដំណើរការនេះ ត្រូវបានចាប់ផ្តើមបើការជំនុំជម្រះទៅលើជនជាប់ចោទនេះ ចៅក្រមត្រូវបានអញ្ជើញឲ្យមកសម្រេចអំពីពិរុទ្ធភាព ឬនិទស្សន៍របស់មនុស្សម្នាក់ និងអំពីតែបទឧក្រិដ្ឋទាំងឡាយដែលគាត់ត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ ។ គាត់នឹងមិនត្រូវបានសម្រេចអំពីបទឧក្រិដ្ឋរបស់អ្នកផ្សេង ឬអំពីជំនឿ ឬសមាជិកភាពរបស់គាត់នៅក្នុងក្រុមមួយឡើយ ។ ប៉ុន្តែ ជាការសម្រេចអំពីភាពរងគ្រោះរបស់អ្នកផ្សេងដែលមានទំហំធំធេងចំពោះអ្វីដែលគាត់បានទទួលខុសត្រូវស្របច្បាប់ ។

[០៩:០៩:០៦]

ពេលនេះលោក លោកស្រីចៅក្រមត្រូវបានអញ្ជើញឲ្យមកកំណត់នៅចំពោះមុខយើងទាំងអស់គ្នាថា ហេតុអ្វីនិងដោយរបៀបយ៉ាងដូចម្តេច បានជាមនុស្សនេះត្រូវបានគេអនុញ្ញាតឲ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ? លោក លោកស្រីចៅក្រមចាំបាច់ត្រូវតែធ្វើយ៉ាងដូច្នេះ ពីព្រោះថា នេះជាច្បាប់និងជាប្រវត្តិសាស្ត្រទាមទារផងដែរ ។ លើសពីករណីមួយនេះ និងលើសពីកិច្ចការប្រចាំថ្ងៃរបស់សវនាការមួយនេះ យើងមិនត្រូវភ្លេចឡើយថា គោលបំណងរបស់តុលាការ ដូចជាតុលាការនេះជាដើម គឺដើម្បីរកការពិតដោយមានការតាំងចិត្ត ដោយគ្មានការភ័យខ្លាច គ្មានការកំហិត ឬគ្មានភាពលម្អៀង ដើម្បីឲ្យមនុស្សជាតិរៀនសូត្រតាម និងទប់ស្កាត់មិនឲ្យប្រវត្តិសាស្ត្រកើតមានឡើងជាថ្មីម្តងទៀត ។

នៅក្នុងការស្វែងរកការពិតនេះ យើងសហព្រះរាជអាជ្ញានឹងជួយអង្គជំនុំជម្រះឲ្យអស់ពីលទ្ធភាពតាមតែអាចធ្វើទៅបាន ខណៈដែលយើងក៏ត្រូវតែយកចិត្តទុកដាក់ទៅលើការទទួលខុសត្រូវរបស់យើងក្នុងការបង្ហាញភស្តុតាងអំពីពិរុទ្ធភាពរបស់ជនជាប់ចោទឲ្យហួសពីវិមតិសង្ស័យ ។

យើងសន្និដ្ឋានថា ភស្តុតាងនៃករណីនេះ ហើយមានភស្តុតាងខ្លះយើងនឹងបញ្ជាក់ជូនក្នុងពេលនេះ គឺពិតជាបង្ហាញបានយ៉ាងគ្រប់គ្រាន់លើការដាក់បន្ទុកចំពោះបទចោទទាំងអស់ ។ យើងសូមឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ ព្រមទាំងពង្រីកការយកចិត្តទុកដាក់ទៅលើភស្តុតាងខ្លះដែលប្រមូលបានបញ្ជូននៅក្នុងសំណុំរឿង ដោយមិនត្រូវនិយាយសាឡើងវិញ អង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយទេ។ ប៉ុន្តែ គ្រាន់តែបញ្ជាក់អំពីភស្តុតាងខ្លះ ហើយនឹងការតភ្ជាប់ការសន្និដ្ឋានបញ្ចប់ ដែលអាចទាញយកពីភស្តុតាងនោះ ។

ហេតុដូច្នេះ យើងនឹងពិនិត្យលើបរិបទនៃបទឧក្រិដ្ឋដែលបានកើតឡើងនៅមន្ទីរស-២១ ជាពិសេសអំពីការបង្កើតកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ មុននឹងធ្វើអត្ថាធិប្បាយអំពីមន្ទីរស-២១ និងបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តឡើងនៅក្នុងមន្ទីរនេះ ។ បន្ទាប់មក យើងនឹងនិយាយអំពីតួនាទីរបស់ជនជាប់ចោទ និងការទទួលខុសត្រូវរបស់គាត់ ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋទាំងអស់នោះ ។ នៅមុនពេលធ្វើការសន្និដ្ឋានបញ្ចប់ទៅលើទិដ្ឋភាពផ្លូវច្បាប់មួយចំនួនពាក់ព័ន្ធនឹងការទទួលខុសត្រូវទាំងនោះ ។

ច្បាស់ណាស់ថាអ្វីដែលយើងនឹងថ្លែងបន្តទៀត គឺជាសេចក្តីអះអាងជាធម្មតា ហើយនិងសាលក្រមរបស់អង្គជំនុំជម្រះមិនដឹងថា នឹងផ្តល់សុពលភាពទៅលើអំណះអំណាងទាំងនោះដែរឬអត់?

[០៩:១២:១២]

លើសពីនេះទៀត ចៅក្រមនៃអង្គជំនុំជម្រះនឹងត្រូវកំណត់ថា តើហេតុអ្វី ពិតជាមានភស្តុតាងគាំទ្រដែលឬទេ? និងកំណត់ថាតើភស្តុតាងអ្វីខ្លះក្នុងចំណោមភស្តុតាងទាំងនោះ នឹងត្រូវយកមកពិចារណា? មន្ទីរស-២១ បានបង្កើតជាផ្នែកគ្រឹះមួយ ដែលជាផ្នែកសំខាន់ដ៏បំផុតនៃការវាយប្រហារ មានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធទៅលើប្រជាជនកម្ពុជាទាំងមូល ហើយការវាយប្រហារនេះ គឺជាការអនុវត្តផែនការមួយ ដែលថ្នាក់លើ ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានយល់ព្រម និងត្រូវបានចាប់ផ្តើមអនុវត្តជាយូរមកហើយមុនការបង្កើតស-២១ ទៅទៀត ។ ក្នុងនាមជាអ្នកនៅក្រោមបង្គាប់ថ្នាក់ដឹកនាំទាំងនេះ និងដោយធ្វើសកម្មភាពទៅតាមបញ្ជារបស់មេដឹកនាំរបស់ខ្លួន និងការជ្រោមជ្រែង លើកតម្កើងគោលនយោបាយទាំងអស់នេះ បទឧក្រិដ្ឋរបស់ជនជាប់ចោទ គឺជាផ្នែកមួយនៃការវាយប្រហារនេះ ។

អង្គជំនុំជម្រះជាទីគោរព! បក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ នៅស្ថានីយ៍រថភ្លើង ក្នុងទីក្រុងភ្នំពេញ ដែលក្នុងនោះមាន នួន ជា ត្រូវបានបោះឆ្នោតជ្រើសតាំងជាអនុលេខាបក្ស ចំណែកឯប៉ុល ពត និងអៀង សារី ជាសមាជិកមជ្ឈិមបក្ស ។ លុះដល់ឆ្នាំ១៩៦៣ សំឡុត ស ដែលហៅថា ប៉ុល ពត បានក្លាយទៅជាលេខាបក្ស ។ មិនយូរប៉ុន្មានទេ ដែលប្រជាជនកម្ពុជានិងពិភពលោកបានស្គាល់ថាជាខ្មែរក្រហម ។ គោលបំណងជាបន្ទាន់របស់ខ្មែរក្រហម គឺការបន្តការញុះញង់ក្នុងចលនានយោបាយ ដើម្បីប្រយុទ្ធប្រឆាំងនឹងសក្តិភូមិនិយម និងចក្រពត្តិនិយម ដើម្បីកសាងកម្លាំងធ្វើយុទ្ធនាការខាងកម្លាំងតស៊ូ ដើម្បីផ្តួលរលំរបបសម្តេច សីហនុ នៅពេលក្រោយមក និងជំរុញឥទ្ធិពលបស្ចិមប្រទេសឲ្យចេញផុតពីប្រទេស ។

គោលបំណងចុងក្រោយបំផុតរបស់ពួកគេ គឺការបង្កើតឲ្យមាននូវសង្គមកុម្មុយនីស្តបរិសុទ្ធមួយ ដែលគេមិនធ្លាប់ឃើញសោះពីមុនមក បើទោះបីជាគំរូកុម្មុយនីស្តស្តាលីន ចិន និងវៀតណាម ពិតជាមានឥទ្ធិពលមកលើកុម្មុយនីស្តខ្មែរក៏ដោយ ។ ឧទានកម្មកុម្មុយនីស្តក៏បានរីកដុះដាលជាបន្តិចម្តងៗ ប៉ុន្តែរដ្ឋប្រហាររបស់សាធារណរដ្ឋប្រឆាំងនឹងសម្តេច សីហនុ ក្នុងឆ្នាំ១៩៧០ ត្រូវបានផ្លាស់ប្តូរនៅអ្វីទាំងអស់ ។

[០៩:១៥:០៣]

ជាការឆ្លើយតបនឹងការអំពាវនាវអតីតព្រះមហាក្សត្រ ដើម្បីឲ្យក្រោកឈរឡើងប្រឆាំងនឹង លន់ នល់ ប្រជាជនទូទាំងប្រទេសបានចូលរួមបដិវត្តន៍ ។ សឹងតែមួយយប់កងកម្លាំងរបស់ខ្មែរក្រហមបានរីកដុះដាលឡើងពីចំនួនពីបីពាន់នាក់ទៅដល់រាប់ម៉ឺននាក់ ។

ការពង្រីកការទម្លាក់គ្រាប់បែកតាមអាកាសរបស់សហរដ្ឋអាមេរិក បានជួយជំរុញឲ្យកសិករ

ដែលមានការស្រេងាកចិត្តជាខ្លាំងរួចជាស្រេចហើយនោះ បានចូលរួមជាមួយកម្លាំងបដិវត្តន៍ខ្មែរក្រហម ដោយធ្វើការពង្រីកតំបន់ត្រួតត្រារបស់ខ្លួនឥតឈប់ឈរនៅចុងក្រោយខ្មែរក្រហមដែលស្ថិតនៅក្នុងរបៀបជាកម្លាំងប្រដាប់អាវុធប្រឆាំងចម្រុះមួយបានចូលមកដល់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ មេសា ឆ្នាំ ១៩៧៥ ។ សុបិនអាក្រក់របស់ប្រជាជនកម្ពុជាបានចាប់ផ្ដើមហើយ ។ មានអ្នកខ្លះ ហើយប្រហែលជានៅតែមានទៀត ក្នុងពេលនេះ នៅតែប្រកែកថារបបខ្មែរក្រហមបានឡើងកាន់អំណាចដែលមានចេតនាល្អបំផុត និងថាអ្វីៗបានធ្វើខុសយ៉ាងគួរឲ្យរន្ធត់បំផុត ប៉ុន្តែបើនិយាយឲ្យសាមញ្ញទៅវាមិនត្រឹមត្រូវទេ ។

ចាប់តាំងពីដំបូងមកម្ល៉េះ ដូចដែលមានភស្តុតាងបញ្ជាក់តាមគោលនយោបាយរបស់ខ្លួន នៅតាមបណ្ដាភូមិភាគនានា ដែលខ្លួនត្រួតត្រាមុនឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំខ្មែរក្រហម គឺមានចេតនាកម្ចាត់ចោលអ្នកដែលគេគិតថាជាខ្មាំង ហើយបានដាក់បញ្ហាសិទ្ធិមនុស្ស និងជីវិតមនុស្សក្នុងតម្លៃមួយដ៏ទាប ។ ដូចដែលបានឆ្លុះបញ្ចាំងក្នុងពាក្យស្លោកមួយគួរឲ្យញាក់សាច់មួយរបស់ពួកគេថា “ទុកក៏មិនចំណេញ ដកចេញក៏មិនខាត” ។ ទោះបីសព្វថ្ងៃនេះមានការសិក្សាស្រាវជ្រាវជាង ៣០ឆ្នាំហើយមកក្ដី ក៏វានៅតែមានការពិបាកយល់អំពីវិសាលភាពនៃការផ្លាស់ប្ដូរជាមូលដ្ឋាន ដែលបានអនុវត្តឡើងដោយខ្មែរក្រហម ដោយភាពគ្មានក្ដីមេត្តា និងប្រសិទ្ធភាពជាមួយនឹងការធ្វើពិសោធខាងផ្នែកវិស្វកម្ម ដើម្បីឲ្យសង្គមឈានទៅដល់ភាពសុខក្សេមក្សាន្តរបស់ខ្លួន ។

[០៩:១៧:២០]

នៅពេលដែលខ្មែរក្រហមបានឡើងកាន់អំណាចនៅកម្ពុជា ខ្លួនបានបែងចែកស្ថាប័នជាឋានានុក្រមនយោបាយ វរសេនាធំដែលបំបែកប្រទេសទៅជាផ្នែក និងផ្នែកតូចៗខុសៗគ្នា ។ ផែនទីសម័យកម្ពុជាប្រជាធិបតេយ្យ ដូចតទៅនេះ បង្ហាញឲ្យឃើញពីឋានានុក្រមនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ។ នេះគឺជាផែនទីនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលភូមិភាគចំនួន៦ ដូចដែលបានឃើញនៅទីនេះ គឺជាផ្នែកដែលធំជាងគេ និងមានអំណាចជាងគេបំផុត ។ ភូមិភាគត្រូវគេបែកចែងទៅជាតំបន់ ហើយតំបន់ត្រូវបានបែងចែកបន្ថែមទៀតទៅជាស្រុក ស្រុកជាបណ្ដុំភូមិមួយចំនួន ។ នេះគឺជាដ្យាក្រាមនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលភូមិភាគរាយការណ៍ ដោយផ្ទាល់ទៅគណៈកម្មការអចិន្ត្រៃយ៍បក្សកុម្មុយនីស្ដកម្ពុជា ហើយតំបន់ឯករាជ្យ ឬស្វយតត្រូវបានបង្ហាញដែលមានពណ៌ខុសៗគ្នា ។

ឧទាហរណ៍៖ នេះគឺជាភូមិភាគនិរតី ដែលបានកំណត់សម្គាល់តាមលេខកូដក្នុងសម័យកម្ពុជា

ប្រជាធិបតេយ្យ ហើយនេះគឺជាតំបន់១៣ ដែលរាយការណ៍ទៅថ្នាក់ដឹកនាំភូមិភាគនិរតី ។

ពីរ ចំណុចនៃការបែកចែកកម្ពុជាទៅជាតំបន់តាមឋានានុក្រមដ៏តឹងរ៉ឹងនេះ បក្សកុម្មុយនីស្តកម្ពុជា បានមានលទ្ធភាពអនុវត្តគោលនយោបាយព្រហ្មទណ្ឌរបស់ខ្លួន តាមរយៈការផ្សព្វផ្សាយនូវបទបញ្ជាទៅថ្នាក់ក្រោមតាមឋានានុក្រម ។ រចនាសម្ព័ន្ធនេះ ក៏បានអនុញ្ញាតឲ្យគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា-- *(សំឡេងកាត់)*

[០៩:១៩:២៤]

**លោក រ៉ូប៊ឺត ពើទីត៖**

លោកប្រធានសូមអនុញ្ញាតផ្អាកប្រហែលជាមួយ ឬពីរ *មីនុត* ព្រោះយើងមានបញ្ហាបច្ចេកទេស ដែលថា យើងខ្ញុំចង់បង្ហាញជូននូវ *ស្លាយ* ជូននូវលោក លោកស្រីចៅក្រម ដែលថាយើងអត់ទាន់បានបង្ហាញដោយសារបញ្ហាបច្ចេកទេស ។ ដូច្នេះសុំអនុញ្ញាតផ្អាក់៥ *មីនុត* ។

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសរៀបចំចាត់ចែងតាមសំណូមពររបស់សហព្រះរាជអាជ្ញា ។

**លោក រ៉ូប៊ឺត ពើទីត៖**

ខ្ញុំសូមនិយាយថា ប្រសិនបើយើងបានរៀបចំពីមុននោះ យើងដំណើរការល្អ ប៉ុន្តែពេលនេះរអាក់រអួល សូមអត់ទោស ។

**ប្រធានអង្គជំនុំ៖**

បាទអញ្ជើញ!

[០៩:២០:៣៧]

**លោកស្រី ជា លាង៖**

តើអង្គជំនុំជម្រះអាចឃើញរូបភាពនឹងដែរ?

**ប្រធានអង្គជំនុំ៖**

មិនឃើញទេៗ បាត់វិញហើយ ។

សូមអញ្ជើញ!

**លោក រ៉ូប៊ឺត ពើទីត៖**

សូមអភ័យទោស ខ្ញុំអាចស្នើថា ឲ្យធ្វើការបញ្ចាំងនៅលើបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

សូមព្រះរាជអាជ្ញាបន្តទៀត ។

**លោកស្រី ជា លាង៖**

សូមអនុញ្ញាតបន្តទៀត ដោយចាប់ផ្តើម ពីរូបភាពដំបូង ។

នៅពេលដែលខ្មែរក្រហមបានឡើងកាន់អំណាចនៅកម្ពុជា ខ្លួនបានបែងចែកស្ថាប័នតាមឋានានុក្រមនយោបាយជាវរសេនាធំដែលបំបែកប្រទេសទៅជាផ្នែកនិងផ្នែកតូចៗខុសគ្នា ។ ផែនទីសម័យកម្ពុជាប្រជាធិបតេយ្យដូចតទៅនេះ បង្ហាញឲ្យឃើញពីឋានានុក្រមនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ។ នេះគឺជាផែនទីនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលភូមិភាគចំនួន៦ ដូចបានឃើញនៅទីនេះ គឺជាផ្នែកដែលធំជាងគេ និងមានអំណាចជាងគេបំផុត ។ ភូមិភាគត្រូវគេបែកចែកទៅជាតំបន់ ហើយតំបន់ត្រូវបានបែងចែកបន្ថែមទៅទៀតជាស្រុក ស្រុកជាបណ្តុំនៃឃុំមួយចំនួន ។ នេះគឺជាដ្យាក្រាមនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលភូមិភាគរាយការណ៍ទៅផ្ទាល់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ហើយតំបន់ឯករាជ្យ ឬស្វយ័តត្រូវបានបង្ហាញដែលមានពណ៌ខុសៗគ្នា ។

ឧទាហរណ៍នេះ គឺជាភូមិភាគនិរតីដែលបានកំណត់សម្គាល់តាមលេខកូដក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ហើយនេះគឺជាតំបន់១៣ ដែលរាយការណ៍ទៅថ្នាក់ដឹកនាំភូមិភាគនិរតី ។

ពីចំណុចនៃការបែកចែកកម្ពុជាទៅជាតំបន់ឋានានុក្រមដ៏តឹងរ៉ឹងនេះ បក្សកុម្មុយនីស្តកម្ពុជាបានមានលទ្ធភាពអនុវត្តនូវគោលនយោបាយព្រហ្មទណ្ឌរបស់ខ្លួន តាមរយៈការផ្សព្វផ្សាយនូវបទបញ្ជាទៅថ្នាក់ក្រោមតាមឋានានុក្រម ។

[០៩:២២:៥៥]

រចនាសម្ព័ន្ធនេះ ក៏បានបានអនុញ្ញាតឲ្យគណៈកម្មការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដឹងអំពីការរីកចម្រើននៃការអនុវត្តគោលនយោបាយនានាដូចដែលបានរាយការណ៍អំពីតំបន់ផ្សេងៗ ។ តាមរយៈការមិនលើកទឹកចិត្តឲ្យមានទំនាក់ទំនង ឬការប្រាស្រ័យទាក់ទងជាផ្លូវការខ្សែទទឹង បក្សកុម្មុយនីស្តកម្ពុជាក៏បានទប់ស្កាត់មិនឲ្យមានសម្ព័ន្ធភាពដែលអាចធ្វើឲ្យខូចដល់ការត្រួតត្រារបស់ពួកគេ ឬដែលធ្វើឲ្យធ្លាក់ចុះដល់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរបស់ពួកគេ ។ នៅទីបំផុតតាមរយៈរដ្ឋ បរិធានរបស់បក្ស និងកម្លាំងប្រដាប់អាវុធ ប្រជាជនកម្ពុជាភាគច្រើនត្រូវបានទទួលរងនូវនយោបាយនៃការជម្លៀសដោយបង្ខំ ពលកម្មដោយបង្ខំ ការចាប់ខ្លួនដោយខុសច្បាប់ ការដាក់ឲ្យជាប់ក្នុងមន្ទីរឃុំឃាំង លក្ខខណ្ឌ

អមនុស្សធម៌ដទៃទៀត ការធ្វើទារុណកម្ម និងការកាប់សម្លាប់ ។

នេះគឺជាឈុតខ្សែវីឌីអូ អំពីការជម្លៀសដោយបង្ខំរបស់កម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជារាប់លាននាក់ត្រូវបានគេបង្ខំឲ្យចេញពីផ្នែកមួយនៃប្រទេសទៅកាន់កន្លែងផ្សេងៗ ។ ការជម្លៀសដោយបង្ខំលើកទី១ បានចាប់ផ្តើមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺនៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានជម្លៀសប្រជាជនចេញពីភ្នំពេញដោយបង្ខំ ។ ឈុតខ្សែវីឌីអូ ខ្លីដូចតទៅនេះ បង្ហាញអំពីទិដ្ឋភាពនៃការជម្លៀសប្រជាជនប្រហែលពីរលាននាក់ពីទីក្រុងភ្នំពេញ ពោលគឺត្រូវបានគេបណ្តេញចេញពីផ្ទះសម្បែងរបស់ខ្លួនក្នុងរយៈពេលមួយយប់ ហើយបង្ខំឲ្យធ្វើដំណើរជាហ្វូងទៅតាមតំបន់ជនបទ ជាមួយហ៊ឹងងរបស់របរបន្តិចបន្តួចដែលអាចយកតាមខ្លួនបាន អ្នកណាដែលរួញរាត្រូវបានសម្លាប់ចោល ។

ដោយសារខ្មែរក្រហមគ្មានអ្វីសម្រាប់ចិញ្ចឹម និងទីជម្រកសម្រាប់អ្នកដែលត្រូវគេជម្លៀស ជាការពិតណាស់មនុស្សរាប់សែននាក់បានស្លាប់ដោយសារការប្រឈម និងបរិយាកាសមិនធ្លាប់ជួប គ្រោះទុរ្ភិក្ស ការនឿយហត់បាក់កម្លាំង និងជំងឺ ។ រូបភាពបង្ហាញពីទីក្រុងខ្មោចទាំងអស់នេះ នូវតែជាបណ្តាំដ៏មានឥទ្ធិពលសម្រាប់ការកំណត់ប្រសិទ្ធភាព និងភាពគ្មានក្តីមេត្តារបស់ខ្មែរក្រហម នៅក្នុងការអនុវត្តគោលនយោបាយរបស់ពួកគេ ។

រលកនៃការជម្លៀសបង្ខំលើកទី២ បានកើតមានឡើងនៅចុងឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៦ ដែលបានបង្កឲ្យមនុស្សរាប់សែននាក់ត្រូវបានគេបង្ខំឲ្យចាកចេញផ្នែកកណ្តាល និងផ្នែកនិរតីនៃប្រទេសទៅកាន់ភូមិភាគពាយព្យ ។ ការជម្លៀសដោយបង្ខំក្នុងទ្រង់ទ្រាយធំមួយទៀតបានកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៨ គឺនៅពេលដែលមនុស្សរាប់ម៉ឺននាក់ ត្រូវបានគេជម្លៀសដោយបង្ខំចេញពីភូមិភាគបូព៌ា ។

បន្ទាប់ពីការគ្រប់គ្រងកម្ពុជា ដោយបក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជាស្ទើរតែទាំងអស់ត្រូវបានគេបង្ខំដោយខុសច្បាប់ នៅក្នុងសហករណ៍ជនបទ ឬការដ្ឋាននានារបស់រដ្ឋាភិបាល ។ នៅក្នុងសហករណ៍ប្រជាជនត្រូវបានគេបង្ខំឲ្យធ្វើពលកម្មនៅក្រោមលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗ ប្រជាជនត្រូវបានគេបង្ខំឲ្យស៊ូទ្រាំនឹងពលកម្ម ដែលក្នុងរយៈពេលវែង ក្នុងលក្ខខណ្ឌធ្វើការងារដ៏រន្ធត់ ដោយគ្មានអាហារ និងការថែទាំផ្នែកពេទ្យគ្រប់គ្រាន់ ។

ខ្សែវីឌីអូ អំពីពលកម្មដោយបង្ខំរបស់កម្ពុជាប្រជាធិបតេយ្យ លក្ខខណ្ឌគួរឲ្យស្អប់ខ្ពើមទាំងនេះក៏បានកើតមានឡើងផងដែរនៅបណ្តាការដ្ឋានធ្វើការរបស់រដ្ឋាភិបាល ហើយមនុស្សរាប់ម៉ឺននាក់ត្រូវបានគេបង្ខំឲ្យធ្វើការលើគម្រោងកសាងដ៏ធំធេងពាក់ព័ន្ធនឹងទំនប់ទឹក អាងស្តុកទឹក ព្រលានយន្តហោះ

និងការងារសាធារណៈដទៃទៀត ។ ដោយជៀសវាងនូវការប្រើឧបករណ៍ទំនើប និងគម្រោងផែនការព្រមទាំងគោលនយោបាយជំនួសសមត្ថភាពការងារ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានធ្វើឲ្យកម្មករធ្វើការដោយបង្ខំរាប់ពាន់នាក់ស្លាប់ ដោយសារការអត់ឃ្លាន ការងារច្រើនហួសហេតុ និងការសម្លាប់ចោល ។ ខ្សែវ៉ឺអូ ខ្លីនេះបង្ហាញអំពីឧទាហរណ៍មួយចំនួននៃគម្រោងការដ៏ធំធេងទាំងនេះ នេះគឺជាគម្រោងលើកទំនប់ និងធ្វើស្រែ ។

[០៩:២៧:៥០]

ដើម្បីធានាឲ្យបាននូវជោគជ័យសម្រាប់បដិវត្តន៍របស់ខ្លួន បក្សកុម្មុយនីស្តកម្ពុជា បានស្វែងរកវិធីដោយលុបបំបាត់អ្នកទាំងអស់ដែលពួកគេចាត់ទុកថាជាខ្មាំង ។ ដោយផ្តើមនៅថ្ងៃដំបូងនៃការឡើងកាន់អំណាចរបស់ពួកខ្លួន បក្សកុម្មុយនីស្តកម្ពុជាបានដាក់ចំណុចដៅទៅលើមេដឹកនាំនយោបាយនៃរបប លន់ នល់ និងមន្ត្រីយោធា ដែលភាគច្រើននៃពួកគេត្រូវបានសម្លាប់ក្នុងអំឡុងនៃការជម្លៀស ដោយបង្ខំពីក្រុងភ្នំពេញ ។ នាយទាហាន និងពលទាហាន មន្ត្រីរាជការ ទោះបីពីដំបូងមិនត្រូវបានគេចាត់ទុកជាអាទិភាពសម្រាប់ការសម្លាប់ក៏ដោយ ក៏បានក្លាយជាគោលដៅសម្រាប់រលកនៃការសម្លាប់នៅពេលក្រោយមកក្នុងឆ្នាំ១៩៧៦ ដែរ ។

បក្សកុម្មុយនីស្តកម្ពុជាក៏បានប្រដេញតាមគោលនយោបាយដ៏ច្បាស់លាស់នូវការលុបបំបាត់សមាជិកវណ្ណៈសេដ្ឋកិច្ច ដូចជា ម្ចាស់ដី ម្ចាស់ហាង ពាណិជ្ជករ អ្នកមានចំណេះដឹង និងអ្នកទាំងឡាយណាដែលបានភ្ជាប់ថា មានការពាក់ព័ន្ធជាមួយនឹងវណ្ណៈទាំងអស់នេះ ។

ប្រជាជនទាំងអស់ដែលគេបានបណ្តេញចេញពីទីក្រុងនានាត្រូវបានចាត់ចូលក្នុងជំពូកប្រជាជនថ្មី និងត្រូវបានគេកំណត់ថា ជាខ្មាំងដ៏សំខាន់ ។ ប្រជាជនថ្មីមួយចំនួនធំត្រូវបានគេសម្លាប់ចោល ដោយសារតែគេចោទថាមិនស្មោះត្រង់ ។ ក្រុមដទៃទៀតដែលទទួលរងការធ្វើបាប និងការកាប់សម្លាប់ដែរ រួមមានវៀតណាម ចាម បញ្ញវន្តកម្ពុជាមកពីបរទេស ដែលត្រូវបានគេបញ្ឆោះបញ្ឆូលឲ្យត្រឡប់ចូលប្រទេសវិញ ខ្មែរកម្ពុជាក្រោម ពុទ្ធសាសនិក និងអ្នកដទៃជាច្រើនទៀត ។ បណ្តាញនៃមជ្ឈមណ្ឌលសន្តិសុខនៅពេញប្រទេស គឺជាសរសរទ្រូងនៃការធ្វើទុកបុកម្នេញនេះ ដែលត្រូវបានគេបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជាទាំងមូល ។

ការផ្ទុះបញ្ចាំងឲ្យឃើញពីមណ្ឌលសន្តិសុខតាមឋានានុក្រមនយោបាយ ត្រូវបានគេបង្កើតឡើនៅគ្រប់ផ្នែកតូចធំទាំងអស់ គឺបានមានការចាប់ផ្តើមពីផ្នែកម្ខាងនៃប្រទេសទៅផ្នែកម្ខាងទៀតនៃប្រទេស ។

រាប់តាំងពីគុកឃុំ ដែលស្ថិតនៅក្រោមគេបង្អស់នៃពីរ៉ាមីត រហូតដល់មន្ទីរស-២១ ដែលនៅកំពូលគេបង្អស់ ។ មណ្ឌលសន្តិសុខទាំងអស់នេះមានគោលបំណងតែមួយគត់ គឺកម្ចាត់ខ្មាំងរបស់របបនេះ ។

[០៩:៣០:៣២]

អ្នកទោសជាច្រើនបំផុតត្រូវបានគេបញ្ជូនទៅមូលដ្ឋានឃុំ ឬក៏ប្រហែលជាទៅមន្ទីរសន្តិសុខស្រុក ជាកន្លែងដែលពួកគេត្រូវបានគេបង្អត់អាហារជាប្រព័ន្ធ ត្រូវតស៊ូទ្រាំនឹងលក្ខខណ្ឌឃុំឃាំងអមនុស្សធម៌ផ្សេងៗ និងពលកម្មដោយបង្ខំ ការធ្វើទារុណកម្មដើម្បីបង្ខំឲ្យឆ្លើយសារភាពចំពោះបទឧក្រិដ្ឋរបស់ខ្លួន និងអ្នកសមគំនិត ហើយក៏ត្រូវបានគេសម្លាប់ចោល ។

ប៉ុន្តែ ប្រសិនបើបទឧក្រិដ្ឋរបស់ពួកគេ ត្រូវបានគេយល់ថាមានជាប់ជំពាក់ទៅនឹងនយោបាយ ឬសន្តិសុខធ្ងន់ធ្ងរនោះ លទ្ធភាពដែលពួកគេត្រូវបានរាយការណ៍ និងបញ្ជូនឡើងទៅមណ្ឌលសន្តិសុខនៅថ្នាក់លើទៀត ក៏មានកាន់តែខ្លាំងឡើងផងដែរ ។

ជាចុងក្រោយ ជាអ្នកទោសជាក់លាក់មួយចំនួនត្រូវបានគេបញ្ចប់នៅមន្ទីរស-២១ ដែលជាខ្សែចុងក្រោយសម្រាប់ជនអភ័ព្វទាំងឡាយណា ដែលបានឡើងមកដល់ទីនេះ ។

មន្ទីរសន្តិសុខភូមិភាគ តំបន់ និងស្រុក ក៏បានទទួលបញ្ជាពីថ្នាក់លើ ហើយចាប់ខ្លួននិងប្រគល់បុគ្គលដែលគេបានឆ្លើយដាក់ថាជាខ្មាំង ដែលមាននៅក្នុងចម្លើយសារភាពរបស់អ្នកទោស ដែលទទួលរងទារុណ្ឌកម្មនៅមន្ទីរស-២១ ។ ពេលបានជាប់ឃុំនៅទីនោះហើយ អ្នកទោសថ្មីនេះដល់វេនដែលខ្លួនត្រូវគេធ្វើទារុណកម្មវិញម្តង រហូតដល់ពួកគេព្រមឆ្លើយសារភាពថា ជាខ្មាំងមែន ហើយភ្ជាប់មិត្ត សហការី និងអ្នកជិតខាងរបស់ពួកគាត់ថាជាខ្មាំងដែរ ដែលបង្កើតបានជាបញ្ជីឈ្មោះជនក្បត់ថ្មីមួយ ដែលនឹងត្រូវបានគេចាប់ខ្លួន ធ្វើទារុណកម្ម និងកម្ទេចចោល ។

វាជាកងវង្វង់ដ៏កាចសាហាវមួយ ហើយចំនួនជនរងគ្រោះចេះតែកើនឡើងរីកធំឡើងទៅតាមពេលវេលា ។ ផែនទីនៃរណ្តៅសាកសពរួមរបស់កម្ពុជាប្រជាធិបតេយ្យ *ស្លាយ* នេះគឺជាការដាក់វាយនៅលើផែនទីជំនាន់កម្ពុជាប្រជាធិបតេយ្យ នូវលទ្ធផលដែលបានមកពីគម្រោងកម្មវិធីមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាហៅថា កម្មវិធីចុះស្រាវជ្រាវ និងធ្វើផែនទីរណ្តៅឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ផែនទីនេះ បង្ហាញពីរណ្តៅសាកសពរួមប្រមាណជា៣៨០កន្លែង ដែលនៅរាយប៉ាយពេញផ្ទៃប្រទេស ។

[០៩:៣៣:០៦]

តភ្ជាប់ទៅនឹងរណ្តៅសាកសពរួមទាំងនោះ គឺជាមន្ទីរសន្តិសុខប្រមាណជា ១៩៥កន្លែង ដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើការចាត់ចែងជនរងគ្រោះរបស់ពួកគេ ។

នៅក្នុងពេលសវនាការនេះ លោក លោកស្រី ចៅក្រម និងជួបបុរសម្នាក់ជាសាក្សី ដែលនឹងនិយាយអំពីឋានានុក្រមដ៏តឹងរ៉ឹងរបស់ប្រព័ន្ធពន្ធនាគារខ្មែរក្រហម ។ ដោយសារអត្តសញ្ញាណរបស់សាក្សីនានាត្រូវបានការពារ មិនឲ្យដឹងនៅក្នុងពេលនេះ យើងខ្ញុំត្រូវហៅគាត់ថា តាមរហស្សនាម KW0១ រូបគាត់ត្រូវបានគេចាប់ខ្លួននៅសហករណ៍មួយដែលស្ថិតនៅទីជនបទដាច់ស្រយាលក្នុងខេត្តមួយនៃប្រទេសកម្ពុជា ។ ហើយដែលមុនដំបូង ត្រូវបានគេដាក់ឃុំឃាំងដោយដាក់ច្រវាក់នៅមន្ទីរសន្តិសុខរបស់សហករណ៍ ។ បន្ទាប់មករូបគាត់ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខស្រុកមួយ ហើយត្រូវបានគេបញ្ជូនពីទីនោះទៅកាន់មន្ទីរសន្តិសុខនៃភូមិភាគពាយព្យ ដែលនៅទីនោះ រូបគាត់ត្រូវបានគេធ្វើទារុណកម្ម ហើយធ្វើទារុណកម្មទៀតជាបន្តបន្ទាប់ ។

ចុងបញ្ចប់រូបគាត់ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរ ស-២១ ដែលជាបណ្តាញនៃមន្ទីរសន្តិសុខ ដែលមានឋានានុក្រមខ្ពស់ជាងគេបំផុតនៃកម្ពុជាប្រជាធិបតេយ្យ ដែលនៅទីនោះរូបគាត់បានជួបតទល់ផ្ទាល់ជាមួយនឹងជនជាប់ចោទនេះ ។ រូបគាត់គឺជាអ្នកតំណាងឲ្យជនជាប់ឃុំ ដែលមានសំណាងជាងគេតែមួយតូចប៉ុណ្ណោះ ដែលជាប់ឃុំឃាំងនៅតាមមណ្ឌលសន្តិសុខនានា ដែលមិនត្រូវបានអស់ជីវិតក្នុងរណ្តៅកប់សពរួមណាមួយ ក្នុងចំណោមរណ្តៅកប់សពរួមទាំងនោះ ។

តុលាការជាទីគោរព!

ទោះបីជា ឌុច មិនត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋណាមួយ ចំណោមឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្រៅមន្ទីរស-២១, មន្ទីរ ស-២៤ និងជើងឯកក្តី ក៏ភស្តុតាងនឹងបង្ហាញឲ្យឃើញថា ឧក្រិដ្ឋ-កម្មទាំងឡាយរបស់គាត់ គឺជាផ្នែកការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធទៅលើប្រជាជនកម្ពុជាដែរ ។ ការវាយប្រហារបែបនេះ បានបណ្តាលឲ្យមានការស្លាប់បុរស ស្ត្រី និងកុមារអស់រាប់សែននាក់ តាមរយៈស្ថានភាពរស់នៅអមនុស្សធម៌ បង្ខំឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ និងការសម្លាប់ ។

[០៩:៣៥:៤១]

ដោយសារតែការដឹងរបស់គាត់អំពីការវាយប្រហារនេះ និងដោយសារតែគាត់មានចេតនាចង់ជំរុញនូវនយោបាយនេះឲ្យបន្តទៅទៀត តាមរយៈការប្រព្រឹត្តិនូវឧក្រិដ្ឋផ្សេងៗ ដែលឧក្រិដ្ឋកម្មទាំងនេះ

ឌុច ត្រូវបានចោទប្រកាន់ថា ជាប្រធាននៃមន្ទីរស-២១ ដែលជាអ្នកដើរតួនាទីសំខាន់ក្នុងការអនុវត្តគោលនយោបាយ ។

ជាការគួរឲ្យកត់សម្គាល់ ការវាយប្រហាររបស់បក្សកុម្មុយនីស្តកម្ពុជា នៅលើប្រជាជនរបស់ខ្លួន គឺមិនដែលជាជម្លោះតែមួយគត់ដែលកើតឡើងនៅក្នុងពេលនោះទេ ។ នៅក្នុងពេលជាមួយគ្នានោះ ប្រទេសកម្ពុជា និងវៀតណាម បានជាប់ដៃនៅក្នុងការជម្លោះប្រដាប់អាវុធមួយនៅតាមព្រំដែនរបស់ខ្លួន ។ ការវាយប្រយុទ្ធគ្នាមានលក្ខណៈខ្លាំងក្លា និងអូសបន្លាយនៅក្នុងទូទាំងអំឡុងពេលនៃកម្ពុជាប្រជាធិតេយ្យកាន់អំណាច ។ ជម្លោះនេះមានការពាក់ព័ន្ធនឹងសវនាការអង្គជំនុំជម្រះនេះ ពីព្រោះ ឌុច ត្រូវបានចោទពីបទបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញានៃទីក្រុងហ្សឺណែវ ដែលលេចចេញមកពីការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ និងការធ្វើមនុស្សឃាតដោយចេតនាទៅលើអ្នកឈ្លើយសឹក និងប្រជាជនស៊ីវិលវៀតណាម ដែលត្រូវបានគេបញ្ជូនទៅមន្ទីរស-២១ ។

អនុសញ្ញានៃទីក្រុងហ្សឺណែវ ជាបន្ថែម ភាគីនានានៃជម្លោះប្រដាប់អាវុធ មានសិទ្ធិត្រូវទទួលបាននូវការការពារមួយចំនួន ។ នៅមន្ទីរស-២១ ការការពារទាំងនេះត្រូវបានគេបដិសេធ ។ ដូច្នេះការសម្លាប់ទាហាន និងជនស៊ីវិលវៀតណាមនៅមន្ទីរស-២១ គឺជាអំពើបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញានៃទីក្រុងហ្សឺណែវ ថែមទាំងបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ ។

ជាជំនួសក្នុងការផ្តល់កិច្ចការពារទៅលើបុរស និងស្ត្រីទាំងនោះ ដូចដែលមានចែងក្នុងអនុសញ្ញានៃទីក្រុងហ្សឺណែវ ឌុច បានធ្វើការត្រួតពិនិត្យមើលទៅលើការឃុំខ្លួន ការធ្វើទារុណកម្ម និងការប្រហារជីវិតរបស់ពួកគេទៅវិញ ។

ភស្តុតាងដែលមាននៅក្នុងសំណុំរឿង បង្ហាញឲ្យឃើញថា ជម្លោះប្រដាប់អាវុធអន្តរជាតិមួយរវាងកម្ពុជានិងវៀតណាម បានចាប់ផ្តើមក្នុងខែមេសា ឆ្នាំ១៩៧៥ និងបង្កើននូវវិសាលភាព និងសន្ទុសន៍នៅក្នុងទូទាំងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាបន្តបន្ទាប់មក ក៏មានការចូលលុកលុយប្រទេសកម្ពុជាក្នុងទ្រង់ទ្រាយដ៏ធំមួយដោយកងទ័ពវៀតណាមនៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ដែលបណ្តាលឲ្យមានការដួលរលំនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងខែមករា ឆ្នាំ ១៩៧៩ ។

[០៩:៣៨:៣៧]

ឌុច បានដឹងអំពីជម្លោះប្រដាប់អាវុធនេះ និងបានដឹងថា ទាហាន និងប្រជាជនស៊ីវិលវៀតណាម ដែលគាត់បានទទួលមកនេះ ត្រូវបានគេចាប់ខ្លួន គឺពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ។ ការប្រយុទ្ធគ្នារវាង

កងទ័ពកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពវៀតណាមបានកើតមានឡើងនៅតាមបណ្តោយព្រំដែនជាមួយវៀតណាម និងតាមកោះនានាដែលស្ថិតនៅឆ្នេរសមុទ្រកម្ពុជា នៅក្នុងអំឡុងឆ្នាំ១៩៧៥ និងចូលឆ្នាំ១៩៧៦ ។

ឃុតឆាកដូចខាងក្រោមនេះបង្ហាញឲ្យឃើញអំពីឧទាហរណ៍មួយ ក្នុងចំណោមការវាយប្រយុទ្ធគ្នានៅតាមព្រំដែនទាំងនេះ ។ ឃុតឆាកនេះ ពីទាហានខ្មែរក្រហមដែលកំពុងវាយប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាម ការប៉ះទង្គិចទាំងនេះ បានមានសន្ទុះរឹតតែខ្លាំងឡើងៗជានិច្ច និងបានកើតឡើងជាញឹកញាប់ ក៏ដូចជាទំហំភូមិសាស្ត្រដ៏កាន់តែរីកធំឡើងដែរ ។

មិនយូរប៉ុន្មាន ក៏មានការប្រយុទ្ធគ្នានៅតាមបណ្តោយខ្សែព្រំដែនកម្ពុជា-វៀតណាមទាំងមូលដោយសារការចូលចូលលុកលុយដោយអាវុធទៅវិញទៅមកទាំងសងខាង ។ ខ្សែបន្ទាត់ពណ៌ក្រហមដែលមានគូសនៅលើផែនទី នៅក្នុងសម័យខ្មែរក្រហមនេះដែរ ដែលបានបង្ហាញកាលពីមុន បង្ហាញឲ្យឃើញជាលក្ខណៈទូទៅថា តើកន្លែងណាខ្លះដែលប៉ះទង្គិច បានកើតមានឡើងនៅតាមបណ្តោយព្រំដែន ។ នេះជាផែនទីរបស់កម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញអំពីព្រំដែននៃប្រទេសវៀតណាម ។

នៅដើមឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានជ្រៀតចូលនៅក្នុងទឹកដីកម្ពុជា ក្នុងខេត្តស្វាយរៀង ក្នុងខែសីហា ឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការតបមកវិញ ដោយការវាយចូលក្នុងខេត្តតាយនិញ ក្នុងទឹកដីវៀតណាម ។ ការចោទប្រកាន់អំពីអំពើសាហាវព្រៃផ្សៃផ្សេងៗ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលដែលកម្ពុជាប្រជាធិបតេយ្យវាយឆ្មក់ចូលក្នុងទឹកដីវៀតណាម ជាមូលហេតុដែលកងទ័ពវៀតណាមធ្វើការវាយលុកដ៏ធំមួយនៅចុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ដោយកងទ័ពវៀតណាមចំនួន ១១ កងពលធំ បានជ្រៀតចូលរហូតដល់ចម្ងាយប្រមាណ៤០គីឡូម៉ែត្រមកក្នុងទឹកដីកម្ពុជា មុនពេលដែលពួកគេបញ្ចប់ការលុកលុយរបស់ខ្លួន ។

ការវាយលុកដ៏ធំធេងនេះ ត្រូវបានបន្តតាមក្រោយឲ្យរយៈពេលមួយនៃការប៉ះទង្គិចគ្នាតាមព្រំដែនដែលជាលក្ខណៈទូលំទូលាយមួយនៅក្នុងអំឡុងពេលភាគច្រើនក្នុងឆ្នាំ១៩៧៨ ដែលបានឈានទៅដល់កម្រិតខ្ពស់បំផុត ដែលបណ្តាលឲ្យវៀតណាមធ្វើការចូលលុកលុយក្នុងទឹកដីកម្ពុជាម្តងទៀត នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមចំនួនរហូតដល់១៥០.០០០នាក់ បានធ្វើការវាយប្រហារចូលក្នុងទឹកដីកម្ពុជា ហើយរដ្ឋាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា ក៏បានដួលរលំព្រមគ្នានឹងការចូលកាន់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ។

[០៩:៤១:៥៣]

អស្ថិរភាពនៃជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមនេះ ត្រូវបានបញ្ជាក់ការពិតដោយឯកសារចំនួនជាងបួនរយឯកសារនៅក្នុងសំណុំរឿង ដែលរាប់បញ្ចូលទាំងសៀវភៅជាច្រើនក្បាលទៀត សេចក្តីរាយការណ៍តាមបណ្តាញផ្សព្វផ្សាយព័ត៌មាននានានៅក្នុងសម័យកាលជាមួយគ្នានោះ ចំនួនជាងពីររយអត្ថបទ សារទូរលេខ និងរបាយការណ៍ពីកងកម្លាំងប្រដាប់អាវុធនៃតំបន់កម្ពុជាប្រជាធិបតេយ្យជាងមួយរយ ដែលរាយការណ៍ស្តីពីការប៉ះទង្គិចគ្នាជាមួយនឹងកម្លាំងរបស់វៀតណាម ។

ឯកសារនានាជាច្រើនរបស់មន្ទីរស-២១ ដែលចុះអំពីទាហានវៀតណាមដែលជាជនជាប់ឃុំឃាំង ព្រមទាំងចម្លើយពីសាក្សីនានាជាច្រើន ដែលនៅក្នុងនោះរួមមានទាំងមានការចាប់ខ្លួនៗឯងផង ។ ស្ថិរភាពនៃជម្លោះប្រដាប់អាវុធ និងការដឹករបស់ ឌុច អំពីជម្លោះប្រដាប់អាវុធនេះ គឺជាភស្តុតាងដែលមិនអាចប្រកែកបានឡើយ ។

អង្គជំនុំជម្រះជាទីគោរព!

គឺនៅក្នុងបរិបទនៃសង្គ្រាមជាមួយវៀតណាម គឺការវាយប្រហារដោយរបបនេះប្រឆាំងនឹងប្រជាជនកម្ពុជា ដែលមន្ទីរស-២១ ត្រូវបានបង្កើតឡើង និងបានដំណើរការ ក៏ប៉ុន្តែអាទិភាពរបស់មន្ទីរ និងកម្រិតនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងមន្ទីរនេះ ទើបតែបានចាប់ផ្តើមបញ្ចេញឱ្យដឹងនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ១៩៧៩ ប៉ុណ្ណោះ ។ នៅថ្ងៃនោះទាហានទ័ពស្រួចនៃកងទ័ពវៀតណាមបានប្រទះឃើញថៃជន្យនូវទីតាំងដែលមានរបងការពារដ៏រឹងមាំមួយនៅក្នុងទីក្រុងភ្នំពេញ ដែលហាក់ដូចជាត្រូវបានគេបោះបង់ចោល ។ នេះគឺជាអ្វីដែលពួកគេបានឃើញ ។

អង្គជំនុំជម្រះជាទីគោរព!

ភាពលំបាកដូចដែលយើងនឹងឃើញនៅក្នុងខ្សែវីដេអូនេះ វាគ្រាន់តែជាការចាប់ផ្តើមដំបូងតែប៉ុណ្ណោះ ជាបន្តបន្ទាប់មកទៀត ពិភពលោកត្រូវតែទទួលស្គាល់អំពីយន្តការនៃការសម្លាប់នោះ។

**លោកហ្វ្រង់ស្វ័រ រូះ**

*(គ្មានការបកប្រែ)*

អង្គជំនុំជម្រះត្រូវការសម្រេចទៅលើរូបភាពនេះ នេះគឺជាកម្មវត្ថុនៃការស្នើសុំ ហើយគឺអ្វីដែលលើកឡើងដោយសហព្រះរាជអាជ្ញាគឺ ខ្ញុំមានការភ្ញាក់ផ្អើល ដោយសារតែរូបភាពនេះបានបង្ហាញជូនមុនពេលការធ្វើសេចក្តីសម្រេច ។

**លោក រ៉ូប៊ឺត ពើទីត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសូមរំឭកខាងសហព្រះរាជអាជ្ញាថា យើងបានពិភាក្សាគ្នាពីវីដេអូនេះហើយ មិនមែនប្រធានបទនៃការពិភាក្សាចំពោះអង្គជំនុំជម្រះទេ នេះគឺជាខ្សែភាពយន្តដែលបាននៅក្នុងសំណុំរឿងជាងពីរឆ្នាំមកហើយ ដោយការអនុញ្ញាតពីអង្គជំនុំជម្រះ ខ្ញុំសូមអនុញ្ញាតជម្រាប ដល់ខាងមេធាវីថា គឺថាមិនគប្បីមានការជំទាស់ពីភាគី ក្នុងដំណាក់កាលបើកសេចក្តីប្រកាសនេះទេ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបន្តទៅទៀត ដែលថាមេធាវីបានដឹងពីអង្គហេតុនោះហើយ ។

[០៩:៤៥:២៩]

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធាន លើកលែងតែមានការជំទាស់ ហើយខ្ញុំសូមជំទាស់ ហើយសូមរក្សាការជំទាស់នេះ ដូច្នេះ ឯកសារនេះគឺថិតនៅក្នុងសំណុំឯកសារតាំងពីជំនាន់មុន ហើយខ្ញុំយល់ថាវាដូចគ្នា ដែលថាឯកសារដែលបានបង្ហាញនៅក្នុងពេលអនុលោម ទៅតាមគំនិតនេះ ។ សហព្រះរាជអាជ្ញាសូមពន្យល់ដល់អង្គជំនុំជម្រះ ហេតុអ្វីបានជាបង្ហាញច្រើន ដែលថាយើងបានកត់ត្រានៅក្នុងសំណុំរឿងនោះរួមមកហើយ ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក រ៉ូប៊ឺត ពើទីត៖**

ពាក្យថារូបភាពនេះ គឺអត់មានតួនាទីទេ គឺថាតុលាការគឺត្រូវផ្តល់យុត្តិធម៌ដល់អ្នកទោស-២១ ។ តាំងពីឆ្នាំ២០០៧ គឺយើងបានបង្កើតភស្តុតាងជាច្រើនដែលមាននៅក្នុងសំណុំរឿង រួមទាំងរូបភាពផងដែរ ។ ហើយគឺការជំទាស់របស់មេធាវី ដែលបានលើកឡើង គឺថាភស្តុតាងដោះបន្ទុកនឹងត្រូវបានដាក់ និងភស្តុតាងដាក់បន្ទុកក៏ត្រូវបានដាក់ផងដែរ ។ ហើយខ្ញុំសូមយកឱកាសនេះ នាពេលនេះ សូមរំឭកថាសេចក្តីផ្តើមនៃការអានបទចោទមិនគួរធ្វើការរារាំង ឬក៏ការធ្វើអន្តរាគមន៍ណាមួយពីភាគីនោះទេ ។

**ប្រធានអង្គជំនុំ៖**

សូមសហព្រះរាជអាជ្ញាឡើងធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីខ្សែវីដេអូដែលបានបង្ហាញអម្បាញ់មិញនេះ ដែលត្រូវបានជំទាស់ដោយមេធាវីការពារក្តី តើវីឌីអូហ្នឹងមានលក្ខណៈយ៉ាងម៉េចទៅ ? វាជាខ្សែវីដេអូថ្មី ឬក៏ជាខ្សែវីដេអូដែលបានរៀបចំរួចហើយ ដែលមាននៅក្នុងសំណុំរឿងស្រាប់ គ្រាន់តែ

យកមករៀបចំបំពេញទៅតាមបទបង្ហាញតែប៉ុណ្ណោះទេ ?

[០៩:៥១:១១]

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមបញ្ជាក់ថា រាល់ភស្តុតាងនីមួយៗដែលយើងបានជជែកនៅថ្ងៃនេះនោះ សុទ្ធតែបង្ហាញជូននៅក្នុងអេក្រង់ ហើយនៅក្នុងសំណុំរឿងទាំងអស់ គឺឋិតនៅក្នុងសំណុំរឿង ហើយបានឋិតនៅក្នុងសំណុំរឿង វាអស់រយៈពេលប្រហែលជា គឺថា៩០ភាគរយនោះ គិតថាលើកលែងតែចម្លើយរបស់សាក្សីនោះ គឺថាជាងពីរឆ្នាំមកហើយនៅក្នុងនោះ ។ ខ្ញុំស្នើថា ប្រសិនបើមេធាវីមានជំទាស់ទៅនឹងភស្តុតាងណាមួយនេះ គឺថានៅក្នុងពេលណាមួយសមស្រប គិតថាដកចេញឬក៏ស្នើសុំឲ្យដកចេញពីសំណុំរឿងនោះ ដោយដាក់ចូលនូវបណ្តឹង ឬក៏ការស្នើសុំទៅសហចៅក្រមស៊ើបអង្កេត លោកមេធាវីនោះ គឺថាបានចេញមកអំពីប្រព័ន្ធស៊ីវិលឡ គឺដឹងច្បាស់ថា ខ្ញុំកត់សម្គាល់ថាវិធាន គឺថាយើងត្រូវគោរព ដែលថាដីកាដំណោះស្រាយចូលជាស្ថាពរហើយ ហើយភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ។ ហើយលោក លោកស្រីបានបញ្ជាក់ហើយ នៅក្នុងសវនាការមុនអង្គសេចក្តីនោះ គឺភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង អាចលើកឡើងដោយភាគីទាំងអស់ ហើយបន្ទាប់ពីនោះ គឺអាស្រ័យទៅលើលោកស្រីចៅក្រម ថាតើយើងត្រូវ ថាតើភស្តុតាងទាំងអស់ត្រូវមកប្រើ ដើម្បីបញ្ជាក់ឲ្យច្បាស់ថាភស្តុតាងទាំងអស់ ដែលយើងនឹងយោងរកនៅថ្ងៃនេះ គឺថាមានស្ថិតនៅក្នុងសំណុំរឿងទាំងអស់ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតរាយច៍៖**

អរគុណលោកពើទីត ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងចង់ដឹងថា ថាតើរូបភាពវីដេអូដែលលោកបានលើកឡើងថាមាននៅក្នុងសំណុំរឿងនោះគឺវាជាមួយត្រឹមត្រូវដែរឬទេ ? ហើយវាដូចទៅនឹងរូបភាពវីដេអូ ដែលវាជាកម្មវត្ថុនៃការដាក់ពាក្យសុំទៅចំពោះអង្គជំនុំជម្រះសាលាដំបូង គឺថាពាក្យសុំដែលមិនទាន់បានធ្វើការសម្រេចនៅឡើយ ។

**លោក រ៉ូប៊ីត ពើទីត៖**

អរគុណ។ ខ្ញុំព្យាយាមស្តាប់ការបកស្រាយ ហើយខ្ញុំសូមឆ្លើយតប ។

អត់ទេ រូបភាពនេះគឺខុសគ្នាហើយយើងបានមកនៅពេលនេះ គឺថាយើងនឹងចំណាយពីភាពខុសគ្នា ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា យើងដឹងច្បាស់ ជាសហព្រះរាជអាជ្ញា ដឹងអំពីកាតព្វកិច្ច អំពីការិយាល័យរបស់យើង ហើយយើងគោរពតាមសាលក្រម និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងរហូតដល់ពេលមានការធ្វើសេចក្តីសម្រេច ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ការ សាវុត្ថ ។

[០៩:៥៤:០១]

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន ។ នៅក្នុងចំណុចទីបួននេះ គឺការធ្វើសេចក្តីសន្និដ្ឋាន ហើយនៅក្នុងធ្វើសេចក្តីសន្និដ្ឋាននេះ គឺថាលោកប្រធាននៅក្នុងនីតិវិធីនេះគឺថាឲ្យសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានដោយមិនបានបញ្ជាក់ថា នៅពេលធ្វើសេចក្តីសន្និដ្ឋាននេះ តើមានបង្ហាញភស្តុតាងឬទេ ? វាអត់មាននិយាយទេ ហេតុអីក៏យកព្រះរាជអាជ្ញាមកបង្ហាញពេលនេះ ភស្តុតាងខ្លះអីពេលក្រោយបង្ហាញក៏បាន ព្រោះពេលនេះឲ្យតែធ្វើសេចក្តីសន្និដ្ឋានទេ មិនទាន់ដល់ពេលបង្ហាញភស្តុតាងទេ ។ សូមអរគុណ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

យើងមានឱកាស នេះជាឯកសារមួយដែលមិនបានពិភាក្សាទេនៅក្នុងដំណាក់កាលស៊ើបអង្កេត យើងបានចំណាយពេលមួយឆ្នាំហើយ ជាមួយសហចៅក្រមស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ខ្ញុំតែងតែស្នើសុំ ថាឯកសារទាំងអស់នៅក្នុងកំណត់ត្រានៃសំណុំរឿងត្រូវតែមានទាំងអស់នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំបញ្ជាក់ថា វានឹងមានយុត្តិធម៌ ប្រសិនបើមុនដែលសហព្រះរាជអាជ្ញាលើកឡើងនូវខ្សែភាពយន្តនេះ ដែលជាឯកសារដើម្បីមានគោលបំណងលើកឡើងហើយកម្មវត្ថុដែលបានលើកឡើងចំពោះអង្គជំនុំជម្រះវានឹងមានយុត្តិធម៌ដល់សហព្រះរាជអាជ្ញា--

**អ្នកបកប្រែ៖**

មិនគ្មានការបកប្រែទេដោយស្តាប់មិនឮ ។

ថាតើខាងបកប្រែភាសាអង់គ្លេសហ្នឹងឮដែរឬទេ ? តើអាចស្តាប់បានទេ ?

[០៩:៥៦:២៩]

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំមានឯកសារច្រើនពាន់ទំព័រនៅក្នុងឯកសារ-- នោះវានឹងមានយុត្តិធម៌ក្នុងដំណាក់កាលស៊ើបអង្កេត ដើម្បីសហព្រះរាជអាជ្ញាដើម្បីស្នើឲ្យទទួលយកជាឯកសារដោយលើកឡើងមកពិភាក្សាតទល់គ្នា ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន មានបញ្ហាបកប្រែ! មានបញ្ហា?

សុំអញ្ជើញមេធាវី អញ្ជើញបន្តទៀត ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមចាត់ចែងរៀបចំឲ្យបានល្អ អ្នកបច្ចេកទេស ។

**អ្នកបកប្រែ៖**

សូមធ្វើការសាកល្បង នេះគឺជាប៉ុស្តិ៍ខ្មែរ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ អ្វីដែលខ្ញុំបានលើកឡើង គឺយើងមានរយៈពេលមួយឆ្នាំកន្លះនៃការស៊ើបអង្កេត ដែលជាប្រព័ន្ធនៃការតទល់ គឺសហព្រះរាជអាជ្ញាជាអ្នកធ្វើការស៊ើបអង្កេត ហើយគឺថាឯកសារជាច្រើនបានធ្វើការពិភាក្សានិងស៊ើបអង្កេត ក្នុងដំណាក់កាលស៊ើបអង្កេត ។ ប៉ុន្តែ ឯកសារមួយចំនួនមិនទាន់បានធ្វើការតទល់គ្នានៅឡើយ ប្រសិនបើលោក លោកស្រី លើកឡើងមុនពេលនេះ គឺថាសហព្រះរាជអាជ្ញា បានប្រកាសថា គាត់បានរកឃើញឯកសារជាច្រើន ហើយគាត់មានបំណងក្នុងការលើកឡើងនិងបង្ហាញ ។ អ្វីដែលយើងបានឃើញនៅថ្ងៃនេះ យើងឃើញថា យើងឃើញនៅក្នុងសំណុំរឿងនូវឯកសារមួយចំនួនដែលយើងមិនទាន់បានធ្វើការពិភាក្សាតទល់នៅក្នុងអំឡុងពេលការស៊ើបអង្កេត ហើយរូបភាពនោះ គឺវាដូចគ្នា គឺវាមិនមែនជាការជំនុំជម្រះដោយយុត្តិធម៌ទេ ប្រសិនបើជាសហព្រះរាជអាជ្ញាចង់នៅក្នុងដំណាក់កាលនេះ ប្រើប្រាស់ឯកសារមិនបានពិភាក្សាតទល់គ្នាក្នុងពេលស៊ើបអង្កេត អ្វីដែលគាត់អាចធ្វើបាន គឺគាត់ត្រូវឲ្យសហមេធាវីគាត់បានដឹង ។ គឺយើងឃើញមានឯកសារ១៧.000 ទំព័រថា តើសហមេធាវីគាត់អាចធ្វើការរៀបចំយ៉ាងម៉េចដែលឯកសារទាំងអស់នោះ មិនបានធ្វើការ

ពិភាក្សាដេញដោលក្នុងពេលស៊ើបអង្កេតដោយមិនបានចង្អុលបញ្ជាក់ជូនសហមេធាវីការពារក្តី និងអង្គជំនុំជម្រះថាតើឯកសារទាំងអស់នោះគឺជាអ្វី? ដោយមិនបានបង្ហាញថាឯកសារនោះចង់លើកឡើងនៅពេលនេះ ។ អ៊ីចឹង គឺវាដូចគ្នានឹងឯកសារដែលលោកព្យាយាមចង់បញ្ចូលនៅក្នុងសំណុំរឿង គឺរូបភាពនៅស-២១ ។ គឺលោកបង្ហាញពីរូបភាពស-២១ លោកមិនបានជម្រាបអំពីរូបភាព ហើយគឺរូបភាពដែលបានបង្ហាញនេះ គឺលោកលើកឡើងថាមាននៅក្នុងសំណុំរឿង ។ គឺវាមិនបានបង្ហាញនៅពេលស៊ើបអង្កេតនៅដំណាក់កាល-- នៅក្នុងដំណើរការរបស់គឺថាអ្វីៗត្រូវតែបង្ហាញឲ្យមានការតទល់គ្នាក្នុងដំណាក់កាលស៊ើបអង្កេត ។

[១០:០១:២៨]

**លោក រ៉ូប៊ឺត ពើទីត៖**

ខ្ញុំសូមអភ័យទោសដើម្បីពន្យារពេលនេះ ហើយខ្ញុំនឹងលើកឡើងអំពីការអះអាងរបស់ខ្ញុំ ។ ទីមួយគឺមិនមែនជាសំណុំរឿងរបស់យើងទេ គឺជាសំណុំរឿងរបស់តុលាការ ។ គឺជាឯកសាររបស់សហចៅក្រមស៊ើបអង្កេត ។ ឥឡូវនេះជាឯកសាររបស់លោកមេធាវីការពារដែរ ។ មិនមែនមួយម៉ឺនប្រាំមួយពាន់មិនមែនមួយម៉ឺនប្រាំពីរពាន់ទេ ។ វាជាអង្គហេតុតែមួយជាឯកសារក្នុងឆ្នាំ២០០៧មក ហើយគឺថាអាចនឹងមានការកែតម្រូវបន្តិចបន្តួចនៅក្នុងដំណាក់កាលមានចម្លើយរបស់សាក្សីមួយចំនួន ហើយបានពិនិត្យយ៉ាងជាក់លាក់ដោយសហព្រះរាជអាជ្ញា ហើយយើងបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានរបស់ខ្លួននៅក្នុងខែកក្កដា ឆ្នាំ២០០៧ ដែលថាមេធាវីមានបទពិសោធន៍នៅក្នុងអន្តរជាតិ ដែលថាបានពិនិត្យមើលដោយចេតនាច្បាស់លាស់ហើយ ។ គឺថាឯកសារភស្តុតាងទាំងអស់យើងបានយោងទៅរកនោះ ។ គឺពីរឆ្នាំមកហើយ ដែលថាជាភស្តុតាងពាក់ព័ន្ធ ហើយដែលអាចទទួលបានសម្រេច ដើម្បីដាក់មកជូនដោយសហព្រះរាជអាជ្ញាដើម្បីគាំទ្រការចោទប្រកាន់នេះ ។

ដូច្នេះ ខ្ញុំមានការយល់ច្រឡំបន្តិចអំពីការភ្ញាក់ផ្អើលរបស់មេធាវីនៅពេលនេះ តើហេតុអ្វីដែលថាលោកយល់ថាភស្តុតាងនេះពាក់ព័ន្ធមិនពាក់ព័ន្ធនោះ?

[១០:០២:៤៥]

ដូចដែលខ្ញុំយល់អំពីកាយវិការនៃអន្តរាគមន៍នោះ គឺអំពីខ្សែភាពយន្តឯកសារនេះ ហើយយើងអាចបង្ហាញខ្សែវីដេអូពីរនេះដែលអាចនឹងឃើញមានភាពខុសគ្នា ប៉ុន្តែយើងនិយាយអំពីស-២១ ។ មេធាវីការពារនិយាយថា "គ្រប់ពេលទាំងអស់យើងនិយាយពីស-២១ គឺយើងនិយាយតែម្តងបានហើយគឺមាន

ភស្តុតាងតែមួយ" ។ ដើម្បីកម្រិតអំពីការពិចារណាភស្តុតាង ដែលថា វាស្ថិតនៅក្នុងសំណុំរឿង គឺភាពខុសគ្នានោះថាអាចនឹងឲ្យលោកប្រាប់យើងថា តើភាគីអាចយោងទៅចំណុចណាមួយក្នុងសំណុំរឿងដែរឬទេ? ខ្ញុំមិនថាសមស្របនោះទេ ។

ដូច្នេះការអន្តរាគមន៍របស់មេធាវីការពារនោះមិនស្របទេ ។ ដូច្នេះ ខ្ញុំសុំស្នើថាបន្តតាមពិត ដើម្បីឲ្យទទួលពេលវេលាសមស្របដើម្បីគោរពតាមពេលវេលា ដើម្បីយើងអាចនឹងឲ្យសវនាការនេះបន្តទៅទៀតបាន ។ សូមអរគុណ ។

[១០:០៦:៤៣]

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីបានស្តាប់នូវសម្តីជំទាស់ដោយលោក ហ្វ្រង់ ស្វ័រ រូ ដែលជាមេធាវីការពារឲ្យជនជាប់ចោទ លើកការបញ្ចាំងនូវខ្សែវីដេអូ ហើយទន្ទឹមនឹងនេះក៏មានការឆ្លើយតបបង្ហាញដោយសហព្រះរាជអាជ្ញា ពាក់ព័ន្ធជាមួយនឹងការជំទាស់នេះ ។ អង្គជំនុំជម្រះយល់ឃើញថា ការជំទាស់របស់មេធាវីនេះក្នុងករណីនេះ គឺមិនត្រឹមត្រូវទេ គឺច្រានចោលការជំទាស់នេះ ។ ហើយអនុញ្ញាតសហព្រះរាជអាជ្ញាធ្វើការសេចក្តីថ្លែងសង្ខេបអំពីបទចោទប្រកាន់បន្តទៀតនូវតាមអ្វីដែលបានគ្រោងទុក ។ សូមអញ្ជើញ ។

[១០:០៧:៣៦]

**លោកស្រី ជា លាង៖**

ខន្តីញោម ។ សូមអរគុណ ហើយសុំអនុញ្ញាតបន្តទៀត ។

អង្គជំនុំជម្រះជាទីគោរព! ភាពលំបាកដូចដែលយើងនឹងឃើញនៅក្នុងខ្សែវីដេអូនេះ វាគ្រាន់តែជាការចាប់ផ្តើមដំបូងតែប៉ុណ្ណោះ ។ ជាបន្តបន្ទាប់មកទៀត ពិភពលោកត្រូវតែទទួលស្គាល់អំពីយន្តការនៃការសម្លាប់នេះ គឺមន្ទីរស-២១ និងតួនាទីដ៏សំខាន់បំផុតរបស់មន្ទីរនេះក្នុងការធ្វើឲ្យប្រជាជនកម្ពុជាត្រូវរងទុក្ខវេទនា ។ ទោះបីជាយ៉ាងណាក៏ដោយ មុនពេលដែលយើងពិនិត្យមើលភស្តុតាងមួយចំនួននៃបទឧក្រិដ្ឋផ្សេងៗ ដោយបានប្រព្រឹត្តនៅមន្ទីរស-២១ នោះ យើងនឹងបញ្ជាក់ឲ្យច្បាស់មុនគេបំផុតគឺអំពីផ្នែករូបវន្តនិងរចនាសម្ព័ន្ធរបស់មន្ទីរនេះ ។

មន្ទីរស-២១ រួមមាន៖ ទីតាំងស្នាក់ការធំ តំបន់ជិតខាងដែលនៅជាប់គ្នាដែលនៅជុំវិញបរិវេណទីតាំង ជំរំសម្រាប់ធ្វើពលកម្មដោយបង្ខំមួយនៅព្រៃស ដែលជាចំណុះដែលត្រូវបានគេស្គាល់ថាជាមន្ទីរស-២៤ ព្រមទាំងកន្លែងសម្រាប់ប្រហារជីវិត និងកប់សពដែលស្ថិតនៅជើងឯក ។

[១០:០៩:០០]

ផែនទីទីក្រុងភ្នំពេញនិងតំបន់ព័ទ្ធជុំវិញ ឥឡូវនេះបើពិនិត្យមើលផែនទីនៅទីក្រុងភ្នំពេញនិងតំបន់ព័ទ្ធជុំវិញយើងអាចឃើញមានប្រអប់ព៌ណបៃតងមួយដែលស្ថិតនៅផ្នែកខាងលើនៃជ្រុងខាងស្តាំដៃ នោះហើយជាកន្លែងដែលទីតាំងស្នាក់ការកណ្តាលនៃមន្ទីរស-២១ នៅទីនោះ ។ ប្រអប់ព៌ណខៀវនៅខាងត្បូងនិងដែលនៅពីខាងក្រោមនៅមន្ទីរស-២១ គឺជើងឯក ។ ជាកន្លែងដែលអ្នកទោសមន្ទីរស-២១ ភាគច្រើនត្រូវបានគេយកទៅសម្លាប់ ហើយសាកសពរបស់ពួកគេត្រូវបានកប់នៅទីនោះ ។ ប្រអប់ព៌ណក្រហមដែលនៅខាងលិចជើងឯក ដែលនៅពីក្រោមជើងឯកនៅខាងជ្រុងខាងឆ្វេងដៃគឺជាមន្ទីរស-២៤ ។ មន្ទីរស-២៤ ស្ថិតនៅក្នុងតំបន់មួយដែលស្ថិតព័ទ្ធជុំវិញពន្ធធនាគារចាស់មួយតាំងពីសម័យអាណានិគមនិយមដែលត្រូវបានដំណើរការធ្វើជាកន្លែងសម្រាប់អប់រំកែប្រែ និងជាជំរំសម្រាប់ធ្វើពលកម្មដោយបង្ខំមួយ ។

[១០:១០:១២]

ទីតាំងទាំងអស់នេះស្ថិតនៅក្នុងឋានានុក្រមរបស់មន្ទីរស-២១ និងដែលត្រូវត្រួតត្រាដោយ ឌុច ក្នុងនាមជាប្រធានមន្ទីរស-២១ ។ ផែនទីផ្លូវចូលនៃទីក្រុងភ្នំពេញ ឥឡូវនេះបើពិនិត្យទៅមើលផែនទីនៃទីក្រុងនោះ យើងអាចមើលឃើញមន្ទីរស-២១ បានលម្អិតជាងនេះ ។ តំបន់ដែលមានព៌ណក្រហម បង្កើតបានជាទីតាំងមន្ទីរកណ្តាលនៃមន្ទីរស-២១ ហើយដែលឥឡូវនេះជាសារមន្ទីរប្រល័យពូជសាសន៍ទួល-ស្លែង ។ តំបន់ព៌ណលឿងដែលព័ទ្ធជុំវិញទីតាំងមន្ទីរកណ្តាលក៏ត្រូវបានត្រួតត្រាដោយមន្ទីរស-២១ និងជាផ្នែករបស់មន្ទីរស-២១ ដែរ ។

ក្នុងតំបន់នេះមានអគារសំខាន់ៗជាច្រើនសម្រាប់កិច្ចដំណើរការការងាររបស់មន្ទីរស-២១ ។ អគារទាំងអស់នោះរួមមាន៖ ផ្ទះមួយចំនួនសម្រាប់សួរចម្លើយនិងធ្វើទារុណកម្ម ពន្ធធនាគារពិសេសមួយសម្រាប់ដាក់អ្នកទោសសំខាន់ៗ អគារមួយសម្រាប់ទទួលអ្នកទោស កន្លែងសម្រាប់ប្រហារជីវិតមួយចំនួន និងរណ្តៅកប់សពរួមនានា។ សាលសម្រាប់បរិភោគអាហាររួមសម្រាប់បុគ្គលិកមន្ទីរស-២១ ឃ្លាំងផ្សេងៗ ប៉ុស្តិ៍ឆែកឆេរមួយចំនួន និងផ្ទះសម្រាប់បុគ្គលិកមន្ទីរស-២១ ដែលរួមទាំងផ្ទះមួយចំនួនដែល ឌុច បានប្រើប្រាស់នៅទូទាំងរយៈពេលដែលគាត់កាន់តំណែង ។

មន្ទីរស-២១ បានគ្របដណ្តប់មហាវិថីម៉ៅសេទុងទៅខាងត្បូង មហាវិថីមុនីវង្សទៅខាងកើត មហាវិថីសីហនុទៅខាងជើង ហើយនិងផ្លូវលេខ១៦៣ ទៅខាងលិច ។ ទីតាំងមួយចំនួនក្នុងចំណោមទីតាំងជាពិសេសទាំងអស់នេះ ដែលស្ថិតនៅខាងក្រៅទីតាំងមន្ទីរកណ្តាលនៃមន្ទីរស-២១ បានកំណត់

សម្គាល់នៅក្នុងផែនទីដែលថតពីលើអាកាសនៃតំបន់ពីមន្ទីរស-២១ អំពីតំបន់នេះ ។ ទីតាំងស្នាក់ការកណ្ដាលនៃមន្ទីរស-២១ បើមើលឲ្យជិតត្រង់ទីតាំងមន្ទីរកណ្ដាលនោះ លោក លោកស្រីចៅក្រមនឹងអាចមើលឃើញអគារធំៗចំនួនប្រាំ ដែលដាក់អក្សរថា “ក”, “ខ”, “គ”, “ឃ”, និង “ង” ។ អគារ “ង” គឺជាកន្លែងដែលគេថតរូបអ្នកទោស និងធ្វើប្រវត្តិរូបអ្នកទោស ដែលជាផ្នែកនៃកិច្ចដំណើរការនៃការចុះបញ្ជី ។

[១០:១២:៥៨]

ចេញពីអគារ “ង” ទៅអ្នកទោសទាំងឡាយនឹងត្រូវគេនាំទៅកាន់អគារ “ក”, “ខ”, “គ” ឬ “ឃ” ដែលនៅក្នុងអគារទាំងនោះមានបន្ទប់សម្រាប់ឃុំឃាំងជាច្រើន ។ អ្នកទោសដែលសំខាន់ៗត្រូវគេដាក់នៅក្នុងអគារ “ក” ។

បន្ទាប់មក សម្រាប់ឃុំឃាំងៗទាំងឡាយនៅក្នុងអគារ “ក” ធំជាងគេ-- បន្ទប់ឃុំឃាំងនៅអគារ “ខ”, “គ”, និង “ឃ” ហើយតាមធម្មតាគេដាក់អ្នកទោសសំខាន់តែម្នាក់ៗគត់ប៉ុណ្ណោះ ។ អគារ “ខ”, “គ” និង “ឃ” ប្រើធ្វើជាគុកសម្រាប់ជនជាប់ឃុំឃាំងធម្មតារបស់មន្ទីរស-២១ ដែលក្នុងនោះមានបន្ទប់ឃុំឃាំងរួមធំទូលំទូលាយសម្រាប់ដាក់អ្នកទោសជាក្រុមផង និងលាយចម្រុះជាមួយនឹងកូនបន្ទប់សម្រាប់ដាក់អ្នកទោសម្នាក់ៗផង ។

[១០:១៣:៤៥]

មានពេលខ្លះកន្លែងទាំងនោះអាចដាក់អ្នកទោសបានរាប់រយនាក់ផងដែរ ។ ដូចអ្វីដែលយើងបានឃើញនៅមន្ទីរស-២១ ជាអង្គភាពរដ្ឋបាលដែលរួមមាន ព្រៃស និងជើងឯក ហើយនឹងពិនិត្យមើលទីតាំងទាំងនោះ និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីនោះ ។ ប៉ុន្តែ ឥឡូវនេះ យើងសូមទាញអារម្មណ៍របស់លោក លោកស្រី ទៅលើភស្តុតាងដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅទីតាំងកណ្ដាលនៃមន្ទីរស-២១ ។ ឧក្រិដ្ឋកម្មទាំងនោះត្រូវបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានការឃុំឃាំងខុសច្បាប់, អំពើអមនុស្សធម៌, និងការធ្វើទារុណកម្ម, និងការសម្លាប់ ។

អង្គហេតុទាំងនេះគាំទ្រធាតុផ្សំបទល្មើសដែលមិនអាចប្រកែកបាន ។ ជនរងគ្រោះដែលបាននាំមកមន្ទីរស-២១ ត្រូវបានចាប់ដោយកងកម្លាំងខ្មែរក្រហមនិងដឹកតាមរថយន្ត ឬទាក់ទាញឲ្យមកដល់មាត់ទ្វារដោយប្រើល្បិច និងបន្ទាប់មកត្រូវបានចាប់ខ្លួនតែម្តង ។ ប្រព័ន្ធច្បាប់ត្រូវបានលុបបំបាត់ចោល ជនរងគ្រោះមិនត្រូវបានប្រាប់ពីបទចោទ មិនមានឱកាសក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ គ្មាន

មេធាវីតំណាង គ្មានចៅក្រមដើម្បីស្តាប់អំណះអំណាងរបស់ពួកគេទេ ។ រាល់ការចាប់ខ្លួនគឺមិនស្របច្បាប់ ដោយអ្នកទោសទាំងអស់សុទ្ធតែត្រូវឃុំខ្លួនដោយខុសច្បាប់ ។ ដូចដែលជនជាប់ចោទខ្លួនឯងបានទទួលស្គាល់ថា គ្មានផ្លូវណាផ្សេងក្រៅពីសេចក្តីស្លាប់ ។ អ្នកទោសទាំងអស់ដែលបានចូលក្នុងមន្ទីរស-២១ នេះគឺមកពីទូទាំងកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ លោក លោកស្រី នឹងបានឮ *KW*០៩ ដែលជាជនម្នាក់ដែលធ្លាប់ធ្វើជាអ្នកទទួលខុសត្រូវលើការងារយាមកាមនៅក្នុងការដឹកជញ្ជូនអ្នកទោស ទៅមន្ទីរស-២១ និយាយថា ជនរងគ្រោះទាំងអស់មកពីគ្រប់ ទិសទីទាំងអស់ ហើយពួកគេបានរួមបញ្ចូលនូវមនុស្សគ្រប់ទាំងអស់ ចាប់តាំងពីកម្មាភិបាលថ្នាក់ខ្ពស់ចុះរហូតដល់ប្រជាជនសាមញ្ញ ។ នៅពេលដែលអ្នកទោសភាគច្រើនត្រូវបានអង្គភាពរបស់ខ្លួនជាអ្នកធ្វើការចាប់ខ្លួន និងបន្ទាប់មកបញ្ជូនខ្លួនទៅកាន់មន្ទីរស-២១នោះ ពេលខ្លះក៏មានកិច្ចសហប្រតិបត្តិការជាមួយនឹងជនជាប់ចោទផងដែរ ។ បុគ្គលិកមន្ទីរស-២១ ក៏បានចូលរួមយ៉ាងសកម្មនៅក្នុងការចាប់ខ្លួនមនុស្ស ដូចដែលសាក្សី *KW*០៩ បាននិយាយថា មានពេលខ្លះអង្គភាពទាំងនោះបានឲ្យពួកយើងខ្ញុំចុះទៅចាប់ដោយខ្លួនឯងដែរ ដោយដឹកតាមរថយន្តរបស់មន្ទីរស-១២ ។ សម្រាប់គោលដៅជនរងគ្រោះមន្ត្រីថ្នាក់ខ្ពស់ ល្បិចល្បួងលោមត្រូវបានប្រើប្រាស់ដើម្បីឲ្យជនរងគ្រោះមកក្នុងបរិវេណមន្ទីរស-២១ ហើយក៏ត្រូវបានចាប់ខ្លួននៅទីនោះតែម្តង ។ អ្នកទោសទាំងឡាយបានចូលមកមន្ទីរស-២១ ស្ទើរតែរាល់ថ្ងៃ ។ ជាធម្មតាត្រូវបានគេដឹកមកដល់តាមរថយន្តដំបូលបិទជិត អ្នកទោសទាំងអស់នោះត្រូវគេឲ្យចុះពីលើរថយន្ត និងត្រូវគេដាក់ឲ្យនៅតាមផ្ទះដែលស្ថិតនៅខាងក្រៅទីស្នាក់ការឃុំជាបណ្តោះអាសន្នសិន។ បន្ទាប់មកទៀត អ្នកទោសទាំងនោះត្រូវបានគេរុំមុខ ហើយត្រូវគេចងមុខ ហើយត្រូវគេនាំទៅកាន់ទីស្នាក់ការធំ ។ លោក លោកស្រី នឹងបានឮសាក្សី *KW*១០ និងសាក្សី *KW*១១ ដែលជាអតីតឆ្មាំយាមគុកនៅមន្ទីរស-២១ រៀបរាប់ជូនអំពីថា តើអ្នកទោសទាំងឡាយបានមកដល់ទីស្នាក់ការធំ ត្រូវគេរុំមុខនឹងដាក់ខ្នោះដៃតាមបែបដូចម្តេចខ្លះ ? រូបគំនូរនៃការមកដល់មន្ទីរស-២១ លោក វ៉ាន់ ណាត ដែលជាអ្នកគូររូបដ៏ប៉ិនប្រសព្វ និងជាអ្នកដែលបានរួចរស់ជីវិតម្នាក់ពីមន្ទីរស-២១ បានគូររូបឡើងវិញអំពីការមកដល់របស់គាត់នាសម័យនោះ ។ អគារ “ង” គឺជាកន្លែងឈប់ដំបូងគេរបស់ជនរងគ្រោះ ។ នៅទីនេះសាក្សី *KW*០៧ នឹងធ្វើការចុះឈ្មោះចូលក្នុងបញ្ជី និងសួរអំពីឈ្មោះទីកន្លែងកំណើត និងមុខតំណែងរបស់អ្នកទោស ដើម្បីអាចបង្កើត ជាប្រវត្តិរូបសង្ខេបមួយ ។ បន្ទាប់មកអ្នកថតរូបរបស់មន្ទីរស-២១ បានថតរូបអ្នកទោសទាំងនោះ ដែលក្នុងនោះរួមទាំងសាក្សី *KW*១៦ ផង ។ រូបថតនេះក្រោយមកត្រូវបានគេផ្តិតហើយបិទភ្ជាប់ជាមួយនឹងប្រវត្តិរូបសង្ខេបដែលសាក្សី *KW*០៧ និង

*KW* ១៦ នឹងធ្វើការបញ្ជាក់ការពិតក្នុងពេលសវនាការ ។ ការមកដល់របស់អ្នកទោស និងព័ត៌មានលម្អិតរបស់អ្នកទោស ត្រូវចុះក្នុងបញ្ជីអ្នកទោស និងជាបន្តបន្ទាប់មកទៀត ការសម្លាប់នឹងត្រូវបានចុះក្នុងបញ្ជីកម្ទេចដោយល្អិតល្អន់ ។ គ្មានអ្នកណាម្នាក់ដឹងច្បាស់ថា ជនរងគ្រោះប៉ុន្មាននាក់ទេដែលបានឆ្លងកាត់ដំណើរការនេះ ប៉ុន្តែមានរូបថត អ្នកទោសជាង៥០០០ សន្លឹក និងបញ្ជីឈ្មោះ បញ្ជីកម្ទេចអ្នកទោស និងប្រវត្តិរូបជាច្រើនដែលមាននៅសេសសល់នៅឡើយ ។ វិធីនៃដំណើរការនៃការថតរូបអ្នកទោស រូបថតនេះជាឧទាហរណ៍ ។ ប្រវត្តិរូបរបស់ ភា ឆាយ ដែលស្រង់ដោយមន្ទីរស-២១ នេះគឺជាឧទាហរណ៍មួយនៃប្រវត្តិរូបក្នុងចំណោមប្រវត្តិរូបជាច្រើនដែលមានរូបថតមួយភ្ជាប់ជាមួយ។ នេះជាប្រវត្តិរូបរបស់ ភា ឆាយ ហៅ ស្ទូ ។ ក្នុងប្រវត្តិរូបនេះមានព័ត៌មានស្តីពីប្រវត្តិរបស់ ភា ឆាយ ដែលក្នុងនោះរួមមានអំពីទីកន្លែងកំណើត អាយុ និងឈ្មោះឪពុកម្តាយ ។ គាត់បានបញ្ជាក់ថា មុនពេលការចាប់ខ្លួនបានធ្វើការនៅផ្នែកពាណិជ្ជកម្មក្រៅប្រទេស និងថាគាត់ត្រូវគេចាប់ខ្លួននៅក្រសួងពាណិជ្ជកម្មកាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៧ ។ នៅពេលដែលដំណើរការចុះបញ្ជីបានបំពេញរួចរាល់ហើយភ្លាម ឆ្មាំយាមពន្ធនាគារមួយចំនួនបានយកអ្នកទោសចេញពីអគារ “ង” ទៅកាន់មន្ទីរឃុំឃាំងរបស់ពួកគេ ។ KW២១ ជាអតីតឆ្មាំយាមពន្ធនាគារមួយរូបនៅមន្ទីរស-២១ នឹងផ្តល់សក្ខីកម្មថា ពួកអ្នកដែលចូលមកដល់ថ្មីនៅមន្ទីរស-២១ ជាធម្មតាតែងតែត្រូវបានគេដោះខោអាវចេញនៅពេលមកដល់ចំណុចនេះ ។ ប្តីប្រពន្ធទាំងឡាយដែលត្រូវបានគេចាប់ខ្លួនមកទាំងអស់គ្នាតាមធម្មតា គឺត្រូវគេបំបែកចេញពីគ្នា ហើយនិងមិនដែលជួបគ្នាទៀតទេ គឺនៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានឃើញប្រពន្ធរបស់គាត់ជាចុងក្រោយ ។ មកដល់សព្វថ្ងៃនេះអ្វីដែលគាត់នៅសេសសល់គឺរូបថតចម្លងពីរូបថតប្រពន្ធរបស់គាត់នៅមន្ទីរស-២១ ។ កុមារតូចៗជាទូទៅនៅជាមួយម្តាយដើម្បីឲ្យមានការឃុំខ្លួនមានការងាយស្រួលរហូតដល់ពួកគេត្រូវបានសម្លាប់ផងដែរ ។ លេខបន្ទប់ឃុំឃាំងរបស់អ្នកទោសនីមួយៗ ត្រូវបានកត់ដោយ *KW*០៧ ដើម្បីឲ្យពួកអ្នកសួរចម្លើយងាយស្រួលរកឆាប់ឃើញ។ អ្នកទោសណាម្នាក់ត្រូវបញ្ចប់នៅត្រឹមបន្ទប់នោះ គឺវាអាស្រ័យទៅនឹងកត្តាមួយចំនួនដែលរួមមានកត្តាអំពីភេទ សញ្ជាតិ និងសារសំខាន់របស់អ្នកទោស ។

[១០:២១:៥៨]

ជាញឹកញាប់អ្នកទោសភេទស្រីទាំងឡាយតែងតែត្រូវបានគេឃុំនៅជាន់ផ្ទាល់ដីនៃអគារ “គ” ។ អគារ“ក” និងផ្ទះមួយដែលស្ថិតនៅខាងក្រៅទីស្នាក់ការកណ្តាលដែលត្រូវបានគេស្គាល់ថាជាគុកពិសេសសម្រាប់ដាក់ឃុំអ្នកទោសដែលសំខាន់ៗ ។ ជនបរទេសត្រូវបានគេឃុំឃាំងដាច់ដោយឡែកពីជនជាតិ

ខ្មែរ ។ ជាបន្ថែមពីលើនេះ អ្នកទោសទាំងឡាយដែលត្រូវបានគេសួរចម្លើយរួចត្រូវបានគេដាក់ដោយឡែកពីអ្នកទោសដែលកំពុងរង់ចាំការសួរចម្លើយ ។ អ្នកទោសដែលតែងតែត្រូវគេដាក់ក្នុងបន្ទប់ឃុំឃាំងសម្រាប់ម្នាក់ៗ នៅក្នុងពេលដែលរង់ចាំការសួរចម្លើយ ។ នៅពេលដែលការសួរចម្លើយត្រូវបានបំពេញចប់សព្វគ្រប់ ហើយអ្នកទោសត្រូវបានគេបញ្ជូនទៅកាន់មន្ទីរឃុំឃាំងដែលធំជាងគេសម្រាប់ដាក់អ្នកទោសជាក្រុមដើម្បីរង់ចាំការសម្លាប់ ។ ប្រហែលជាអ្វីដែលអាចបញ្ជាក់ច្បាស់អំពីតួនាទីសំខាន់នៃមន្ទីរស-២១ និងស្ថានភាពរបស់វាក្នុងក្របខ័ណ្ឌ មន្ទីរសន្តិសុខទាំងឡាយដែលគេអាចយល់បានគឺតាមរយៈប្រភេទអ្នកទោសដែលគេបញ្ជូនទៅទីនោះ ។ កម្រងបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ រួមបញ្ចូលគ្នានេះ ត្រូវបានបង្កើតឡើងដោយការដាក់លាយបញ្ចូលគ្នានូវបញ្ជីឈ្មោះចំនួនពីរ។ បញ្ជីឈ្មោះទីមួយគឺមានអ្នកទោសចំនួន៩៨០៥នាក់ ដែលត្រូវបានគេសម្លាប់នៅមន្ទីរស-២១ ។ បញ្ជីឈ្មោះទីពីរ គឺមានអ្នកទោស ១១៨៦នាក់ ដែលត្រូវបានគេចាប់ខ្លួននឹងបញ្ជូនទៅកាន់មន្ទីរស-២១ ។ បញ្ជីទាំងពីរនេះ ត្រូវបានរៀបចំចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើបញ្ជីឈ្មោះទាំងនេះហើយ ហើយនិង បញ្ជីប្រហារជីវិតដែលជាច្បាប់ដើម ដែលត្រូវបាននៅក្នុងមន្ទីរស-២១ ។

ការិយាល័យសហព្រះរាជអាជ្ញាបានរួមបញ្ចូលគ្នានូវបញ្ជីទាំងពីរនេះ ហើយបានលុបបំបាត់នូវកន្លែងណាដែលមានឈ្មោះជាន់គ្នា ។ ជាលទ្ធផលនោះគឺ កម្រងបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ ដែលរួមបញ្ចូលគ្នានេះ ដែលមានឈ្មោះអ្នកទោសមន្ទីរស-២១ ចំនួន១២៣៨០នាក់។ បញ្ជីឈ្មោះនេះគឺជាបញ្ជីឈ្មោះដល់ល្អិតល្អន់ជាងគេបំផុតនៃជនរងគ្រោះដោយមន្ទីរស-២១ ក្នុងចំណោមបញ្ជីណាមួយទាំងអស់ដែលធ្លាប់រៀបរាប់ចងក្រងកន្លងមក ហើយដែលជនជាប់ចោទក៏បានទទួលស្គាល់ផងដែរថាជាបញ្ជីនេះមានលក្ខណៈត្រឹមត្រូវជាសារវន្ត ហើយតាមពិតចំនួនជនរងគ្រោះអាចមានច្រើនជាងនេះទៀតផង ។ ការយល់ដឹងរបស់យើងជាច្រើនអំពីសមាសភាពផ្សេងៗ នៃជនជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ គឺទទួលបានមកដោយសារតែការធ្វើវិភាគទៅលើបញ្ជីនេះ ។ តារាងគំនូសបង្ហាញរាងសំប៉ែតបង្ហាញអំពីសមាសភាពអ្នកទោសមន្ទីរស-២១ ។ តាមតារាងគំនូសនេះបង្ហាញថា អ្នកទោសមានចំនួន៧៨ភាគរយ នៃអ្នកទោសស-២១ ទាំងនោះគឺមកពីរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ឬពីអង្គភាពយោធានានា ។

[១០:២៥:២៥]

ចំនួន៤ភាគរយទៀតនៃអ្នកទោសទាំងនេះដែលមានពណ៌ ពណ៌នាថាគឺជាភរិយារបស់កម្មាភិបាល

ទាំងឡាយដែលត្រូវបានគេចាប់ខ្លួន ។ ប្រហែលជា៣ភាគរយទៀតនៃអ្នកទោសទាំងនេះ ត្រូវបានបញ្ជាក់អត្តសញ្ញាណថា គឺជាជនជាតិវៀតណាម ។ ចំនួនដែលសេសសល់ ចំនួន១៥ភាគរយទៀតនៃអ្នកទោសមន្ទីរស-២១ទាំងនោះ គឺមានលាយចំរុះគ្នារវាងប្រជាជនថ្មី អតីតទាហាន មន្ត្រីនានានៃរបបសាធារណរដ្ឋខ្មែរ ប្រជាជន ដែលត្រូវបានពិពណ៌នាថា ជាអណិកជនចិន បញ្ញាជន ជនបរទេសមួយចំនួនតូចមកពីប្រទេសផ្សេងៗ និងមានការចុះបញ្ជីមួយចំនួនដែលទូលំទូលាយពេក ដែលមិនអាចឲ្យកំណត់ពីប្រភេទបាន ។ ព័ត៌មាននៅក្នុងកម្រងបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ រួមបញ្ចូលគ្នាបង្ហាញអ្នកទោសប្រមាណជា៧០ភាគរយ គឺមានភេទប្រុស និងអាយុ ជាមធ្យមនៃអ្នកទោសទាំងនោះគឺ២៩ឆ្នាំ ទោះបីជាអត្រាភាគរយនេះអាចខ្ពស់ ដោយសារតែកុមារទូទៅមិនឃើញមានចុះក្នុងបញ្ជីមន្ទីរស-២១ ទេ ។ ជាមធ្យមអ្នកទោសត្រូវបានគេដាក់ឃុំចំនួន៦១ថ្ងៃមុននឹងត្រូវកម្ទេចចោល ។

ក្នុងកម្រងបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១រួមបញ្ចូលគ្នា ក៏បង្ហាញឲ្យឃើញផងដែរថា មានកម្មាភិបាលមន្ទីរស-២១ ជាច្រើនរូបក្លាយទៅជាអ្នកទោសមន្ទីរស-២១ ។ មានអ្នកទោសនៅក្នុងបញ្ជីតិចណាស់ក៏១៩០នាក់ដែរ ដែលអាចស្គាល់អត្តសញ្ញាណច្បាស់លាស់ថា គឺជាអតីតបុគ្គលិករបស់មន្ទីរស-២១ ។ ដោយដៅទៅលើកម្មាភិបាល និងទាហានរបស់ខ្លួន ដំណើរការចម្បងរបស់មន្ទីរស-២១ គឺច្បាស់ដើម្បីលុបបំបាត់សត្រូវរបស់បក្សដែលស្របទៅនឹងពាក្យស្លោករបស់ខ្មែរក្រហមដែលថា "សត្រូវស៊ីរូងផ្ទៃក្នុង" ។ ខ្មែរក្រហមធានាថា ការប្រឆាំងទាំងអស់ត្រូវលុបបំបាត់ ដោយសម្លាប់ប្រពន្ធ ប្ដី និងកូនរបស់សត្រូវ ។ បញ្ជីនេះក៏ចង្អុលបង្ហាញផងដែរនូវតួនាទីរបស់មន្ទីរស-២១ ក្នុងការវាយប្រហារ ជាលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ ដែលបានកើតឡើងនៅទូទាំងប្រទេសកម្ពុជា ។ គំនូសបង្ហាញអំពីការចុះបញ្ជីនៃមន្ទីរស-២១ អំពីអ្នកទោសពីភូមិភាគបូព៌ា ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៨ ការបោសសម្អាតភូមិភាគបូព៌ាគឺមានឯកសារជាច្រើន ដែលត្រូវបានបញ្ជាដោយថ្នាក់ដឹកនាំខ្មែរក្រហមក្នុងតារាងគំនូសនេះបង្ហាញពីការវិភាគលើតួលេខស្ថិតិតាមខែនៃអ្នកទោសដែលមកពីភូមិភាគបូព៌ា ។ ដូចលោកលោកស្រីចៅក្រមបានឃើញស្រាប់ ហើយចំនួនអ្នកទោសមកពីភូមិភាគបូព៌ាដែលចូលមកមន្ទីរស-២១ មានចំនួនតិចណាស់ ទាល់តែមកដល់ខែមេសា ឆ្នាំ១៩៧៨ ស្រាប់តែកើនឡើងខ្ពស់ភ្លាម ។ មានអ្នកទោសជិត១០០០នាក់ មកពីភូមិភាគបូព៌ា បានចូលមកក្នុងមន្ទីរស-២១ ក្នុងអំឡុងខែមេសា ឧសភា និងមិថុនា ឆ្នាំ១៩៧៨ ។

នេះបញ្ជាក់យ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្តនៅមន្ទីរស-២១ ជាផ្នែក

មួយដ៏សំខាន់នៃការវាយប្រហារ ដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធរបស់បក្សកុម្មុយនីស្ដកម្ពុជាលើប្រជាជនកម្ពុជា ។

[១០:២៩:០៨]

អង្គហេតុដែលច្បាស់មួយទៀតគឺ ទោះបីជារយៈពេលឃុំខ្លួននៅមន្ទីរស-២១ នោះយូរ ឬឆាប់ក៏ដោយអ្នកទោសត្រូវបានទទួលរងនូវលក្ខខណ្ឌនៃការឃុំខ្លួនដ៏អមនុស្សធម៌ ។ ពួកអ្នកទោសត្រូវគេបដិសេធមិនផ្ដល់ឲ្យគ្រប់គ្រាន់នូវម្ហូបអាហារបរិភោគ ទឹកផឹក និងពេទ្យសម្រាប់ផ្ដល់ការថែទាំសុខភាពទេ ។ ហើយជាធម្មតាគឺត្រូវបានគេយកចេញពីមន្ទីរឃុំឃាំងដែលមិនមានអនាម័យ មិនដែលមានមនុស្សច្រើនហួសចំណុះពេក ដើម្បីយកទៅធ្វើទារុណកម្ម និងដើម្បីសម្លាប់តែប៉ុណ្ណោះ ។ អ្នកទោសទាំងឡាយត្រូវបានគេដាក់ខ្នោះជើងទាំងអស់គ្នា នៅក្នុងបន្ទប់ឃុំឃាំងនានាដែលមានលក្ខណៈដ៏តូចចង្អៀតដែលបិទជិតជុំវិញ និងដែលមានមនុស្សច្រើនលើសចំណុះ ។

[១០:៣០:០១]

KW១០ នឹងបង្ហាញសក្ខីកម្មថា ពួកអ្នកទោសនៅក្នុងអគារ “ខ” និង “គ” ដែលត្រូវគេដាក់ខ្នោះជើង និងខ្នោះដៃទាំងអស់គ្នាជាក្រុមៗដែលមានមនុស្សដប់ៗនាក់ដេកទល់ជើងគ្នាពេញបន្ទប់ ។ សាក្សី KW១៥ នឹងផ្ដល់សក្ខីកម្មថា អ្នកទោសបានដេកដោយជើងជាប់ខ្នោះ ដែលមានដែករនុកមួយប្រមាណប្រាំពីរតឹក ដែលមាន-- សូម្បីតែពួកអ្នកទោសដែលត្រូវបានគេធ្វើទារុណកម្មរួចហើយក្ដីក៏គេបដិសេធមិនព្រមឲ្យខ្មើយដើម្បីកើយ ឬកន្ទេលក្រាលដេកដែរ ។

របបអាហារហូបចុកនៅមន្ទីរស-២១ គឺមិនដែលគ្រប់គ្រាន់ទាល់តែសោះ សាក្សី *KW០៩* ដែលធ្លាប់ជាអតីតឆ្មាំយាមគុកមួយរូបនឹងផ្ដល់សក្ខីកម្មថា អ្នកទោសមន្ទីរស-២១ទាំងឡាយ គឺគេឲ្យរបបបបរ រាវហូបពីរដងក្នុងមួយថ្ងៃ ។ ហើយពេលហូបនោះទៀតសោត គឺគេឲ្យអ្នកទោសហូបទាំងជើងជាប់ខ្នោះនៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ។ សាក្សី KW១០ នឹងផ្ដល់សក្ខីកម្មថា ពេលខ្លះអ្នកទោសបានទទួលកាន់តែតិចជាងនេះថែមទៀត របបអាហារបាយ ឬសម្លតែមួយវែកប៉ុណ្ណោះ និងគ្មានសាច់ ឬត្រីទេ ។ ការដកយករបបអាហារហូបចុកដែលមិនបានគ្រប់គ្រាន់ទៅហើយនេះក្ដី ក៏ត្រូវបានគេធ្វើជាការដាក់ទណ្ឌកម្មមួយផ្នែកដែរ ។

[១០:៣១:៣៥]

អ្នកទោសមន្ទីរស-២១ ក៏ត្រូវបានដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពដែលគ្មានអនាម័យផងដែរ ។

សាក្សី KW១៥ ដែលជាអតីតឆ្មាំយាមគុកមួយរូបនៅមន្ទីរស-២១ នោះនឹងផ្តល់សក្ខីកម្មថា អ្នកទោសទាំងឡាយមិនត្រូវបានគេអនុញ្ញាតឲ្យចាកចេញពីបន្ទប់ឃុំឃាំងរបស់ខ្លួន ដើម្បីឲ្យទៅបត់ជើងតូច ឬបត់ជើងធំនោះទេ ។

ផ្ទុយទៅវិញ ពួកអ្នកទោសទាំងអស់ត្រូវបានគេផ្តល់នូវធុង ឬកែសគ្រាប់សម្រាប់ឲ្យពួកគេបន្ទោរបង់លាមក ឬនោមដាក់នៅក្នុងនោះ ។ ដែលគេទុកនៅក្នុងបន្ទប់ឃុំឃាំងនោះ រហូតដល់ពេលមានឆ្មាំគុកផ្នែកខាងអនាម័យមកប្រមូលយកទៅ ។ អ្នកទោសមន្ទីរស-២១ ត្រូវបានគេឃុំឃាំងនិងឲ្យងូតទឹកនៅក្នុងស្ថានភាពអមនុស្សធម៌ដែលមិននឹកស្មានដល់ ។ សាក្សី KW១៥ និង KW២៧ នឹងរំឭកឡើងវិញអំពីអ្នកទោសមន្ទីរស-២១ទាំងឡាយ ដែលមានជះចំហាយក្លិនស្អុយដោយគេមិនអនុញ្ញាតឲ្យងូតទឹក ។ សាក្សីទាំងនោះក៏នឹងរៀបរាប់ផងដែរអំពីថា តើធ្វើដូចម្តេចខ្លះទៅនៅពេល ដែលឆ្មាំគុកចូលមកក្នុងបន្ទប់ឃុំឃាំងនូវរៀងរាល់ប្រាំពីរថ្ងៃទៅដប់ថ្ងៃម្តង? ដែលបញ្ជាឲ្យអ្នកទោសក្នុងនោះស្រាតខោខ្លីចេញ ដែលជាសម្លៀកបំពាក់ដែលមានតែមួយគត់របស់ពួកគេ ។ ហើយក៏ជះទឹកទាំងធុងទៅទាំងធុង ទៅលើពួកគេដែលគេដេកតម្រៀបគ្នាដោយជើងជាប់ខ្នោះ ដែលមានរនុកដែកតភ្ជាប់ពីម្នាក់ទៅម្នាក់ទៀត ។

[១០:៣៣:០៧]

នៅមន្ទីរស-២១ ការព្យាបាលជំងឺមិនមានគ្រប់គ្រាន់ទេ ។ បញ្ហាដំបូង គឺបុគ្គលិកពេទ្យពុំទទួលការបណ្តុះបណ្តាលត្រឹមត្រូវទេ ។ សាក្សី KW២០ គឺជាក្មេងដែលពុំទទួលការបណ្តុះបណ្តាលពីមុខវិជ្ជាពេទ្យនិងមិនចេះអក្សរ ប៉ុន្តែគាត់ជាកុមារពេទ្យតែម្នាក់គត់ដែលនៅរស់ពីមន្ទីរស-២១ ខណៈពេលដែលបុគ្គលិកពេទ្យធំៗត្រូវបានគេចាប់ខ្លួននិងសម្លាប់ ។

បន្ថែមលើការដែលបានទទួលការហ្វឹកហ្វឺនមិនបានល្អ ។ ពួកពេទ្យទាំងនោះមិនមានសម្ភារៈ ឬថ្នាំសង្កូវឲ្យបានត្រឹមត្រូវដើម្បីព្យាបាលអ្នកជាប់ឃុំដែលបានទទួលរងនូវទារុណកម្មទេ ។ នៅក្នុងករណីជាច្រើន ពួកនោះគ្រាន់តែអាចសម្អាតរបួសបានដោយប្រើទឹកអ៊ីដ្សូឌីន ឬទឹកអំបិលតែប៉ុណ្ណោះ ។

នេះនៅមិនទាន់គ្រប់គ្រាន់ទេ ។ ដូចដែល សាក្សី KW២០ នឹងផ្តល់សក្ខីកម្មថា នៅពេលខ្លះអ្នកទោសដែលបានរងទទួលទារុណកម្មមានរបួសនៅពាសពេញខ្នង នៅលើដៃ និងនៅលើដងខ្លួនរបស់ពួកគេ ព្រមទាំងមានរបួសធ្ងន់ធ្ងរនៅលើក្បាល ក្រចកដៃ ក្រចកជើង ត្រូវបានដកថែមទៀតផង ។ ទីបញ្ចប់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ គឺត្រូវបានប្រើសម្រាប់តែរក្សាជីវិតអ្នកជាប់ឃុំឲ្យនៅរស់ទុកសម្រាប់សួរចម្លើយនិងធ្វើទារុណកម្មលើកក្រោយទៀតតែប៉ុណ្ណោះ។

[១០:៣៤:៣៥]

សាក្សី KW១៩ ដែលជាអតីតពេទ្យនៅមន្ទីរស-២១ នឹងផ្តល់សក្ខីកម្មថា គាត់ត្រូវបានទទួលបញ្ជាពិសេសឲ្យធ្វើការព្យាបាលអ្នកទោសសំខាន់ៗបន្ទាប់ពីការសួរចម្លើយ ដើម្បីឲ្យពួកគេនៅមានសុខភាពល្អសម្រាប់សួរចម្លើយម្តងទៀត ។ ច្បាស់ណាស់ថា គ្រប់អ្នកទោសរស់នៅក្នុងបរិយាកាសនៃការភ័យខ្លាចក្នុងការធ្វើទារុណកម្មឬការសម្លាប់ ។ មិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេ ដែលពួកអ្នកទោសព្យាយាមធ្វើការសម្លាប់ដោយខ្លួនឯង ដើម្បីគេចផុតពីលក្ខខណ្ឌអមនុស្សធម៌ទាំងអស់នេះ សាក្សី KW១៥ ដែលជាអតីតអ្នកយាមនៅមន្ទីរស-២១ ពិពណ៌នាអំពីរបៀបដែលពួកអ្នកយាមត្រូវធ្វើនៅពេលចាប់ផ្តើមដំបូងនៃវេនយាមរបស់ខ្លួន ។ ក្នុងការត្រួតពិនិត្យអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំង ដើម្បីប្រយ័ត្នកុំឲ្យអ្នកទោសដាក់ដែលគោល ម្ជុល ឬសម្ភារៈផ្សេងៗដែលអាចប្រើសម្រាប់សម្លាប់ខ្លួនឯងបាន ។

[១០:៣៥:៤៥]

សាក្សី KW១០ ដែលជាអតីតអ្នកយាមនៅមន្ទីរស-២១ នឹងផ្តល់សក្ខីកម្មថា អ្នកទោសខ្លះនៅមន្ទីរស-២១ ធ្វើឃាតកម្មបានសម្រេច ។ ក្នុងចម្លើយជាកសិណរបស់គាត់សាក្សីរូបនេះ នឹងរំឭកឡើងវិញអំពីវិសាលភាពដែលពួកអ្នកទោសនៅសម្លាប់ខ្លួនដោយខ្លួនឯង និងអំពីវិធី ដែលបានប្រើដូចជា៖ ការចាក់ខ្លួនឯងនឹងខ្មៅដៃឬប៊ិច ការចាក់ខ្លួនឯងនឹងអម្បែងកែវ ការដុតខ្លួនឯងនឹងចង្កៀង និងការលោតពីលើអគារគុក ។

ប្រហែលជាការបង្ហាញលក្ខខណ្ឌទាំងអស់នេះអាចជួយឲ្យយើងយល់បាន ។ រូបថតទាំងនេះទំនងជាត្រូវបានថតដោយអ្នកថតរូបម្នាក់នៅមន្ទីរស-២១ នៅពីខាងក្នុងបន្ទប់ឃុំឃាំងរួមមួយ ។ នៅផ្នែកខាងក្រោយ លោក លោកស្រី អាចមើលឃើញអ្នកទោសក្នុងបន្ទប់ឃុំឃាំងដេកជាជួរនៅលើឥដ្ឋ ។ បន្ទប់ឃុំឃាំងរួមនេះជាគំនូរដែលគូរដោយលោក វ៉ាន់ ណាត បង្ហាញអំពីផ្នែកខាងក្នុងនៃបន្ទប់ឃុំឃាំងរួមមួយ ។ បន្ទប់ឃុំឃាំងរួមនៅទីនេះ លោក លោកស្រី អាចមើលឃើញរូបភាពអំពីផ្នែកខាងក្នុងនៃមន្ទីរឃុំឃាំងរួមដូចដែលបានឃើញនៅថ្ងៃនេះ ។

នេះជារូបថតអ្នកទោសម្នាក់នៅមន្ទីរស-២១នេះ ត្រូវបានថតពីខាងក្នុងបន្ទប់ឃុំឃាំងឯកជនមួយដែលនៅក្នុងអគារ “ខ” “គ” ឬ “ឃ” ។ នៅខាងឆ្វេងនិងនៅខាងស្តាំរូបថតនេះ លោក លោកស្រី អាចមើលឃើញជញ្ជាំងឥដ្ឋអត់បូកស៊ីម៉ង់ត៍ ដែលបានសាងសង់អំពីខ័នបន្ទប់ធំៗទៅជាបន្ទប់ឃុំឃាំងតូចៗ ។ គំនូរដែលគូរដោយលោក វ៉ាន់ ណាត ជារូបគំនូរពាក់កណ្តាលខ្លួននៅខាងក្នុងមន្ទីរឃុំឃាំងឯកជនមួយ ។

រូបថតនេះបង្ហាញអំពីបន្ទប់ឃុំឃាំងឯកជនដែលស្ថិតនៅជាប់ពីមួយទៅមួយ ។ វាច្បាស់ណាស់ ទោះបីជារយៈពេលប៉ុន្មានថ្ងៃក៏ដោយ អ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ គឺត្រូវឋិតក្នុងលក្ខខណ្ឌអមនុស្សធម៌គ្រប់នាទីទាំងអស់ ។

ជាបន្តទៀតនេះ ខ្ញុំសូមអនុញ្ញាតឲ្យសហការីរបស់ខ្ញុំខាងផ្នែកអន្តរជាតិនឹងធ្វើការសន្និដ្ឋានសង្ខេបជាបន្ត ។ សូមអរគុណ ។

[១០:៣៨:១០]

**ប្រធានអង្គជំនុំ៖**

ម្ភៃនាទីរហូតដល់ម៉ោងដប់មួយ អញ្ជើញចូលវិញ ។ សូមជម្រាបអ្នកចូលរួមនិងសាធារណជនទាំងអស់អញ្ជើញចូលមកវិញមកកាន់កន្លែងរៀងៗខ្លួនឲ្យបានមុនម៉ោងដប់មួយ ។

សូមសម្រាក ។

*[សវនាការសម្រាកពីម៉ោង ១០៣៩នាទីដល់ម៉ោង ១១:០០នាទី]*

[១១:០៣:០៣]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការសវនាការរបស់យើងបន្តទៀត ហើយជាកិច្ចចាប់ផ្តើមនេះគឺសូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបបន្តពីសហចៅក្រមជាតិ ។

**លោក រ៉ូប៊ឺត ពើទីត៖**

លោកមេធាវី លោកប្រធានជាទីគោរព ដើមបណ្តឹងរដ្ឋប្បវេណី ហើយនឹងប្រជាពលរដ្ឋកម្ពុជាទាំងអស់ជាទីគោរព ។ ថ្ងៃនេះខ្ញុំឈរទីនេះ ដោយមានសេចក្តីអំណរគុណ ដោយមានកិត្តិយសបានជួយលោក លោកស្រីចៅក្រម ដើម្បីនាំមកនូវយុត្តិធម៌ជូនជនរងគ្រោះរាប់ពាន់នាក់នៅស-២១ ។ ខ្ញុំគ្មានសង្ស័យអ្វីទេ ដែលយើងទាំងអស់នៅទីនេះ យើងបានដឹងអំពីសារសំខាន់នៃការជំនុំជម្រះនេះ ហើយ

នឹងអានុភាពនៃសាលក្រមដែលនឹងត្រូវចេញ ។ ដូចដែលសហសេវិកខ្ញុំបានសន្យា យើងជាសហព្រះរាជអាជ្ញានឹងជួយលោក លោកស្រីចៅក្រម ដើម្បីឲ្យស្វែងរកយុត្តិធម៌អស់ពីសមត្ថភាពរបស់យើងខ្ញុំ ។

ស្របតាមការប្តេជ្ញានេះ និងដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះ ខ្ញុំសូមបន្តលើកឡើងនូវបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅស-២១ និងជាពិសេសអ្វីដែលពិតជាមានការពាក់ព័ន្ធទៅនឹងស-២១ នោះ គឺទារុណកម្មទៅលើជនរងគ្រោះ ដើម្បីទាញយកចម្លើយសារភាព ។ ដូចដែលជនជាប់ចោទបានសារភាពខ្លួនឯង គឺថានឹងមានភស្តុតាងជាច្រើនដែលគាំទ្រ គឺថាការទារុណកម្មបានធ្វើឡើងយ៉ាងទូលំទូលាយនៅស-២១ ។ ហើយតាមការបញ្ជាក់ផ្ទាល់របស់ជនជាប់ចោទ ជួនកាលដោយដៃគាត់ផ្ទាល់ អ្នកជាប់ឃុំឃាំងត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការឈឺចាប់ ឬក៏ទុក្ខសោកយ៉ាងខ្លាំងលើរាងកាយ និងផ្លូវចិត្ត ដើម្បីស្រង់យកសម្លើយសារភាព ជួនកាលក្នុងរូបភាពជាទណ្ឌកម្ម ។ ភស្តុតាងទាំងនេះ គឺច្បាស់លាស់ ហើយមិនអាចបដិសេធបាន ។ ជាឧទាហរណ៍ សាក្សី KW០៤ ដើមបណ្តឹងរដ្ឋប្បវេណី គាត់ជាមនុស្សតែម្នាក់ក្នុងចំណោមមនុស្សមួយចំនួនតូចដែលរួចរស់ជីវិតនៅក្នុងស-២១ ។ គាត់ជាមនុស្សក្នុងចំណោមជនមួយចំនួន ដែលអាចផ្តល់បញ្ជាក់ពីហេតុការណ៍ដែលកើតឡើងនៅក្នុងស-២១ ។ គេបានវាយគាត់ ដោយរំពាត់ខ្សែតី ឆក់ខ្សែភ្លើង ឆក់រហូតទាល់តែគាត់បានសារភាព ។

[១១:០៦:០០]

ជនរងគ្រោះត្រូវបានវាយដំ ដោយរំពាត់ផ្តៅ រំពាត់ខ្សែតី ឆក់ខ្សែភ្លើង ដកក្រចកដៃ ក្រចកជើង យកថង់ផ្លាស្ទិកមកគ្របក្បាល ដើម្បីបង្ខំឲ្យឆ្លើយ និងសម្រាតខោអាវចេញ ហើយយកខ្សែភ្លើងឆក់ប្រដាប់ភេទជនរងគ្រោះ ។ អ្នកសួរចម្លើយនៅស-២១ មិនមែនជាអ្នកសម្រេចវិធីធ្វើទារុណកម្មដ៏ឃោរឃៅនេះនោះទេ ប៉ុន្តែជនជាប់ចោទបានបង្រៀនវិធីធ្វើទារុណកម្មនោះ ។ ដូចដែលបញ្ជាក់ជាលម្អិតក្នុងសេចក្តីថ្លែងការណ៍របស់គាត់ ជនជាប់ចោទបានប្រាប់អ្នកសួរចម្លើយឲ្យធ្វើទារុណកម្មអ្នកទោស ដោយវាយនឹងដំបង ឆក់ខ្សែភ្លើង ច្រកថង់ផ្លាស្ទិក បន្តក់ទឹកលើថ្ងាស បន្ទាប់មកយកកន្សែងពោះគោគ្របមុខ ។ ជនជាប់ចោទបានបញ្ជាក់ថា គេចូលចិត្តប្រើទារុណកម្មវាយនឹងដំបងច្រើនជាងគេ ពីព្រោះវិធីផ្សេងទៀតធ្វើឲ្យខាតពេល ។

សាក្សី KW១០ ជាអតីតអ្នកយាមនៅ ស-២១ នឹងផ្តល់សក្ខីកម្មថា ជនជាប់ចោទបានបង្រៀនវិធីនេះ និងបញ្ជាក់ថាគេប្រាប់អ្នកឲ្យសួរចម្លើយធ្វើយ៉ាងណាដែលចាំបាច់ដើម្បីទទួលបានចម្លើយ ។ ភស្តុតាងដែលបន្សល់ទុកដោយជនជាប់ចោទ ឬអ្នកក្រោមបង្គាប់របស់គាត់នៅស-២១ បញ្ជាក់ច្បាស់អំពីហេតុ-

ការណ៍នេះ ។ ដូចលោក លោកស្រីចៅក្រមបានជ្រាបហើយ គឺថាសំណុំរឿងមានឯកសារជាង១២០ ដែលបានបង្កើតឡើងដោយ ស-២១ ហើយនិងមានចំណារផ្ទាល់ដៃរបស់ជនជាប់ចោទក្នុងសម័យនោះ ។ ចំណារទាំងនេះមានរហូតចាប់ពីចំណារ ដែលមានកាលបរិច្ឆេទដំបូងនៅចម្លើយសារភាពរបស់ អ៊ុំ សឺន នៅថ្ងៃទី០១ កញ្ញា ឆ្នាំ១៩៧៥ រហូតចំណារចុងក្រោយចុះថ្ងៃទី២១ ធ្នូ ១៩៧៨ លើចម្លើយសារភាពរបស់ គឹម សុខ ។ ខ្ញុំសូមជម្រាបថា ចំណារទាំងនោះផ្តល់ផ្លូវឆ្ពោះទៅរកការពិត អំពីបញ្ហាសំខាន់បំផុតក្នុងរឿងក្តី ។ ជាឧទាហរណ៍ ចំណារផ្ទាល់ដៃរបស់ជនជាប់ចោទ ទីមួយ គឺឧទាហរណ៍ឯកសាររបស់ ដាញ់ ស៊ីយ៉ាន ជនជាប់ចោទបានណែនាំឲ្យអ្នកសួរចម្លើយថា វាយរហូតដល់នាងឈប់និយាយថា "នាងទៅប្រទេសវៀតណាមដើម្បីព្យាបាលជំងឺ" ។ ចំណារផ្ទាល់ដៃរបស់ជនជាប់ចោទ ក្នុងឧទាហរណ៍ដូចជាការសួរចម្លើយរបស់ យ៉ា ដែលជាអតីតលេខាភូមិភាគឦសាន និងសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការមជ្ឈិមបក្ស ។ ចំពោះចំណារផ្ទាល់ដៃរបស់ ឌុច ។បានប្រាប់ ប៉ុន ថា គាត់ប្រើវិធានការក្តៅប្រឆាំង យ៉ា ។ វិធីក្តៅមានន័យថា ទារុណកម្ម ហើយធ្វើជ្រុលដល់ស្លាប់ក៏មិនខុសនឹងអង្គការវិន័យដែរ តាមពិត ឌុច កំពុងប្រាប់ ប៉ុន ឲ្យធ្វើទារុណកម្ម យ៉ា រហូតដល់ស្លាប់ ។ ជនជាប់ចោទទទួលស្គាល់ថា គាត់បានសរសេរឯកសារណែនាំការធ្វើទារុណកម្ម តែគាត់បានអះអាងថា ក្នុងករណីជាច្រើនគាត់គ្រាន់តែសរសេរដាក់ ចម្លងតាមសេចក្តីសម្រេចរបស់ថ្នាក់លើរបស់គាត់ ដែលគាត់ហៅឲ្យ ។

[១១:០៩:២៥]

យើងខ្ញុំសូមបញ្ជាក់ថា ការអះអាងមិនអាចទទួលយកបានទេ គ្មានភស្តុតាងគាំទ្រ មិនអាចជឿបានទេ ។ ខ្ញុំនឹងនិយាយបន្ថែមអំពី-- បន្តិចអំពីការពិនិត្យមើលអំពីបញ្ហាអ្វីជនរងគ្រោះណាជាប់ចោទពេញចិត្តសួរចម្លើយគាត់បានស្រង់ ហើយខ្ញុំបានបញ្ជាក់ថា អ្វីដែលជនជាប់ចោទបញ្ជាក់នោះ គឺត្រូវតែស្លាប់ ។ ជនជាប់ចោទបានទទួលស្គាល់ថា ជួនកាលគាត់បានទុកអ្នកទោសម្នាក់ជាបណ្តោះអាសន្នរហូតដល់ទាល់តែសម្រេចយកទៅកម្ទេច ។ ជនជាប់ចោទបានទទួលស្គាល់ថា ជួនកាលគាត់បានរក្សាទុកជាបណ្តោះអាសន្នអ្នកទោសដែលមានជំនាញ ប៉ុន្តែនៅទីបំផុត នឹងត្រូវយកទៅសម្លាប់ដដែល ។ យើងនឹងបានស្តាប់សក្ខីកម្ម សាក្សីរបស់អតីតអ្នកយាមស-២១ សាក្សី KW១១ និងដូចដែលជនជាប់ចោទបានទទួលស្គាល់ខ្លួនឯង ចាប់ពីថ្ងៃទី១ ដែលមន្ទីរនេះឃុំខ្លួនជនរងគ្រោះទីមួយ ដែលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺគ្មាននរណាម្នាក់អាចចេញពី ស-២១ ដែលរស់បានទេ ។

ស-២១ បានរក្សាទុកឯកសារយ៉ាងប្រុងប្រយ័ត្នដូចគ្នានឹងបុព្វជនសម័យហាយនភាពដែរ ។

ឯកសារទាំងនោះរួមទាំងឯកសាររបស់អ្នកដែលត្រូវបានសម្លាប់ផងដែរ ។ បញ្ជីប្រហារជីវិតលេខប្រាំ យើងសូមអរគុណចំពោះប្រវត្តិសាស្ត្រ ប៉ុន្តែយុត្តិធម៌ផងដែរ ដែលបានបន្សល់ទុកនៅឯកសារទាំងអស់នេះ ដែលយើងទាំងអស់គ្នាមានមួយចំនួននៅក្នុងសំណុំរឿង ។

នៅក្នុង *ស្លាយ* ដែលលោក លោកចៅក្រម បានឃើញនេះ គឺឯកសារកំណត់ត្រាពីបីទំព័រក្នុងចំណោមកំណត់ត្រារាប់រយសន្លឹកក្នុងបញ្ជីប្រហារជីវិត ដែលរៀបរាប់ឡើងដោយស-២១ ។ រាល់បន្ទាត់នីមួយៗតំណាងឲ្យជនរងគ្រោះម្នាក់ដែលត្រូវបានសម្លាប់ ។ ដំបូងឡើយគេសម្លាប់អ្នកទោសភាគច្រើននៅក្នុងជុំវិញបរិវេណ ស-២១ តាមការពិពណ៌នារបស់អ្នក-- ហើយគេបានសម្លាប់ឲ្យទម្លាក់ចូលក្នុងរណ្តៅរួចវះពោះ ។

សាក្សី KW១០ អតីតអ្នកសួរចម្លើយ ស-២១ នឹងផ្តល់សក្ខីកម្មអំពីវិធីសម្លាប់បែបត្រជាក់ គឺការបូមឈាមអ្នកទោស ។ គេបានចងអ្នកទោសភ្ជាប់ទៅនឹងគ្រែ ចាក់ម្ជុលចូលភ្ជាប់ទៅនឹងដបមួយ ទុកឲ្យជីវិតរបស់គេហូរចេញពីខ្លួនបន្តិចម្តងៗ ។ យោងតាមសម្តីរបស់សាក្សីមានអ្នកទោសរាប់ពាន់អ្នកត្រូវបានសម្លាប់តាមវិធីនេះ ទោះបីជាគាត់អះអាងថា គាត់មិនបានដឹងអំពីវិធីនេះក៏ដោយ ជនជាប់ចោទមិនបានបដិសេធថា រឿងនេះមិនបានកើតឡើងនោះទេ ។ លោក លោកស្រីចៅក្រមជាអ្នកកំណត់អំពីការអះអាងនេះ ។ នៅដើមឆ្នាំ១៩៧៧ ដោយមានការភ័យខ្លាចអំពីជំងឺឆ្លង ដោយសារមានសាកសពច្រើន ដែលកប់នៅជុំវិញបរិវេណធំ ជនជាប់ចោទបានសម្រេចថា គាត់ត្រូវការកន្លែងសម្លាប់ និងកន្លែងកប់ថ្មី ។ ចាប់ពីពេលនោះមកជនរងគ្រោះភាគច្រើន ត្រូវបានយកចេញពីស-២១ ទៅកាន់កន្លែងមួយហៅថា ជើងឯក ។ ទោះជាយ៉ាងណាក៏ដោយ រហូតទាល់តែក្រោយពេលការសម្លាប់ភាគច្រើនត្រូវបានផ្ទេរទៅ ជើងឯក ជនជាប់ឃុំមួយចំនួនរួមទាំងជនបរទេស និងកម្មាភិបាលសំខាន់ៗត្រូវបានសម្លាប់នៅក្នុងនិងបរិវេណជុំវិញកន្លែងធំដដែល ។ ស-២១ អ្នកជាប់ឃុំឃាំងនៅលើគ្រែ តាមពិតការសម្លាប់បន្តកើតមាននៅបរិវេណធំរហូតដល់ចុងក្រោយនៃស-២១ ។

កន្លែងដែលយើងហៅថា “ជើងឯក” ថ្ងៃនេះគឺសំដៅដល់កន្លែងមួយដែលស្ថិតនៅប្រហែលជា ៧ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ស្ថិតនៅតំបន់ជិតភូមិមួយដែលឈ្មោះជើងឯកដូចគ្នា ។ មុនឆ្នាំ១៩៧៧ ផ្នែកមួយនៅកន្លែងនោះត្រូវបានប្រើជាកន្លែងកប់ខ្មោចចិន ។ ផ្នូរចិនទាំងនោះនៅអាចមើលឃើញរហូតដល់សព្វថ្ងៃនេះ ។ ទោះជាយ៉ាងណាក្តីចាប់ពីឆ្នាំ១៩៧៧ មកវាបានក្លាយជាវាលពិឃាតចម្បងសម្រាប់ជនរងគ្រោះមកពី ស-២១ ក្នុងរយៈពីរឆ្នាំកន្លងខាងមុខ អ្នកទោសប្រហែលរាប់ពាន់ នឹងត្រូវបាននាំចេញពី ស-

២១ ឃុំខ្លួនចងមុខដាក់ខ្នោះដៃរួចដឹកឡានទៅជើងឯក ។ ជួនកាលគេយកចេញរៀងរាល់ថ្ងៃ ធម្មតាគេយកទៅនៅពេលយប់ មធ្យាបាយដឹកជញ្ជូនបាននាំគេទៅជើងឯក និងកាន់សេចក្តីសម្លាប់ ។ ដូចដែលអ្នកយាមបញ្ជាក់ នៅពេលទៅដល់ទីនោះអ្នកទោសស្គម សល់តែស្បែកដណ្តប់ឆ្អឹង ខ្នងកោង ចងមុខហើយត្រូវបានអូសចេញពីឡានចូលផ្ទះឈើមួយ ។ អតីតអ្នកយាមជើងឯកនិងពេជ្ឈឃាដសាក្សីKW២៤ នឹងបញ្ជាក់ប្រាប់ថា ចេញពីផ្ទះក្នុងរាត្រីមរណៈអ្នកទោសម្តងមួយៗ បាននាំទៅកាន់រណ្តៅដោយពន្លឺចង្កៀងប្រេងកាត គេបានបញ្ជាឲ្យអង្គុយ លុតជង្គង់ ហើយវាយដំបងពីក្រោយ ហើយក៏បានធាក់ទម្លាក់ក្នុងរណ្តៅ ហើយនិងដោះខ្នោះចេញនៅពេលដែលអ្នកនោះស្លាប់ហើយ ។

រណ្តៅសពរួម នៅក្នុងការគាស់រណ្តៅដែលបានធ្វើឡើងក្នុងឆ្នាំ១៩៨០ នោះនៅជើងឯកគេបានប្រទះឃើញអដ្ឋិធាតុរាប់ពាន់ ។ អដ្ឋិធាតុមួយចំនួននៅសល់រហូតដល់សព្វថ្ងៃនេះ ដែលថាមានរណ្តៅតម្រៀបគ្នាដែលយើងអាចឃើញរហូតដល់សព្វថ្ងៃនេះ ។ រូបភាពដើមឈើមួយដើមដែលមានផ្លាកថាជាកន្លែងសម្លាប់កុមារ ឈើនេះឈរនៅទីនោះរហូតដល់សព្វថ្ងៃ ។ តាមកំណត់ត្រា និងរូបដ៏គួរឲ្យរន្ធត់ផ្សេងទៀត រូបភាពស-២១ បង្ហាញអំពីជនរងគ្រោះមួយចំនួនជាកុមារ សូម្បីតែទារកក៏មានដែរ ។ ពួកគេទាំងនោះប្រឈមមុខនឹងជោគវាសនាអាក្រក់ដូចឪពុកម្តាយរបស់គេដែរ ។

ទោះជាយ៉ាងណាក្តី ការស៊ើបអង្កេតមិនបានកំណត់របៀបដែលពួកគេបានប្រឆាំង ពិនិត្យឃើញទាំងស្រុងទេ ។ សាក្សីបានបញ្ជាក់ថា កុមារបានត្រូវគេសម្លាប់ សាក្សីម្នាក់បានបញ្ជាក់ថា ករណីមួយដែលគា ាត់បានឃើញគេទម្លាក់កុមារចេញជាន់ខាងលើនៃអគារនៅស-២១ ។ ប៉ុន្តែគ្មាននរណាម្នាក់បានផ្តល់សេចក្តីលម្អិតចំពោះបុគ្គលនោះទេ ។ ជនជាប់ចោទបានបដិសេធថាមិនមានការសម្លាប់កុមារ ហើយ តាមពិតសញ្ញាពិតប្រាកដលើដើមឈើនេះមិនបានផ្តល់ព័ត៌មានអ្វីថែមទៀតទេ ។

ខ្ញុំសូមគោរពស្នើលោក លោកស្រីចៅក្រមថា ផ្តល់កិត្តិយសដល់វិញ្ញាណក្ខន្ធកុមារទាំងនេះតាមរយៈការសំណូមឲ្យបានសមស្របដើម្បីរិះរកវិធីដែលគេសម្លាប់ជនរងគ្រោះ ជាជនស្លូតត្រង់ទាំងនេះ ។ ដោយប្រឈមនឹងភស្តុតាងដ៏លើសលប់អំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំបែបនេះ ហើយបានប្រព្រឹត្តក្នុងរយៈពេលដ៏យូរមកហើយនោះ និងក្នុងទម្រង់ជាប្រព័ន្ធ យើងប្រហែលជាមិនអាចដឹងពីចំនួនរងគ្រោះពិតប្រាកដ ត្រូវបានសម្លាប់នៅស-២១ ក្រោមអំណាចរបស់ជនជាប់ចោទនោះទេ ។

លោក លោកស្រីចៅក្រមជាទីគោរព! ដូចដែលបានពិភាក្សា ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋនៅស-២៤ ដែលហៅថាជា ព្រៃស ។ ព្រៃស គឺជាកន្លែងលត់ដំ ដែលស្ថិតនៅក្រោម ស-២១ ហើយរាយការណ៍ផ្ទាល់ទៅឲ្យជនជាប់ចោទ ។ ស-២១ មានមូលដ្ឋាននៅម្តុំអតីតគុកសម័យអាណានិគម ដែលមានឈ្មោះថា ព្រៃស ឬ នឹងគ្របដណ្តប់លើតំបន់ធំមួយរួមទាំងការដ្ឋាន និងភូមិភាគនៅជិតនោះ ។ ពីដំបូងកន្លែងនោះគ្រប់គ្រងដោយ ហ៊ុយ ស្រែ ជា កម្មាភិបាលជាន់ខ្ពស់ទីបីក្នុងឋានានុក្រម ស-២១ នៅក្រោម ឌុច និង ហ៊រ ។ នៅពេលដែល ហ៊ុយ ស្រែ ត្រូវបានចាប់ខ្លួនបញ្ជូនមក ស-២១ ក្នុងចុងឆ្នាំ១៩៧៨ ផល ដែលធ្លាប់ទទួលបន្ទុកអង្គភាពអ្នកយាមនៅស-២១ បានឡើងតំណែងជំនួស ។ ស-២៤ ជាកន្លែងលត់ដំកម្មាភិបាល កម្មករ និងយុទ្ធជនដែលមានកំហុស ឬត្រូវបានសង្ស័យថាជាខ្មាំង ។ គេបែងចែកអ្នកទាំងនោះទៅជាបីប្រភេទ អ្នកនៅក្នុងប្រភេទទី១ ត្រូវទទួលរងលក្ខខណ្ឌអាក្រក់បំផុត ការលត់ដំរាប់បញ្ចូលទាំងការឃុំខ្លួនដោយខុសច្បាប់ ការងារដោយ បង្ខំ អាហារមិនគ្រប់គ្រាន់ និងថ្នាំពេទ្យមិនគ្រប់គ្រាន់ ការអប់រំនយោបាយនិងអំពើឃោរឃៅ ។ ការងារដោយបង្ខំរួមមានការធ្វើប្រឡាយ ធ្វើស្រែចម្ការ ឃ្វាលគោក្របី ការងារសាងសង់ទំនប់ដែល ភាគច្រើនធ្វើដោយដៃមិនមានឧបករណ៍គ្រប់គ្រាន់ឡើយ ។ ការងារចាប់ផ្តើមពីព្រលឹមស្រាងៗ និងឈប់សម្រាកនៅពេលព្រលប់ អ្នកដែលមិនខំប្រឹងប្រែងធ្វើការត្រូវបានគេវាយរំពាត់ ឬដំបង ។ មនុស្សរាប់ពាន់នាក់ត្រូវបានឃុំខ្លួននៅតាមការដ្ឋាននានាក្នុង ស-២១ នៅពេលណាមួយ ហើយគ្រប់ៗគ្នា សុទ្ធតែទទួលរងការងារដោយបង្ខំ ។ អ្នកទោសដែលមិនអាចលត់ដំបានត្រូវបានសម្លាប់ចោល ឡានដឹកពួកគេនៅពេលយប់ ហើយដឹកពួកគេទៅស-២១ ហើយនិងដើងឯង ។ អ្នកទាំងនោះមិនមានអ្នកណាត្រឡប់មកវិញឡើយ ។

បញ្ជីអ្នកទោសរួមនៅ ស-២១ ចង្អុលបង្ហាញថា មានអ្នកទោសជាង៥០០នាក់ រួមទាំងអ្នកទោសដែលកំពុងលត់ដំ ឬបុគ្គលិក ស-២៤ ត្រូវបានបញ្ជូនមកស-២១ ដើម្បីសួរចម្លើយ និងសម្លាប់ចោល ។

[១១:១៩:៥០]

ដូចបញ្ជាក់ក្នុងឯកសារនេះ ក្នុងចំណោមអ្នកដែលត្រូវបានសម្លាប់ទាំងនោះ រួមទាំងកុមារផងដែរ ការបាត់មនុស្សជាបន្តបន្ទាប់បានបង្កើតនូវបរិយាកាសភ័យរន្ធត់ដែលគម្រាមដល់អាយុជីវិតរបស់គេជារៀងរាល់ថ្ងៃនៅស-២៤ ។ បន្ថែមលើឋានៈ ជាអ្នកបញ្ជានៅស-២៤ ដោយសារមុខតំណែងរបស់ខ្លួនជាប្រធាន ស-២១ ជនជាប់ចោទបានសារភាពថា គាត់ទៅស-២៤ ម្តងម្កាល ប៉ុន្តែ បដិសេធថាគាត់

ឯកសារដើម

មិនបានឃើញលក្ខខណ្ឌលំបាកទាំងនោះទេ ។ ដែលថាជនជាប់ចោទមានអំណាច ហើយគាត់បានទទួលស្គាល់សារភាពនៅអំពីនោះ ។

លោកប្រធាន, លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមដាក់ជូនដោយគោរពថា លោក លោកស្រីចៅក្រមនឹងឃើញមានភស្តុតាងនៅក្នុងសំណុំរឿង ដែលអាចយើងជឿជាក់ហួសពីវិសមតិសង្ស័យថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះពិតជាបានប្រព្រឹត្តឡើង។

ជាការពិតណាស់ នៅក្នុងអំឡុងពេលស៊ើបអង្កេត ជនជាប់ចោទខ្លួនឯងភាគច្រើនបានទទួលស្គាល់ថាឧក្រិដ្ឋកម្មទាំងអស់នោះបានកើតឡើងមែន ។ ក្នុងអំឡុងពេលស៊ើបអង្កេត និងតាមរយៈសេចក្តីប្រកាសរបស់មេធាវីការពារក្តី ជនជាប់ចោទក៏បានអះអាងដែរថា គាត់ទទួលស្គាល់ការទទួលត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មទាំងអស់នោះ ។ ប៉ុន្តែ ការទទួលស្គាល់អំពីការទទួលខុសត្រូវដូចដែលបានបង្ហាញ និងតវ៉ាដោយជនជាប់ចោទ និងមេធាវីការពារក្តីមានភស្តុតាងគាំទ្រត្រឹមត្រូវត្រឹមកម្រិតណា ?

ខ្ញុំសូមសន្និដ្ឋានថា ចំណុចនេះអាចជាបញ្ហាចម្រូងចម្រាស់មួយដែលត្រូវសម្រេចដោយសាលក្រម របស់លោក លោកស្រីចៅក្រម ។ ចំណុចនេះអាចបញ្ហាដ៏ចម្រូងចម្រាស់មួយមែន ប៉ុន្តែវាមិនអាចជាបញ្ហាដ៏ពិបាកបំផុតនោះទេ ។ ជនជាប់ចោទបានប្រឹងប្រែងរៀបរាប់អំពីអំណាចរបស់គាត់ថា អំណាចនេះមានលក្ខណៈកម្រិតនិងមានតែឈ្មោះ ។ អំពីការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មនានា គ្រាន់ជាការបង្គ្រប់កិច្ច ហើយជាសំខាន់ គឺដើម្បីបញ្ជូនបញ្ហាទាំងឡាយបន្ត ហើយអំពីការប្តេជ្ញារបស់គាត់ចំពោះគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជានិងស-២១ ដែលមានលក្ខណៈស្ទាក់ស្ទើរ និងធ្វើឡើងក្រោមការបង្ខិតបង្ខំ ។ ប៉ុន្តែ យើងខ្ញុំសូមសន្និដ្ឋានថា ភស្តុតាងទាំងអស់ដែលត្រូវពិនិត្យ មើល និងបង្ហាញហួសពីវិមតិសង្ស័យថា ជនជាប់ចោទមានអំណាចឯករាជ្យនៅក្នុងការគ្រប់គ្រងស-២១ ជនជាប់ចោទបានប្រើអំណាចនោះដោយចេតនា និងយ៉ាងសកម្ម នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នោះ ហើយជនជាប់ចោទបានបំពេញការងារទាំងនេះរហូតដល់ស-២១ បញ្ចប់គោលដៅនិងទទួលជោគជ័យ។

ដោយមានការអនុញ្ញាតពីលោក លោកស្រីចៅក្រម នាពេលនេះ ខ្ញុំនឹងរៀបរាប់ភស្តុតាងទាំងនោះដោយចាប់ផ្តើមពីរចនាសម្ព័ន្ធរបស់ស-២១ ។ ដ្យាក្រាមនេះ គឺបង្ហាញនូវរចនាសម្ព័ន្ធចាត់តាំងរបស់ស-២១ ចាប់តាំងពីខែមីនា ឆ្នាំ១៩៧៦ នៅពេលដែលជនជាប់ចោទក្លាយជាប្រធានស-២១ រហូតដល់ពេលចាប់ខ្លួន ហ៊ុយ ស្រែ នៅចុងឆ្នាំ១៩៧៨ ។ ដ្យាក្រាមនេះបានផ្អែកលើភស្តុតាងនៅក្នុងសំណុំរឿង ហើយបានរៀបរាប់នៅក្នុងកថាខណ្ឌទី៥៩ ដល់ ៧៨ នៅក្នុងដីកាសន្និដ្ឋានស្ពាពររបស់សហព្រះរាជ

អាជ្ញា។ មានចំណុចពីរ ដែលខ្ញុំចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញចាប់អារម្មណ៍ ចំណុចទី១ ជនជាប់ចោទរាយការណ៍ផ្ទាល់ជូនគណៈអចិន្ត្រៃយ៍អំពីការងារទាំងអស់ដែលពាក់ព័ន្ធនឹងការឃុំខ្លួន ការសួរចម្លើយ និងការសម្លាប់អ្នកទោសនៅ ស-២១ ។

ពីដំបូង ជនជាប់ចោទរាយការណ៍ជូនសមាជិក គណអចិន្ត្រៃយ៍ សុន សេន ប៉ុន្តែនៅក្នុងខែសីហា ឆ្នាំ១៩៧៧ ជនជាប់ចោទបានចាប់ផ្តើមរាយការណ៍ជូន នួន ជា ដែលជាសមាជិកគណអចិន្ត្រៃយ៍មួយរូបផ្សេងទៀត ។ តាមរយៈការសារភាពរបស់គាត់ ជនជាប់ចោទរាយការណ៍ដូច្នេះ រហូតដល់ស-២១ ដួលរលំ ។ ចំណុចទី២ មានអង្គភាពធំៗចំនួនបី នៅ ស-២១ អង្គភាពការពារ អង្គភាពសួរចម្លើយ និង ស-២៤ អង្គភាពនីមួយៗរាយការណ៍ផ្ទាល់ជូនជនជាប់ចោទ ហើយបុគ្គលិកក្រោមបង្គាប់របស់ជនជាប់នៅគ្រប់អង្គភាពទាំងអស់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដូចដែលបានរៀបរាប់ ។ ដ្យាក្រាមនេះ ដោយមានការកែប្រែមានគូសពណ៌លឿងបង្ហាញថា មានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះក្រោយពីចាប់ ហ៊ុយ ស្រែ ដែលជាប្រធា ស-២៤ ។ មានបុគ្គល៣រូប បានប្តូរមុខតំណែង ប៉ុន្តែរចនាសម្ព័ន្ធទាំងមូលត្រូវបានរក្សាទុកឲ្យនៅដដែល ។ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់នោះ គឺបុគ្គលគ្រប់រូបនៅតែបន្តរាយការណ៍ជូនជនជាប់ចោទដដែល ។

[១១:២៤:៣០]

ដ្យាក្រាមទាំងនេះផ្អែកជាចំបងលើចម្លើយរបស់អតីតបុគ្គលិកស-២១ ហើយប្រហែលវាគ្មានអ្វីគួរឲ្យយើងភ្ញាក់ផ្អើលឡើយ ។ ដ្យាក្រាមទាំងនេះ ខុសពីតារាងរចនាសម្ព័ន្ធចាត់តាំងនានាដែលជនជាប់ចោទបានដាក់ចូលជាភស្តុតាងនៅក្នុងអំឡុងពេលស៊ើបអង្កេត ។ ដ្យាក្រាម ឧទាហរណ៍នៅក្នុងតារាងមួយនេះដែល ឌុច បានរៀបចំវាហាក់ដូចជាបង្ហាញថាជនជាប់ចោទទទួលខុសត្រូវលើ ស-២៤ លើវគ្គនយោបាយ វគ្គរៀនសូត្រនយោបាយប្រចាំឆ្នាំ និងការលើការទទួលចម្លើយសារភាពពីអង្គភាពសួរចម្លើយតែប៉ុណ្ណោះ ។ ការទទួលខុសត្រូវទាំងអស់ផ្សេងទៀត និងការស្តីបន្ទោសនានាបានទម្លាក់លើ ហ៊ិរ ដែលជាបុគ្គលិកក្រោមបង្គាប់របស់ជនជាប់ចោទ ។ ហើយដែលជនជាប់ចោទបានដឹងច្បាស់ថា ហ៊ិរ បានស្លាប់បាត់ជាយូរមកហើយ ។

នៅអំឡុងពេលស៊ើបអង្កេតជនជាប់ចោទមិនបានបដិសេធថា អ្វីដែលគាត់បានរៀបរាប់បានបង្ហាញហួសពីតួនាទីជាប្រធានក្នុងទ្រឹស្តី ហើយជាក់ស្តែងជនជាប់ចោទបានបន្តលើកឡើងថា ជនជាប់ចោទមិនបានក្តាប់ព័ត៍មានអ្វីជាក់ស្តែងឡើយនៅក្នុងជីវិតការងាររបស់គាត់ ។ យោងតាមជនជាប់ចោទ

សេចក្តីសម្រេចថាអ្នកណាខ្លះដែលត្រូវយកទៅសម្លាប់ ត្រូវបានចោទថា សុន សេន ឬ នួន ជា ជាអ្នកសម្រេច ហើយសេចក្តីសម្រេចទាំងនោះឆ្លងតាមរយៈការិយាល័យរបស់ខ្លួនតែប៉ុណ្ណោះ ។

[១១:២៥:៤៧]

ហើយចំពោះសេចក្តីសម្រេចប្រចាំថ្ងៃអំពីដំណើរការ ស-២១ តាមការប្រមើលមើល ឬបុគ្គលិកក្រោមបង្គាប់របស់គាត់ជាអ្នកសម្រេច ។ ជនជាប់ចោទបានអះអាងថា ខ្លួនគ្មានអ្វី ធ្វើអ្វីក្រៅពីអានចម្លើយសារភាពនៅក្នុងការិយាល័យរបស់ខ្លួនពេញមួយថ្ងៃ នៅពេលឧក្រិដ្ឋកម្មទាំងឡាយបានប្រព្រឹត្តជុំវិញខ្លួន ។

យើងខ្ញុំសូមសន្និដ្ឋានថា ការអះអាងរបស់ជនជាប់ចោទពុំមានភស្តុតាងគាំទ្រឡើយ ហើយនៅក្នុងអំឡុងពេលស៊ើបអង្កេត នៅពេលដែលមានភស្តុតាងផ្ទុយ ជនជាប់ចោទត្រូវតែទទួលស្គាល់អំពីអំណាចពិតប្រាកដរបស់ខ្លួន ប៉ុន្តែ ដូចដែលយើងខ្ញុំបានបញ្ជាក់ការទទួលស្គាល់នេះនៅខ្វះការពិតនៅឡើយ ។ សូមលោក លោកស្រីចៅក្រម ធ្វើការចាប់អារម្មណ៍លើភស្តុតាងមួយចំនួនដែលអាចជួយ បង្ហាញការពិតវាប្រាកដណាស់ភស្តុតាងមួយចំនួនលេចចេញពីជនសមគំនិតរបស់ជនជាប់ចោទ ។ មនុស្សជំនិតដ៏ទុកចិត្តម្នាក់របស់ជនជាប់ចោទនៅម-១៣ និង ស-២១ គឺសាក្សី KW0៨ និងចូលមក ផ្តល់ចម្លើយថាជនជាប់ចោទបានចាត់ចែងអង្គភាពសន្តិសុខទាំងមូល ហើយជនជាប់ចោទបានដឹងគ្រប់ការងារ ហើយបានចេញគ្រប់សេចក្តីសម្រេចនៅស-២១ ។ អ្នកសួរចម្លើយនឹងមកផ្តល់ចម្លើយថា ជនជាប់ចោទបានបង្រៀនពួកគេអំពីទ្រឹស្តី និងការអនុវត្តបច្ចេកទេសធ្វើទារុណកម្ម ដែលរួមមាន បង្គាប់ពួកគេឲ្យសួរសំណួរបែបណា ហើយប្រើបច្ចេកទេសបែបណានៅក្នុងស្ថានភាពជាក់លាក់មួយចំនួន ។

សាក្សីនានានឹងផ្តល់ចម្លើយថា ជនជាប់ចោទបានបញ្ជាឲ្យធ្វើទារុណកម្មអ្នកទោស ហើយលទ្ធផលនៃការសួរចម្លើយត្រូវបញ្ជូនឲ្យជនជាប់ចោទពិនិត្យមើលភ្លាមៗ ។ ជនជាប់ចោទនឹងបង្គាប់ឲ្យសួរចម្លើយ និងធ្វើទារុណកម្មបន្ថែមប្រសិនខ្លួនមិនពេញចិត្ត ឬនឹងបង្គាប់ឲ្យសម្លាប់អ្នកទោសប្រសិនបើមិនចាំបាច់សួរចម្លើយ ឬធ្វើទារុណកម្មបន្ថែម ។

ការអះអាងថា បុគ្គលិកក្រោមបង្គាប់ជាអ្នកដំណើរការស-២១ និងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយតាមចិត្តចង់របស់ពួកគេ គឺផ្ទុយនឹងភស្តុតាង និងផ្ទុយនឹងលក្ខណៈជាក់ស្តែង ។ សូមលោក លោកស្រីចៅក្រមពិចារណាត្រង់នេះ បុគ្គលនៅទីនេះប្រហែលអាចដឹងច្រើនជាងបុគ្គលដទៃទៀតនៅក្នុងប្រទេសនេះថា កំហុសតូចមួយតែប៉ុណ្ណោះ ឬការខ្ជិលធ្វើការ តាមការមើលឃើញជាក់ស្តែង ឬតាមការសន្និដ្ឋាន

អាចឆក់យកសង្ខាររបស់អ្នក ឬសង្ខាររបស់អ្នក អ្នកដែលស្គាល់អ្នក ។ បុគ្គលនៅទីនេះ ដដែលខ្លួនឯងនឹងទទួលយកភារកិច្ចពីរបបនេះ ក្នុងគោលបំណងដើម្បីធានាមិនឲ្យរបបនេះទទួលការគំរាមកំហែងភាគច្រើនពីសត្រូវទាំងឡាយ ។ ហើយបុគ្គលនេះបានបំពេញការងារទាំងអស់នេះជាច្រើនឆ្នាំ ។ ឥឡូវនេះ បុគ្គលនេះដដែលបានសុំឲ្យលោក លោកស្រីចៅក្រមជឿគាត់ថា គាត់បានលះបង់ការទទួលខុសត្រូវទាំងនោះ ហើយបណ្តោយឲ្យវាសនារបស់គាត់ និងគ្រួសារគាត់ស្ថិតនៅក្នុងកណ្តាប់ដៃរបស់បុគ្គលិកក្រោមបង្គាប់របស់គាត់ ។

ខ្ញុំសូមសន្និដ្ឋានថា ចំណុចនេះមិនគួរឲ្យយើងជឿឡើយ ។ វាមិនគួរឲ្យយើងជឿបានទេដែលថា រាល់សេចក្តីសម្រេច រាល់ការបញ្ជា នៅពីក្រោយ រាល់ចំណារមរណៈ ជនជាប់ចោទកំពុងនិយាយទូរស័ព្ទ ឬសន្ទនាជាមួយថ្នាក់លើដើម្បីទទួលយកសេចក្តីណែនាំមកបំពេញភារកិច្ចលើគ្រប់ករណីទាំងអស់ ។

មានអ្នកទោសរាប់ពាន់នាក់ដែលរងទារុណកម្ម រងការសួរចម្លើយ និងរងការសម្លាប់ចោលក្នុងអំឡុងពេលជាងបីឆ្នាំ ហើយចំពោះគ្រប់សេចក្តីសម្រេចទាំងអស់ ជនជាប់ចោទចង់ឲ្យយើងជឿថា មានតែកម្មាភិបាលសំខាន់តែពីររូបប៉ុណ្ណោះ គឺ សុន សេន ដែលជារដ្ឋមន្ត្រីការពារជាតិ និង នួន ជា ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាបានចំណាយពេលយ៉ាងច្រើនឥតគណនាចាត់ចែងក្នុងទ្រង់ទ្រាយលើមន្ទីរស-២១ ហើយកម្មាភិបាលទាំងពីរនេះ បានធ្វើអ្វីទាំងអស់នោះ ។ ទន្ទឹមនឹងការព្យាយាមបង្កើតការគ្រប់គ្រងប្រទេសនេះ ការព្យាយាមផ្លាស់ប្តូររចនាសម្ព័ន្ធទាំងអស់របស់ស-២១ ហើយនិងការព្យាយាមធ្វើសង្គ្រាម ជាមួយសត្រូវដ៏ខ្លាំងក្លា និងដ៏ភ័យខ្លាច ។

ប៉ុន្តែ ខ្ញុំសូមលើកឡើងថា ចំណុចនេះមិនគួរឲ្យជឿនោះទេ ។ ជាការពិតណាស់គឺថាការអំណាចឯករាជ្យរបស់ជនជាប់ចោទពុំអាចបដិសេធថាពុំមាននោះទេ ។ ការវិភាគលើបញ្ជីអ្នកទោសរួមបង្ហាញថា ចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ យ៉ាងហោចណាស់មានសមាជិកស-២១ ចំនួន១៩១នាក់ ត្រូវបានគេសម្លាប់ចោល ។

ខ្ញុំជឿថាបុគ្គលមួយចំនួនគាត់ងោកពេលធ្វើការ ហើយថាតើជនជាប់ចោទចាំបាច់ត្រូវការអំណាចថ្នាក់លើបំផុតនៅក្នុងប្រទេសនេះដើម្បីអាចចាប់ខ្លួន និងសម្លាប់ចោលដែរឬទេ?

វាបង្ហាញយ៉ាងច្បាស់ថា គឺជនជាប់ចោទមានអំណាចនៅលើស-២១ ហើយគាត់មិនអាចបដិ-សេធថាពុំបានប្រើប្រាស់អំណាចនោះទេ ។ ជាការពិតទៅតើគេឲ្យគាត់ធ្វើអ្វីខ្លះ នៅពេលគេឲ្យគាត់ទទួលខុសត្រូវលើដំណើរការមន្ទីរដ៏សំខាន់មួយដូចស-២១? ផ្ទុកពីការអះអាងរបស់មេធាវីការពារក្តីថា

មន្ទីរសន្តិសុខទាំងឡាយរបស់កម្ពុជាប្រជាធិបតេយ្យពុំមានចាត់ថ្នាក់ជាក់លាក់ ។ ភស្តុតាងបានបញ្ជាក់ថាពុំមានមន្ទីរណាសំខាន់ជាងមន្ទីរ ស-២១ សម្រាប់របបនេះឡើយ ។

សាក្សីមួយរូបនឹងមកផ្តល់ចម្លើយថា សុន សេន ខ្លួនឯងទទួលស្គាល់ករណីនេះ នៅពេលគាត់ថ្លែងសុន្ទរកថាក្នុងពេលប្រជុំមួយដែលជនជាប់ចោទបានចូលរួមដោយលើកឡើងថា ស-២១គឺជាព្រលឹងជាតិដ៏សំខាន់មួយ ។ យើងពុំមានឃើញភស្តុតាងណាមួយនៅក្នុងសំណុំរឿង ឬពុំឃើញក្រុមមេធាវីការពារក្តីចង្អុលបង្ហាញភស្តុតាងណាមួយដល់សហចៅក្រមស៊ើបអង្កេតបញ្ជាក់ថា មន្ទីរសន្តិសុខមួយផ្សេងទទួលការយកចិត្តទុកដាក់ខ្លាំងជាងពីគណៈមជ្ឈិម ។ មន្ទីរសន្តិសុខមួយផ្សេងដើរតួសំខាន់ក្នុងការកម្ទេចកម្មាភិបាលជាន់ខ្ពស់បំផុតរបបនេះ ជាងមន្ទីរនេះ ហើយមន្ទីរសន្តិសុខមួយផ្សេងទៀតមានប្រធានដែលអាចទាក់ទងជាមួយជួរដឹកនាំរបស់ប្រទេសនេះ ដូចមន្ទីរសន្តិសុខរបស់ជនជាប់ចោទ ។

តាមរយៈតួនាទីរបស់ខ្លួន ជនជាប់ចោទអាចទាក់ទងផ្ទាល់ជាមួយមេដឹកនាំជាន់ខ្ពស់បំផុតរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ដោយមានកម្មាភិបាលតិចតួចប៉ុណ្ណោះទទួលបានបុព្វសិទ្ធិបែបនេះ ។ ជនជាប់ចោទគឺជាកម្មាភិបាល ស-២១ តែម្នាក់គត់ដែលមានសិទ្ធិទាក់ទងរាយការណ៍ជូនគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាពីដំបូងតាមរយៈរដ្ឋមន្ត្រីការពារជាតិ និងក្រោយមកតាមរយៈបងទីពីរ គឺ នួន ជា ។

តើអាចឲ្យយើងជឿតាមរយៈការតវ៉ាថា ជនជាប់ចោទពុំទទួលខុសត្រូវលើមន្ទីរសន្តិសុខដ៏សំខាន់បំផុតមួយរបស់កម្ពុជាប្រជាធិបតេយ្យយ៉ាងដូចម្តេច? ខ្ញុំសូមសន្និដ្ឋានថា វាមិនអាចទៅរួចឡើយ ។

[១១:៣២:៥២]

ដោយសារជានជាប់ចោទបានយកចិត្តទុកដាក់ខ្លាំងលើដំណើរការស-២១របស់ខ្លួន យើងខ្ញុំមានយើងមានភស្តុតាងបង្ហាញថា គាត់បានដើរតួនាទីសំខាន់មួយនៅក្នុងដំណើរការសន្តិសុខជាតិ ។ សាក្សី KW២៥ ជានីរសាររបស់ក្រសួងការបរទេសនឹងផ្តល់ចម្លើយថា ជនជាប់ចោទបានចូលរួមនៅទីស្តីការក្រសួង ដោយមានមេដឹកនាំដទៃទៀតជួបប្រជុំគ្នា ។ មានឯកសារជាច្រើនបានបង្ហាញឲ្យឃើញ ។ តុលាការនឹងស្តាប់ចម្លើយរបស់អ្នកជំនាញប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទរវល់នឹងវិភាគចម្លើយសារភាព ដើម្បីទាញយកព័ត៌មានពីអ្នកទោសក្នុងបុព្វហេតុការពាររបបនេះ និងផ្តល់ព័ត៌មានសំខាន់ដល់មេដឹកនាំជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យ ហើយជនជាប់ចោទធ្វើការងារនេះអស់រយៈពេលច្រើនឆ្នាំ ។

យើងគ្មានអ្វីឆ្ងល់ឡើយនៅពេលដែលមានបោកគ្រាប់បែកនៅកណ្តាលក្រុងភ្នំពេញ ឬនៅពេលមានការបាចត្រាក់នៅក្នុងក្រុង ក្នុងគោលបំណងគំរាមកំហែងដល់អំណាចរបស់អង្គការ ។ មេដឹកនាំទាំងឡាយបានកោះហៅជនជាប់ចោទឲ្យជួយរែកមុខពិរុទ្ធជន ។ ដោយសារតួនាទីនេះ និងការជឿជាក់បែបនេះ ទើបជនជាប់ចោទបានដឹងច្បាស់អំពីគោលនយោបាយដ៏ឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយឧក្រិដ្ឋចំពោះការវាយប្រហារលើប្រជាជនកម្ពុជា ។ តាមរយៈការគ្រប់គ្រង ឬពេលខ្លះតាមរយៈការប្រព្រឹត្តិ ការសួរចម្លើយ និងចម្លើយសារភាពពិស្តាររបស់ជនរងគ្រោះរាប់ពាន់នាក់ រាប់តាំងពីជួរកម្មាភិបាលថ្នាក់ក្រោមរហូតដល់សមាជិកគណៈមជ្ឈិម និងតាមរយៈការទាក់ទងជាមួយកម្មាភិបាលជាន់ខ្ពស់ទាំងឡាយនៅក្នុងប្រទេសនេះ ។ ជនជាប់ចោទប្រហែលបានដឹងច្បាស់ជាងអ្នកផ្សេងនៅក្នុងប្រទេសណា តើមានប្រទេសនេះ តើមានអ្វីខ្លះនៅលើប្រជាជនកម្ពុជា?

ទោះបីជាគោលនយោបាយទូទៅរបស់កម្ពុជាប្រជាធិបតេយ្យ ដែលថា កម្មាភិបាលដឹងតែអំពីការងារនិងភារកិច្ចរបស់ខ្លួនក៏ដោយ យើងដឹងច្បាស់ថា ជនជាប់ចោទបានដឹងពេញលេញថាឧក្រិដ្ឋកម្មរបស់មន្ទីរនេះ គឺការវាយប្រហារក្នុងទ្រង់ទ្រាយធំ និងក្នុងលក្ខណៈស៊ីសង្វាក់លើប្រជាជនស៊ីវិល ហើយជនជាប់ចោទបានអនុវត្តអំណាចរបស់ខ្លួនក្នុងការឈានដល់ការវាយប្រហារបែបនេះ ។

លោកប្រធាន លោក លោកស្រីចៅក្រម ក្នុងឋានៈអ្នកមានអំណាចខ្ពស់បំផុតនៅក្នុងមន្ទីរសន្តិសុខដ៏សំខាន់បំផុតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ តើជនជាប់ចោទប្រើអំណាចនោះដូចម្តេច? តើគាត់ចូលរួមដូចម្តេចខ្លះនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនៅស-២១? បញ្ហានោះក៏មានជម្រុងចម្រាស ហើយនិងមានការ ដោយមានការអនុញ្ញាតពីលោក លោកស្រីចៅក្រម ខ្ញុំនឹងគូសបញ្ជាក់ដោយសង្ខេបអំពីបញ្ហាដែលយល់ថាជាមុខតំណែងពាក់ព័ន្ធ និងទាញយកការពិនិត្យភស្តុតាងមួយចំនួនដែលអាចមានប្រយោជន៍ដល់ការវាយតម្លៃរបស់លោក លោកស្រីចៅក្រម ។

[១១:៣៥:៥៧]

តាមការបញ្ជាក់របស់គាត់ក្នុងបទសម្ភាសន៍មុខតំណែងរបស់ជនជាប់ចោទ គឺគ្រាន់តែជាអ្នកសម្រួលក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ។ អនុលោមតាមសម្តីរបស់គាត់ផ្ទាល់ តួនាទីរបស់គាត់ភាគច្រើនបំផុតគឺគ្រាន់ មានកម្រិតត្រឹមតែអនុវត្តនយោបាយ និងសម្រេច អនុវត្តសេចក្តីសម្រេចរបស់អង្គភាពប៉ុណ្ណោះ ។ អង្គការបានសម្រេចថា ត្រូវចាប់ខ្លួនអ្នកណា ការសួរចម្លើយ និងទារុណកម្មអ្នកទោស គឺជាការទទួលខុសត្រូវរបស់អ្នកក្រោយបង្គាប់របស់គាត់ ហើយអង្គការបានពេញចិត្តថា ជនរងគ្រោះបាន

ប្រាប់ពីពាក្យចុងក្រោយដែលជាប្រយោជន៍គ្រប់គ្រាន់រួចហើយ ។ ជនជាប់ចោទគ្រាន់តែបញ្ជូនសេចក្តីសម្រេចដើម្បីសម្លាប់ជនរងគ្រោះនោះ ។

អនុលោមតាមសម្តីរបស់គាត់ ការទទួលខុសត្រូវស្ថិតនៅក្នុងការរាយការណ៍របស់គាត់ទៅថ្នាក់លើរបស់គាត់ ហើយបានផ្សព្វផ្សាយបទបញ្ជាទៅថ្នាក់នោះជាពិសេសជាសេចក្តីអធិប្បាយយ៉ាងល្អនៃការទទួលខុសត្រូវស្របច្បាប់របស់អ្នកដែលជាអ្នកជួយ និងអ្នកជំរុញបទល្មើស ។ ហើយជាពិសេសទៅទៀតបង្កនូវលក្ខខណ្ឌអមនុស្សធម៌ជាច្រើននៅស-២១ ។ ការបញ្ជាទាក់ទងទៅនឹងប្រឆាំងទៅលើជនជាប់ឃុំឃាំងនោះ សាក្សីនោះក៏បានបង្ហាញថា ជនជាប់ចោទបានបញ្ជា ហើយបានធ្វើផែនការក្នុងការចាប់ខ្លួនជនមួយចំនួនដែលទាក់ទងទៅនឹង-- ហើយក៏បញ្ជាបុគ្គលិកឲ្យទៅខេត្តដើម្បីចាប់មនុស្ស ។

ជនជាប់ចោទ គឺថាមើល-- ទទួលស្គាល់ទៅលើភស្តុតាងថា អ្នកក្រោមបង្គាប់របស់ខ្លួន ហើយរៀបចំដើម្បីរៀបចំមនុស្សចេញពីអង្គភាពយោធាមួយជាស្រេច ។ នៅទីបំផុតនៅក្នុងកាលៈទេសៈមួយចំនួននោះ ជនជាប់ចោទបានចាប់ខ្លួនមនុស្សដោយផ្ទាល់ដៃដែលបានគ្រោងទុកនោះ ។

ទារុណកម្ម ហើយនិងអំពើផ្សេងៗដើម្បីស្រង់យកចម្លើយសារភាពនៅស-២១ ជនជាប់ចោទហើយបានទទួលបញ្ជាថា ត្រូវធ្វើទុក្ខបុកម្នេញ ហើយនិងឈានដល់ការសម្លាប់ ។ នៅពេលដែលមានសេចក្តីសម្រេចដើម្បីធ្វើការចាប់ខ្លួនទទួលបានទៅថ្នាក់លើ សេចក្តីសម្រេចនោះគឺថាគឺធ្វើឡើងតាមសំណើរបស់ជនជាប់ចោទ ដើម្បីធ្វើការចាប់ខ្លួន ។ គឺថាមានភស្តុតាងដ៏ល្អចំពោះបញ្ជាក់ពីបញ្ហានេះ ជនរងគ្រោះដែលគាត់បានស្នើឡើងគឺត្រូវតែបានចាប់ខ្លួន ។

[១១:៣៨:៥៧]

ជាពិសេសនោះ តាមការយល់ដឹងរបស់គាត់ ដែលជាបទពិសោធន៍នៅ ម១៣ នោះ ជនជាប់ចោទគឺបានបង្កើតនូវលក្ខខណ្ឌអមនុស្សធម៌ និងការរស់នៅអមនុស្សធម៌នៅស-២១ នូវសាក្សី KW១១ នឹងបញ្ជាក់ថា ការឃុំខ្លួនគាត់បានផ្តល់ការណែនាំពីលក្ខខណ្ឌឃុំខ្លួន ហើយជនជាប់ចោទបានឃើញមនុស្សដែលស្គមស្គាំងអំពើទារុណកម្ម ហើយរស់នៅក្នុងស្ថានភាពដ៏អាក្រក់បំផុត ។ ហើយមិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា គាត់បានដោះស្រាយបញ្ហាហ្នឹងឲ្យបានធូរស្រាលនោះទេ ។ គឺថាមានការតាមដាន ហើយនិងការពិនិត្យមើល គឺថាយន្តការទាំងអស់ដែលបង្កើតឡើងនៅស-២១ ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង ហើយគាត់ពិតជាបានសួរសម្លើយជនរងគ្រោះដោយខ្លួនឯងផងដែរ ។

ដូចដែលអ្នកសួរចម្លើយពីស-២១ នឹងបញ្ជាក់នៅពេលនេះ គឺថាការបញ្ជានោះឲ្យប្រើការសួរចម្លើយ ឬទារុណកម្មនោះ ជួនកាលធ្វើជាលាយលក្ខណ៍អក្សរ ជួនកាលដោយផ្ទាល់មាត់អំពីរបៀបប្រើទារុណកម្ម ។ ជនជាប់ចោទបានទទួលស្គាល់ថា ហើយគាត់បានសួរចម្លើយផ្ទាល់ទៅលើអ្នកទោសសំខាន់ៗមួយចំនួនឯកសារភស្តុតាងមួយចំនួនបញ្ជាក់អំពីការចូលរួមរបស់គាត់ក្នុងនីតិវិធីនោះ ។

ជនជាប់ចោទបានទទួលស្គាល់ថា ពេលដែលគាត់បានតទល់ជាមួយភស្តុតាង គាត់បានចូលរួមក្នុងការសួរចម្លើយ ប៉ុន្តែគាត់បានបដិសេធថាមិនបានប្រើទារុណកម្មនោះទេ គឺថាគ្រាន់តែបានទះកំភ្លៀងអ្នកទោសតែប៉ុណ្ណោះ ប៉ុន្តែសាក្សីនោះបាននិយាយថា ជនជាប់ចោទបានទាក់អ្នកទោស ហើយនិងវាយនឹងដំបង ហើយក៏បានឆក់ខ្សែភ្លើងទៅលើអ្នកទោសរហូតទាល់តែសន្លប់ ។ អតីតកម្មាភិបាលស-២១ KW១៥ និងផ្តល់សក្ខីកម្មថា គាត់បានឃើញថា ជនជាប់ចោទបាននិយាយថា ខ្លួនមិនពេញចិត្តអំពើរបស់អ្នកសួរចម្លើយក្នុងការធ្វើទារុណកម្ម ។ អ្នកសួរចម្លើយនេះ គឺថាក្រោយមកត្រូវបានគេចាប់ខ្លួន ហើយសម្លាប់នៅស-២១ ។ នេះជាឧទាហរណ៍គំរូមួយ ។

ទៅនៅបំផុតសាក្សីនឹងបង្ហាញថាជនជាប់ចោទ គឺថាយើង គាត់មានធ្វើចំណារផ្ទាល់ដៃនៅលើឯកសារជាច្រើនដែលដាក់ថា “កម្ទេច” ។

ដោយមានការអនុញ្ញាតទាំងនេះ អ្នកយាម ហើយនិងនាំយកនូវអ្នកទោសដាក់លើឡាន ហើយពិនិត្យមើលអត្តសញ្ញាណ ហើយបញ្ជូនទៅវាលមរណៈនៅជើងឯក ។ នេះសាក្សីបើមានកំហុស ឬក៏មានការកុហកនោះ គឺថាជនជាប់ចោទ គឺជាមេ ។

ដូច្នេះហើយលោក លោកស្រីចៅក្រមជាអ្នកវិនិច្ឆ័យលើកត្តានេះ ។ ដូច្នេះ ដូចដែលយើងបានឃើញហើយ ជនជាប់ចោទនៅរស់ ហើយត្រូវតែលោក លោកស្រីចៅក្រមធ្វើនូវសេចក្តីសម្រេចសាលក្រមនៅក្នុងរបាយការណ៍មួយដែលចែងថា ជនជាប់ចោទបានដឹងអំពីការបន្ទុះគ្រាប់បែកមួយ នេះជាហេតុការណ៍មួយ ។

សូមអភ័យទោសលោក រ៉ូបឺត ពើទីត នេះក្នុងករណីចម្លើយសារភាព ប៊ុន ណារ៉ាក់ ហើយនិងគឺមានការវិភាគនៅលើចម្លើយសារភាពដែលគាត់បានស្នើឲ្យចាប់ ឈឹម សំអួន ។ ហើយគាត់បានផ្តល់អនុសាសន៍ឲ្យស៊ើបអង្កេតលើបុគ្គលបីនាក់ទៀត ដែលថានៅក្នុងអាចនឹងស៊ើបអង្កេតដើម្បីរកមនុស្សផ្សេងទៀតដែលជាប់ពាក់ព័ន្ធទៅនឹង ជន សំអឿន នោះ ។

នេះហើយជាសេចក្តីសារភាពរបស់ សំអឿន ដែលថាបានផ្តល់ចំណារផ្ទាល់ដៃមួយនៅកន្លែងនេះ នៅក្នុងឯកសារនៅស-២១ ។ ឌុច បានទទួលស្គាល់ថា គាត់បានសរសេរថា មិនទាន់សារភាពទេ ត្រូវធ្វើទារុណកម្ម ។ នៅក្នុងចម្លើយសារភាពនេះ ឯកសារនេះក៏បានបង្ហាញថា ជនចោទបានស្នើទៅអង្គការថា ១៥០នាក់នៃជនជាប់ចោទត្រូវកម្ទេច ហើយអង្គការត្រូវបានឯកភាព ។

ជនជាប់ចោទទទួលស្គាល់ថា ត្រូវសួរបួននាក់ សម្លាប់អ្នកផ្សេងទៀតទាំងអស់ ។ នៅក្នុងចំណុចនេះគឺថាជនជាប់ចោទទទួលស្គាល់ថា ខ្លួនបានសរសេរ ពូ ប៉េង សម្លាប់ទាំងអស់នេះ សម្លាប់ឲ្យហ្មត់ ។ នេះហើយគឺជាចម្លើយសារភាពរបស់ គឹម សុខ នៅថ្ងៃទី២១ ខែ១២ ឆ្នាំ១៩៧១ ដែលទទួលបានមកពីស-២១ នៅក្នុងសំណុំរឿង ។ ជនជាប់ចោទបានសរសេរចំណារ និយាយសុំ អនុញ្ញាតឲ្យខ្ញុំចាប់ខ្លួនជនម្នាក់នោះ ។

១៥ថ្ងៃមុនពេលដែលដួលរបបនេះ លោក លោកស្រីចៅក្រមបានឃើញហើយ លោកចៅក្រមគិតថាសុំដោយស្របច្បាប់សូមចាប់ខ្លួនជនរងគ្រោះម្នាក់មួយទៀត ។ ហើយនៅក្នុងកិត្តិយសកិត្តិសព្ទរបស់យើង គឺថាជនជាប់ចោទបានធ្វើអំពើដូចមានពន្យល់នៅក្នុងចំណារផ្ទាល់ដៃរបស់គាត់ ដែលគាត់និយាយថា ពូ ប៉េង សម្លាប់ឲ្យហ្មត់ គាត់ផ្តល់ឱកាសឲ្យ ប៉េង នូវដើម្បីជំរុញការងាររបស់ខ្លួនក្នុងភារកិច្ចអ្នកក្រោមបង្គាប់នោះ ។

[១១:៤៩:៥១]

ចំពោះអ្នកផ្សេងទៀងដូចដែលយើងបានបញ្ជាក់នោះ គឺថាជនជាប់ចោទបានអះអាងថា អ្វីដែលគាត់ធ្វើឡើងត្រូវបានជាសេចក្តីសម្រេចដែលត្រូវសរសេរតាមថ្នាក់លើបង្គាប់ឲ្យ ។ ដូច្នេះហើយ លោក លោកស្រីចៅក្រមត្រូវពិនិត្យសេចក្តីពន្យល់ ដោយពិនិត្យលើភស្តុតាង ហើយនិងកំណត់ត្រានៅក្នុងសំណុំរឿង ។

យើងបានជឿជាក់ថា នៅពេលដែលលោក លោកស្រីចៅក្រមបានពិនិត្យភស្តុតាង ដែលទាក់ទងទៅនឹងសក្ខីកម្មរបស់សាក្សី ហើយនិងការសារភាពរបស់ជនជាប់ចោទ កាលៈទេសៈនៃប្រតិបត្តិការនៃស-២១ ហើយនឹងឯកសារនានា ។ លោក លោកស្រីចៅក្រមនឹងសន្និដ្ឋានជនជាប់ចោទ បានអនុវត្តដោយដឹងខ្លួន ដោយមានចេតនា ហើយលើការត្រួតពិនិត្យលើរចនាសម្ព័ន្ធម៉ាស៊ីនឧក្រិដ្ឋនៃស-២១ ហើយគាត់មានអំណាចចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ ។ ហើយតាមពិត គាត់បានប្រើសិទ្ធិ និងអំណាចទាំងនោះក្នុងរយៈពេលពេញមួយអាណត្តិដែលគាត់ធ្វើជាប្រធានស-២១ ។ ហើយយើង

នឹងជឿថា ផ្អែកលើអង្គហេតុ និងភស្តុតាង គឺវាហួសពីវិមតិសង្ស័យ ហើយយើងអាចនឹងកំណត់ថា តើអ្វីជាការទទួលខុសត្រូវស្របច្បាប់ ដែលថាគាំទ្រដោយអង្គហេតុនោះ ។ នៅក្នុងដីកាដំណោះស្រាយ ដូចបាន លោកចៅក្រមបានជ្រាបហើយ នៅក្នុងការដឹកនាំស-២១នោះ គាត់ទទួលការចោទប្រកាន់ថាបានប្រព្រឹត្ត ហើយទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តិនៅស-២១ ដែលជាការទទួលខុសត្រូវជាបុគ្គល នៅក្នុងការគាត់ជម្រុញ ញុះញង់ ហើយជួយសម្រួលក្នុងការប្រពឹត្តបទល្មើស ហើយនិងខកខានមិនបានទប់ស្កាត់ ឬក៏ដាក់ទណ្ឌកម្មបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅស-២១ ។

នៅក្នុងសេចក្ដីដីកាសន្និដ្ឋាននោះ ដីកាដំណោះស្រាយបានបញ្ជាក់ថា ពីព្រោះភស្តុតាងបានបង្ហាញថា ជនជាប់ចោទបានអំណាចទទួលនូវលទ្ធផលឧក្រិដ្ឋ ដែលគាត់បានចង់បាន ហើយបានចូលរួមយ៉ាងសំខាន់គ្រប់ដំណាក់កាលទាំងអស់នៃម៉ាស៊ីនឧក្រិដ្ឋស-២១ ហើយយើងក៏មានជឿជាក់ថា ទម្រង់នៃការទទួលខុសត្រូវដែរ គឺថាជាផ្នែកមួយនៃបទឧក្រិដ្ឋរបស់ជនជាប់ចោទ ហើយជាផ្នែកមួយ ជាប្រតិបត្តិការរបស់ស-២១ ។ ដូចដែលយើងបានបញ្ជាក់ពីខាងដើមនៃដំណើរការនេះ យើងជំរុញឲ្យ តុលាការនេះពិចារណា ហើយនឹងអនុវត្តនូវទ្រឹស្ដីថាការ-- ទ្រឹស្ដីសហកម្មឧក្រិដ្ឋរួម ហៅថា *ជេស៊ីអ៊ី* ចំពោះអង្គហេតុនៃរឿងនេះ ទោះបីជាយ៉ាងណាក្ដី គឺថាយើងមិនទាន់បានដល់ដំណាក់កាល ដែលយើងត្រូវលើកទេ ។ ប៉ុន្តែ ជាការល្អ យើងនិយាយថាអំពីការយល់ដឹងរបស់គាត់ ដូច្នេះជាផលពិបាក គឺនៅក្នុងសហកម្មឧក្រិដ្ឋរួម គឺថាអាចត្រូវអនុវត្តចំពោះករណីនេះក្នុងអង្គហេតុ ដើម្បីរកឲ្យឃើញនៅការទទួលខុសត្រូវទាំងស្រុងរបស់ជនជាប់ចោទ ជាពិសេសប្រសិនបើយើងរកឃើញថា គាត់បានអនុវត្តអំពើនោះ ជាសហចារី ជាមួយនឹងអ្នកក្រោមបង្គាប់ ហើយគាត់បានប្រព្រឹត្តអំពើឧក្រិដ្ឋ ដើម្បីសម្រេចបាននូវលទ្ធផលឲ្យបានព្រមគ្នា ជាមួយគ្នានោះ ពេលនោះ គាត់ត្រូវតែរកឃើញថា គាត់បានពិនិត្យបទឧក្រិដ្ឋ ដូចដែលគាត់បានបញ្ជាផ្ទាល់នោះដែរ ។ ហើយជាពិសេសអំពើរបស់គាត់ គាត់បានចូលរួមក្នុងការប្រព្រឹត្តិអំពើជាមួយនឹងសហចារីរបស់គាត់ ។ បន្ទាប់ពេលនោះ គាត់មិនមែនត្រឹមតែជាអ្នកជួយសម្រួល និងប្រព្រឹត្តបទល្មើសនោះទេ ប៉ុន្តែគាត់នឹងមានពិរុទ្ធភាពអំពីការប្រព្រឹត្តិបទឧក្រិដ្ឋ ហើយការដាក់ទោសចំពោះអ្វីដែលគាត់បានប្រព្រឹត្តនោះ ។

ខ្ញុំសូមជម្រាបថា ទ្រឹស្ដីសហកម្មឧក្រិដ្ឋរួម គប្បីតែយកមកអនុវត្តនៅក្នុងករណី ដើម្បីភ្ជាប់ការទទួលខុសត្រូវនឹងជនម្នាក់អំពីការប្រព្រឹត្តិរបស់គាត់ ហើយនិងការចូលរួមនៅការប្រព្រឹត្តិក្នុងបទឧក្រិដ្ឋនោះ ទោះបីជាគាត់មិនបានយកដៃផ្ទាល់គាត់ទៅប៉ះពាល់នោះក៏ដោយ ។ ហើយប្រសិនបើបទឧក្រិដ្ឋ

នោះមិនមានចម្រូងចម្រាសអ្វីនោះក៏ដោយ ផ្តុះបញ្ចាំងអំពីឧក្រិដ្ឋនេះ រួមទាំងការទទួលខុសត្រូវរបស់ជនជាប់ចោទ តែហេតុអ្វីបានជាយើងចំណាយពេលច្រើននៅលើអង្គហេតុទាំងឡាយ ប្រសិនបើអង្គហេតុនោះ ទទួលស្គាល់ហើយនោះ? តុលាការនេះ គឺជំរុញមិនឲ្យចំណាយពេលអង្គហេតុ ពីព្រោះអង្គហេតុទាំងឡាយត្រូវបានទទួលស្គាល់រួចហើយ ។

ជាការពិតណាស់ចម្លើយ គឺសាមញ្ញបំផុត នៅក្នុងប្រព័ន្ធច្បាប់នេះ ជនជាប់ចោទ គឺមិនអាចមានពិរុទ្ធភាពទេ ទាល់តែអង្គហេតុនោះត្រូវបានវិនិច្ឆ័យ ហើយជាការពិតណាស់ យើងត្រូវពិចារណាអំពីអង្គហេតុទាំងអស់នេះ ហើយនិងការសហការរបស់ជនជាប់ចោទក្នុងពេលស៊ើបអង្កេត ។ ជាមន្ត្រីតុលាការ យើងត្រូវតែទទួលស្គាល់អំពីការសហការបែបនោះ ។

ជាប់តាំងពីពេលចាប់ផ្តើម ជនជាប់ចោទបានបោះបង់សិទ្ធិនៅស្ងៀមមិននិយាយស្តី ហើយផ្តល់សេចក្តីថ្លែងការណ៍ចំពោះ២៤ ជូនសហចៅក្រមស៊ើបអង្កេត ដែលរួមមានឯកសារជាច្រើន និងការពន្យល់ទៅលើឯកសារទាំងអស់នោះ ។ ការសហការរបស់ជនជាប់ចោទ គឺបានសម្រួលដល់ការផ្ទៀងផ្ទាត់ទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ហើយនិងការរកឃើញ ឬការបំភ្លឺទៅលើឯកសារជាក់លាក់មួយចំនួន ដែលយើងដឹងច្បាស់ថា វាអាចជួយសម្រួលដល់ដំណើរការនេះ ។

[១១:៥០:៥៨]

ជាពិសេសជនជាប់ចោទបានជួយឲ្យយើងយល់អំពីគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានជួយបញ្ជាក់លើភាពត្រឹមត្រូវលើឯកសារ និងសំណេរមួយចំនួន ។ គាត់បានចូលរួមនៅក្នុងការសម្តែង និងការតទល់ និងបានផ្តល់នូវការបកស្រាយរបស់គាត់លើឯកសារលាយលក្ខណ៍អក្សរមួយចំនួនក៏រួមទាំងវាក្យសព្ទខ្មែរក្រហមមួយចំនួន ។

ដូច្នេះ ទោះបីយើងខ្ញុំសន្និដ្ឋានថា ការសហការនេះត្រូវបានកម្រិតត្រឹមការទទួលស្គាល់លើអំណាចពិតប្រាកដ និងការទទួលខុសត្រូវរបស់គាត់នៅក្នុងឧក្រិដ្ឋក៏ដោយ សក្ខីកម្មរបស់គាត់ គឺជាផលប្រយោជន៍នៃការស្វែងរកការពិតក្នុងលក្ខណៈកម្រិតមួយតែប៉ុណ្ណោះ ។ ជនជាប់ចោទទទួលស្គាល់ថា ការសហការនេះគឺកើតចេញពីវិប្បដិសារី គាត់ទទួលស្គាល់ភាពអសីលធម៌នៃសកម្មភាពអតីតកាលរបស់គាត់ ហើយជាការពិតណាស់ គាត់បានសុំឲ្យជនរងគ្រោះទាំងឡាយអភ័យទោសដោយ ផ្ទាល់តែម្តងនៅពេលសម្តែងឡើងវិញ និងតាមរយៈមេធាវីការពារក្តីរបស់គាត់ ។

ខ្ញុំសូមបញ្ជាក់ថា គាត់នឹងមិនធ្វើដូច្នេះតែទេ នៅចំពោះមុខលោក លោកស្រីចៅក្រម ។ ថាតើវិប្បដិសារីនេះមានលក្ខណៈពិតប្រាកដប៉ុនណា ? ផ្ទុយពីការយល់ឃើញរបស់អ្នកជំនាញផ្នែកវិកលចរិត ខ្ញុំសូមលើកឡើងថា ជាការពិត ចំណុចនេះគឺជាសំណួរដ៏ត្រឹមត្រូវមួយដែលត្រូវសួរ ។ គាត់មិនដែលបានសុំឲ្យជនរងគ្រោះអភ័យទោសឲ្យគាត់ពេលគាត់ត្រួតពិនិត្យការធ្វើទារុណកម្ម និងសម្លាប់លើជនរងគ្រោះឡើយ ។ តើយើងអាចជឿលើការសារភាពនាពេលនេះដែរឬទេ? ប្រសិនបើជនជាប់ចោទទទួលវិប្បដិសារីចំពោះការដាក់ទោសមែននោះ ដូច្នេះ វិប្បដិសារីនោះ ត្រូវតែបង្ហាញតាមការពេញចិត្ត និងរកឲ្យឃើញតាមរយៈការយល់របស់ចៅក្រម ។ ប្រសិនបើវាអ៊ីចឹងមែននោះ ខ្ញុំសូមលើកឡើងថា អតីតកាលអាចជួយឆ្លុះបញ្ចាំងអំពីបច្ចុប្បន្នកាល ដើម្បីវិនិច្ឆ័យថាតើជនជាប់ចោទបានកែប្រែត្រឹមកម្រិតណា? លោក លោកស្រីចៅក្រមត្រូវតែមើលចំណុចណា ដែលគាត់បានចាប់ផ្តើមកែប្រែ ។ ចំណុចនេះ លោក លោកស្រីចៅក្រមត្រូវពិនិត្យមើលចាប់ពីឆ្នាំ ដែលគាត់បានចូលរួមក្នុងបក្សកុម្មុយនីស្តកម្ពុជា គាត់បានធ្វើ-- គាត់បានគេជ្រើសរើសឲ្យចូលជាសមាជិកនៅក្នុងបក្ស ដោយគ្រូរបស់គាត់ឈ្មោះ ឆាយ គឹមហួ ។ ១៥ឆ្នាំក្រោយមក គឺគាត់ទៅជាអ្នកចាត់ចែងលើការធ្វើទារុណ និងការសម្លាប់ ឆាយ គឹមហួ។ ចាប់តាំងពីគាត់ចាប់អារម្មណ៍ការអំពាវនាវរបស់បក្ស ហើយគាត់បានលាក់ខ្លួននៅក្នុងឆ្នាំ១៩៦៦ ដល់ឆ្នាំ ដល់ប្រហែលជាឆ្នាំ១៩៩២ នៅពេលដែលគាត់ដកខ្លួនឆ្ងាយពីខ្មែរក្រហម យើងពុំឃើញមានភស្តុតាង គាំទ្រលើការសន្និដ្ឋានជាជាងភស្តុតាងថា ជនជាប់ចោទបានប្តេជ្ញាទាំងស្រុងចំពោះបុព្វហេតុខ្មែរក្រហម និងគោលនយោបាយរបស់បក្ស ។ បក្សកុម្មុយនីស្តកម្ពុជា បានទទួលស្គាល់តាំងពីដើមលើការប្តេជ្ញា ហើយជនជាប់ចោទបានក្លាយជាកម្មាភិបាលដឹកនាំមន្ទីរសន្តិសុខនៅតំបន់១៥នៃភូមិភាគពិសេស ។ ចាប់ពីនោះមក គាត់បានបង្កើត និងដំណើរការមន្ទីរសន្តិសុខរបស់ភូមិភាគពិសេស គឺម១៣ ដែលដំណើរការស្របជាមួយមន្ទីរឧក្រិដ្ឋដទៃទៀត ដូចស-២១ ចាប់តាំងពីខែតុលា ឆ្នាំ១៩៧១ ដល់ខែមេសា ឆ្នាំ១៩៧៥ ។ គឺថាចំណុចនេះ គឺវាស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជាមិនស្ថិតនៅក្នុងយុត្តាធិការតុលាការក៏ដោយ ប៉ុន្តែលោក លោកស្រីចៅក្រមត្រូវតែបញ្ជាក់ថា ម១៣ គឺវាពាក់ព័ន្ធទៅនឹងករណីនេះ ។

[១១:៥៥:០៥]

ក្រោមបង្គាប់របស់ សុន សេន ហើយគ្រូមួយទៀតដែលគាត់បានសម្លាប់នៅស-២១ ជនជាប់ចោទ គឺបានដុសខាត់ជំនាញរបស់គាត់នៅម១៣ គឺជនជាប់ចោទ គាត់បានដំណើរការមន្ទីរម១៣ ហើយ

គាត់បង្កើតលក្ខខណ្ឌមួយដែលមានអមនុស្សធម៌នៅម១៣ ។ សាក្សីនឹងត្រូវផ្តល់សក្ខីកម្ម ដែលថាមានស្ត្រីជាច្រើន ហើយអ្នកទាំងអស់នោះ ត្រូវបានគេដាក់ខ្នោះ ហើយអ្នកទោសទាំងអស់ នោះមិនត្រូវបានគេផ្តល់ទឹកគ្រប់គ្រាន់ ។ ជនជាប់ចោទ គឺគាត់សម្លាប់ដោយខ្លួនឯង ឬក៏អ្នកក្រោមបង្គាប់របស់គាត់ ហើយគាត់ គឺថាជនជាប់ចោទបានធ្វើទារុណកម្មដោយខ្លួន ឧទាហរណ៍ដោយយកក្រណាត់ជ្រលក់ប្រេងកាត ។

ម១៣ គឺជាទីកន្លែងហ្វឹកហាត់ ហើយគឺជាកន្លែងដែលមានការវាយតប់ផ្សេងៗដល់អ្នកទោស ហើយជនជាប់ចោទបានធ្វើការសម្លាប់អ្នកទោស ។ សាក្សី អ្នកចុងក្រោយដែលត្រូវសម្លាប់នៅម១៣ គឺសម្លាប់នៅខែមេសា ឆ្នាំ១៩៧៥ ក្រោយពីការដួលរលំភ្នំពេញ គឺជនជាប់ចោទនឹងមកផ្តល់សក្ខីកម្ម ។ សាក្សី KW៣៣ គឺគាត់នឹងមកផ្តល់ចម្លើយថានៅក្នុងអំឡុងពេលនោះ គឺជនជាប់ចោទ គឺបានធ្វើការគ្រប់គ្រងទៅលើការសម្លាប់ និងការធ្វើទារុណកម្មរបស់ជនជាប់ចោទ គឺថាមានសាក្សីមកបង្ហាញអំពីការដែលអ្នកទោសផ្សេងៗត្រូវបានសម្លាប់ ហើយជនជាប់ចោទ គឺគាត់បានបង្កើតប្រព័ន្ធនៃការកត់ត្រាអ្នកចេញ អ្នកចូល ចំពោះអ្នកទោស ។ ហើយគាត់ គឺបង្កើតអំពីប្រព័ន្ធរាយការណ៍ ហើយគឺថា យើងឃើញមានការទទួលសេចក្តីបង្គាប់របស់គាត់ ហើយ ម១៣ គឺគាត់បានបង្កើតបច្ចេកទេសសួរចម្លើយ ហើយក្រោយមកយកមកប្រើនៅស-២១ ។ ម១៣ គឺផ្តល់ឱកាសឲ្យ គាត់ធ្វើការហ្វឹកហាត់អ្នកសួរចម្លើយ និងបុគ្គលក្រោមបង្គាប់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ ។ នេះគឺជាអំពើរបស់បុគ្គលដែលគាត់ធ្វើនៅក្នុងក្រោមការបង្ខិតបង្ខំ នេះជាជម្រើសរបស់គាត់ ហើយក្រោយពីការដួលរលំរបស់របបនេះ ហើយគាត់ចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តគោលនយោបាយផ្ទៃក្នុងរបស់របបនេះ ។ ថាតើមានអ្វីកើតឡើងក្រោយពេលដួលរលំរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៧៩ មានការលើកឡើងច្រើន ។ ជនជាប់ចោទ គឺគាត់បានលើកឡើងថា-- គឺយើងឃើញមាន ការកើតឡើងនូវស-២១ ប៉ុន្តែយើងត្រូវកត់សម្គាល់ថា នៅពេលដែលរបបនេះដួលរលំ គឺគាត់មិនបានរត់ចេញ គឺគាត់មិនបានឆក់យកឱកាសដែលវាកើតចេញពីផលវិបាកនៃសង្គ្រាមនេះ រត់ចេញពីខ្មែរក្រហម ហើយចេញមកទទួលស្គាល់សកម្មភាពរបស់គាត់ ហើយគាត់បានរត់ចូលព្រៃជាថ្មីម្តងទៀត ហើយគឺ គាត់នៅតែជាសមាជិកអស់រយៈពេល១៣ឆ្នាំទៀត ។ គឺខ្មែរក្រហមបានជឿជាក់លើគាត់ ហើយគាត់ត្រូវ បានគេបញ្ជូនទៅចិនឲ្យសិក្សារយៈពេល២ឆ្នាំ ។ នៅក្នុងឆ្នាំ១៩៩២ និង១៩៩៣ ជនជាប់ចោទចុងក្រោយចាប់ផ្តើមរត់ចោលបក្ស ហើយគាត់ឈប់គាំទ្រគោលនយោបាយរបស់បក្ស ។

លោក លោកស្រីចៅក្រមទីគោរព យើងមិនអាចបដិសេធថា សូម្បីតែអ្នក បុគ្គលិកដែលយកចិត្តទុកដាក់ គាត់បានរស់នៅក្នុងរបបនេះមួយរបប ។ ប៉ុន្តែច្បាប់ទទួលស្គាល់បញ្ហាមួយចំនួន ប៉ុន្តែវាមិនជាចំណុចការពារដែលលើកឡើងថា លោកបានប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ខ្លាចខ្លួនឯងក្លាយជាជនរងគ្រោះ ។ ការលើកឡើងដូច្នេះ វាមានលក្ខណៈងាយស្រួលពេក យើងត្រូវការពិចារណាចំពោះភស្តុតាងទាំងឡាយដែលថា ជនជាប់ចោទគាត់បានជ្រើសរើសយកផ្លូវមួយដែលនាំទៅដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលដាក់បន្ទុកលើគាត់ ហើយជនជាប់ចោទបានចូលរួម ដោយបានដឹង និងដោយមានឆន្ទៈ ជាជាងជនរងគ្រោះនៃការភ័យខ្លាច គាត់គឺជាបុគ្គលម្នាក់ដែលបង្កើតការភ័យខ្លាច ដែលការភ័យខ្លាចនេះគ្របដណ្តប់រហូតដល់ថ្ងៃឆក់យកជីវិតរបស់ជនរងគ្រោះ ។

នៅក្នុងការបញ្ចប់ការជំនុំជម្រះ ប្រសិនបើយើងបង្ហាញការពិតអំពីអ្វីដែលកើតឡើងនៅស-២១ ខ្ញុំសូមសន្និដ្ឋានដោយគោរពថា លោក លោកស្រីត្រូវតែដេញដោលជនជាប់ចោទអំពីអង្គហេតុនៃរឿងក្តីនេះ ហើយការសន្និដ្ឋាននៃអង្គហេតុទាំងនេះ បង្ហាញថា ជាជាងរូបភាពដែលគាត់ជាបុគ្គល ដែលអនុវត្តដោយខ្លួនឯង គឺគាត់បានបង្ហាញនៅក្នុងពេលស៊ើបអង្កេតថា គាត់មិនបានដឹងអំពីភាពភ័យខ្លាច ដែលប្រព្រឹត្តដោយបុគ្គលិកក្រោមបង្គាប់របស់គាត់ ។ គាត់មិនដឹងច្បាស់ ហើយគាត់គឺជាអ្នកយកចិត្តទុកដាក់ចំពោះការសម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ហើយព្រឹត្តិការណ៍ទាំងអស់នេះ គឺអាចអះអាងថា គឺជាឧក្រិដ្ឋកម្ម ហើយគាត់ក៏អាចទទួលបានផលប្រយោជន៍ខ្លះអំពីការទទួលស្គាល់ ។

ដើម្បីសន្និដ្ឋានបញ្ចប់ លោក លោកស្រីចៅក្រម យើងទាំងអស់គ្នានឹងចាប់ផ្តើមស្តាប់ភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ ដូចជាភស្តុតាងដែលយើងខ្ញុំលើកឡើងសង្ខេបសម្រាប់ថ្ងៃនេះ ។ យើងបានលើកឡើងទៅលើប្រធានបទមួយចំនួន ហើយបង្ហាញក្នុងលក្ខណៈទូទៅ ។យើងបានពិភាក្សាអំពីការកើតឡើងនៃបក្សកុម្មុយនីស្តកម្ពុជា ការវាយប្រហារក្នុងលក្ខណៈរីករាលដាល និងលក្ខណៈស៊ីសង្វាក់លើប្រជាជនកម្ពុជា និងជម្លោះប្រដាប់អាវុធនៅវៀតណាម ។

យើងនិយាយអំពីឧក្រិដ្ឋកម្មដ៏សាហាវ ដែលប្រព្រឹត្តនៅស-២១ ហើយនឹងការទទួលខុសត្រូវផ្នែកច្បាប់ និងជាក់ស្តែងចំពោះឧក្រិដ្ឋកម្មទាំងអស់នោះ ។ បញ្ហាទាំងអស់នេះ គឺវាជាធាតុផ្សំសម្រាប់ការជំនុំជម្រះ ហើយគួរ យើងគួរតែពិនិត្យឲ្យបានហ្មត់ចត់ ហើយខ្ញុំគិតថាយើងគួរតែពិនិត្យ ប៉ុន្តែខ្ញុំសូមសន្និដ្ឋានដោយគោរពថា ដើម្បីរកយុត្តិធម៌ យើងត្រូវតែរកការពិត ហើយការពិតគឺអាចបង្ហាញតាមរយៈរឿងរ៉ាវរបស់ជនរងគ្រោះនីមួយៗពីជនរងគ្រោះ ។ បុគ្គលដែលគាត់នៅពីក្រោយពាក្យស្លោក និងប្រភេទមួយ

ចំនួន គឺបុគ្គលទាំងអស់នេះ មានឈ្មោះ មានជន មានសាច់ញាតិរបស់ខ្លួន មានការចងចាំផ្សេងៗ ហើយពួកគេគួរទទួលបានថ្ងៃនេះនៅក្នុងតុលាការ ហើយមករៀបរាប់អំពីរឿងរ៉ាវដែលពួកគេចងចាំ ។ ហើយនៅពេលដែលមានការជំនុំជម្រះ គាត់នឹងនិយាយអំពីរឿងរ៉ាវរបស់គាត់ ការស្តាប់ផ្សេងៗ ហើយជនជាប់ចោទ គឺគាត់មិនមែនជាបុគ្គលដូចនៅក្នុងថ្ងៃនេះទេចំពោះការឈឺចាប់ផ្សេងៗដែលកើតឡើងពីរបបមុន ។ ទោះបីជាមានការឈឺចាប់ក៏ដោយ គឺកាំង ហ្កេកអ៊ាវ ឬ ឌុច ហៅ ឌុច ត្រូវតែស្តាប់នៅលើរឿងរ៉ាវទាំងអស់នេះ ដោយសារតែវាជាតម្រូវផ្នែកយុត្តិធម៌ ។

[១២:០៣:២៥]

មុនពេលដែលយើងពិចារណាការអញ្ជើញមេធាវីការពារក្តីធ្វើការយល់ទៅលើចំណុចមួយចំនួននោះ គឺយើងឃើញថា មានការមិនគិតរវល់អំពីបញ្ហាមនុស្សធម៌ ហើយគាត់បានក្លាយទៅជាឃាតក អ្នកសម្លាប់ ហើគាត់បានទទួលស្គាល់ចំពោះជនរងគ្រោះរបស់គាត់ ចំពោះមនុស្សធម៌ទាំងអស់នេះ ។ ថាតើយើងរកយុត្តិធម៌យ៉ាងម៉េច យើងត្រូវតែយកច្បាប់មកអនុវត្តចំពោះអង្គហេតុ ដើម្បីឲ្យយើងរកឃើញយុត្តិធម៌ យើងមិនអាចធ្វើអ្វីក្រៅពីនេះ ។ គឺយើងដឹងអំពីច្បាប់ ហើយច្បាប់នៅចំពោះមុខយើង ។ យើងមានអង្គហេតុគឺជនរងគ្រោះ ហើយយើងមានភាពត្រេកអរដែលថា យើងបានដឹងអំពីបញ្ហាសាហាវផ្សេងៗដែលកើតឡើង ហើយចំពោះអង្គហេតុ និងកិត្តិយស ដែលបានបដិសេធចំពោះគាត់កាលពីលើកមុន គឺយើងត្រូវតែស្តាប់សម្លេងរបស់គាត់ដែលវាបាត់បង់យូរមកហើយនៅក្នុងនិទ្ទណ្ឌភាព ហើយគាត់នៅពេលនេះទាមទារឲ្យមានយុត្តិធម៌ដែលបានបដិសេធយូរមកហើយ ។ ដូច្នេះ គឺនៅពេលនេះ គឺយើងព្យាយាមរកយុត្តិធម៌ ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា ឥឡូវហ្នឹងយ៉ាងម៉េចទៅ ពេលវេលាដូចជាអស់ហើយ ។ ពេលវេលាអស់ហើយម៉ោង១២ជាងហើយ ហើយតើបទបង្ហាញរបស់លោកហ្នឹងនៅប៉ុន្មានទៀត?

**លោក រ៉ូប៊ឺត ពើទីត៖**

អ៊ឺចឹង ខ្ញុំនឹងចំណាយពេលតែប៉ុន្មាននាទីតែប៉ុណ្ណោះ ។

នៅពេលដែលយើងពិនិត្យលើជនរងគ្រោះ គឺយើងនឹងឃើញមានការឆ្លើយតបទៅលើសំណួរដែលលោកសាស្ត្រាចារ្យ *អាវ៉ូសែល* សួរ គឺគាត់បានសួរថា គឺមិនមែនតែរឿងរ៉ាវទេ យើងត្រូវធ្វើការរកយុត្តិធម៌តាមរយៈរឿងរ៉ាវ ដែលបានប្រាប់ទាំងអស់នោះ ។

ខ្ញុំសូមដាក់ជូនសេចក្តីសន្និដ្ឋានទាំងអស់ ដូចលោក លោកស្រីចៅក្រមបានជ្រាបនៅពេលនេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលត្រូវពិសារអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះសាលាដំបូងសូមប្រកាសសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់រហូតដល់ម៉ោងមួយកន្លះរសៀល ហើយអង្គជំនុំជម្រះសូមជម្រាបអ្នកចូលរួម និងសាធារណជនទាំងអស់ចូលមកកាន់ទីកន្លែងរៀងខ្លួនៗឲ្យបានមុនម៉ោង១និង៣០នាទី ដើម្បីបន្តសវនាការ ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងទៅកាន់បន្ទប់រងចាំ ហើយនាំបង្គាប់ឲ្យត្រឡប់មកវិញឲ្យបានមុនម៉ោង១ និង៣០នាទី ។

*[សវនាការសម្រាកនៅម៉ោង ១២:០៧នាទីដល់ម៉ោង ១៣:៣៣នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ ៖**

អង្គជំនុំជម្រះប្រកាសកិច្ចបន្តដំណើរនីតិវិធីសវនាការ ។

កិច្ចជាបន្តនេះត្រូវដល់ពេលវេលាដែលមេធាវីការពារជនជាប់ចោទ និងជនជាប់ត្រូវឡើងធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ។ ប៉ុន្តែ ពីម្សិលមិញអង្គជំនុំជម្រះបានបានទទួលនូវលិខិតមួយរបស់មេធាវីការពារក្តី ដែលបានស្នើសុំមកអង្គជំនុំជម្រះអំពីការប្រព្រឹត្តិទៅនៃការធ្វើសេចក្តីសន្និដ្ឋានតបនេះ ហើយមុននឹងសម្រេចអំពីដំណើរការនីតិវិធីទៅមុខទៀត សូមអញ្ជើញមេធាវីការពារក្តីឡើងបង្ហាញបញ្ជាក់អំពីខ្លឹមសារនៃលិខិតនិងគោលបំណងរបស់លិខិតដែលផ្ញើមកអង្គជំនុំជម្រះសាលាដំបូងពីម្សិលមិញ ថាតើការប៉ុនប៉ងនោះយ៉ាងដូចម្តេច?

សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ មេធាវីការពារពិចារណាឃើញថា ជនរងគ្រោះបានរង់ចាំជាយូរមកហើយដើម្បីឲ្យជនជាប់ចោទនិយាយដោយខ្លួនឯង ។ មេធាវីការសូមស្នើថា សូមឲ្យផ្តល់ឱកាសឲ្យ

ជនជាប់ចោទនិយាយក្នុងពេលនេះ ។ បន្ទាប់ពីនោះមក មេធាវីការពារនឹងសម្រេច ថាតើមេធាវីរបស់ខាងការពារត្រូវមានអ្វីបន្ថែមដែរឬទេ?

ចំណុចដំបូងគឺ យើងសូមស្នើការអនុញ្ញាតពីតុលាការ ដើម្បីសូមឲ្យជនជាប់ចោទគាត់និយាយដោយខ្លួនឯងជាមុន ។ ជាការឆ្លើយតបទៅនឹងសេចក្តីថ្លែងការបើករបស់សហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រម និងការសូមឲ្យមានការផ្លាស់ប្តូរនូវ នូវការដែលឡើងធ្វើសេចក្តីថ្លែង-ការណ៍តបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបដែលធ្វើឡើងដោយសហព្រះរាជអាជ្ញានេះ។

ហើយជាកិច្ចបន្តសូមអញ្ជើញលោក កាំង ហ្គេកអ៊ាវ សូមអញ្ជើញក្រោកឈរ ។

សូមអញ្ជើញលោកធ្វើការសេចក្តីសន្និដ្ឋានតបទៅនឹងបទចោទប្រកាន់ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា ។ សូមអញ្ជើញ ។

[១៣:៣៥:៤៧]

**ជនជាប់ចោទ៖**

សូមអរគុណលោកប្រធាន ។ ដំបូងខ្ញុំសូមបញ្ជាក់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅកម្ពុជាខ្លះ ។ តាមតម្រាយដែលសហព្រះរាជអាជ្ញាលោកមានប្រសាសន៍រួចមកហើយ ។ ខ្ញុំសូមបញ្ជាក់ថា ប្រជាជនកម្ពុជា រងទុក្ខវេទនា ដោយការកាប់សម្លាប់នេះយូរឆ្នាំហើយ គឺចាប់តាំងពីឆ្នាំ១៩៦៦ ដែលឧត្តមសេនីយ៍ លន់ នល់ គាត់កាប់សម្លាប់កសិករនៅសំឡូត ។ បន្ទាប់មកទៀតរដ្ឋប្រហារ ១៨មីនា ភាគនយោបាយទាំងអស់ ប្រណាំងប្រជែងគ្នាកាប់សម្លាប់ប្រជាជនកម្ពុជារហូតដល់ថ្ងៃ១៧ មេសា ១៩៧៥ ទើបឧក្រិដ្ឋ-កម្មនេះ វាធ្លាក់ផ្តាច់មុខទៅលើបក្សកុម្មុយនីស្តកម្ពុជា នេះតម្រាយប្រវត្តិសាស្ត្រដែលខ្ញុំសូមលើកជូនអង្គប្រជុំ ស្របតាមតម្រាយដែលសហព្រះរាជអាជ្ញាព្រឹកមិញ លោកមានប្រសាសន៍ ។

តទៅនេះ ខ្ញុំសូមបញ្ជាក់អំពីគោលជំហរខ្ញុំ ដូចតទៅ៖

ពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា ជាអ្នកទទួលខុសត្រូវផ្តាច់មុខលើឧក្រិដ្ឋកម្មនៅកម្ពុជា ភស្តុតាងសំខាន់គឺ លក្ខន្តិកៈបក្សឆ្នាំ១៩៧៦ ។ ទំព័រទី១ នៃលក្ខន្តិកនេះសរសេរជាអាទិ៍ថា "ក្រោយពីដឹកនាំសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ បានទាំងស្រុងនឹងជាស្ថាពរនៅថ្ងៃ១៧ មេសា ១៩៧៥ មក ។ បក្សកុម្មុយនីស្តកម្ពុជា ដឹកនាំបដិវត្តន៍សង្គមនិយម និងកសាង

សង្គមនិយមតទៅទៀត ដោយផ្ដាច់មុខ ដាច់ខាតនឹងគ្រប់ផ្នែក” នេះជាភស្តុតាងដែលខ្ញុំសូមលើកជូនជាតិប្រជាជនតាមរយៈអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ។

ទី១) ខ្ញុំសូមវិភាគអំពីឧក្រិដ្ឋកម្មទូទាំងប្រទេសពីថ្ងៃ១៧មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។ ក្រោយ ១៧ មេសា ១៩៧៥ ប៉ុល ពត កើតចិត្តភ្លើតភ្លើនខ្លាំងណាស់ បានលើកមាគ៌ាដែលប៉ះពាល់អាយុមនុស្ស នេះគឺមកពី ប៉ុល ពត គាត់មានសព្វមានគ្រប់ សំខាន់គឺមានបក្ខជនរាប់ម៉ឺននាក់នៅក្នុងកណ្ដាប់ដៃគាត់ ។ ឧក្រិដ្ឋកម្មជំនាន់នោះធំធេងណាស់ ។ ដោយឡែកការបាត់បង់អាយុជីវិតមានទៅដល់ជាងមួយលាននាក់ ដោយខ្ញុំជាបក្ខជនមួយរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំទទួលស្គាល់ថា “ខ្ញុំពិតជាមានតួនាទីទទួលខុសត្រូវខាងផ្លូវចិត្តលើឧក្រិដ្ឋកម្មដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តនៅជំនាន់នោះ” ខ្ញុំសូមសម្តែងនូវវិប្បដិសារី សោកស្ដាយយ៉ាងឈឺចាប់បំផុត ចំពោះឧក្រិដ្ឋកម្មគ្រប់យ៉ាង ដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩ ។

ទី២) ខ្ញុំសូមបញ្ជាក់ដោយឡែក អំពីឧក្រិដ្ឋកម្មនៅ ស-២១ ខ្ញុំសូមទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្ញុំតាមផ្លូវច្បាប់ ។ ខ្ញុំសូមបញ្ជាក់ថា តាមផ្លូវច្បាប់ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលកើតមាននៅ ស-២១ សំខាន់គឺសកម្មភាពធ្វើទារុណកម្ម និងសម្លាប់ផ្ដាច់ផ្ដោចអាយុជីវិតមនុស្ស ។

តាមតម្រាយដែលខ្ញុំបានធ្វើរួចមកហើយ នៅវេលាដែលលោកសហចៅក្រមស៊ើបអង្កេតនាំខ្ញុំទៅសម្ដែងសកម្មភាពរំឭកព្រឹត្តិការណ៍ចាស់ឡើងវិញ នៅជើងឯកនិងនៅសារមន្ទីរប្រល័យពូជាសាសន៍ទួលស្លែងគឺ ខ្ញុំសូមអនុញ្ញាតចូលសុំទោសជនរងគ្រោះ ដែលនៅរស់រានមានជីវិត និងសុំទោសក្រុមគ្រួសារជនរងគ្រោះទាំងអស់ដែលបានស្លាប់បាត់បង់ជីវិតយ៉ាងអាណោចអាធ័មនៅស-២១ ។

ពេលនេះ ខ្ញុំសូមអស់លោកទាំងនោះ លោកមេត្តាទទួលដឹងឮថាខ្ញុំចង់សុំទោស សូមលោកមេត្តាយកបំណងនេះទៅពិចារណា ។ ខ្ញុំមិនជាមិនទាន់ទាមទារសូមឲ្យលោកអត់ទោសឲ្យខ្ញុំនៅពេលឥឡូវនេះទេ ។ ខ្ញុំដឹងហើយថា ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើជីវិតមនុស្សជាពិសេសទៅលើជីវិតស្ត្រី និងកុមារ ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរមិនអាចអត់ឱនឲ្យបានទេ ។ សំណូមពរបច្ចុប្បន្ននេះ របស់ខ្ញុំគឺសូមអស់លោក លោកមេត្តាទុកទ្វារចូលសុំទោសនេះ ឲ្យនៅចំហ ។

[១៣:៤៥:០០]

ទី៣) វិប្បដិសារីដ៏សែនចុកចាប់របស់ខ្ញុំ

រំឭកអតីតកាលពេលណា ខ្ញុំសែនខ្លោចផ្សាពេលនោះ ។ ខ្ញុំតក់ស្លុតណាស់ កាលណាខ្ញុំនឹកដល់សកម្មភាពកន្លងមក ដែលខ្ញុំបានទទួលអនុវត្តនិងបានបញ្ជាឲ្យអនុវត្ត ដែលសុទ្ធតែជាសកម្មភាពប៉ះពាល់ដល់អាយុជីវិតជនស្លូតត្រង់យ៉ាងច្រើនក្នុងនោះរួមមានទាំងស្ត្រី និងកុមារផង ។

ទោះបីខ្ញុំធ្វើដោយគោរពតាមបញ្ជារបស់អង្គការក៏ដោយ ក៏ខ្ញុំពិតជាទទួលខុសត្រូវចំពោះឧក្រិដ្ឋ-កម្មទាំងនេះ ។ ខ្ញុំបានជម្រាបសហចៅក្រមស៊ើបអង្កេតហើយថា ខ្ញុំជាចំណាប់ថ្នូរនិងជាតួសម្តែងនៃរបបឧក្រិដ្ឋកម្មនេះ ។ ខ្ញុំជឿថា មនុស្សម្នាជាទូទៅនៅពេលនេះ ចាត់ទុកខ្ញុំថាកំសាក ថាអមនុស្សធម៌ ខ្ញុំទទួលពាក្យនេះដោយស្មោះនិងដោយគោរព ។ នៅសម័យស-២១នោះ ខ្ញុំចាត់ទុកជីវិតខ្ញុំនិងជីវិតគ្រួសារខ្ញុំសំខាន់លើសជីវិតអ្នកជាប់ឃុំឃាំងនៅស-២១ នោះ ។

ប្រកែកប្រណាំងនឹងបទបញ្ជាពីខាងលើ ទោះបីដឹងថា បទបញ្ជានោះឧក្រិដ្ឋក៏ដោយ ក៏ខ្ញុំមិនដែលប៉ិននឹកនាដល់ដែរ នៅជំនាន់នោះ ។ នេះជាបញ្ហាស្លាប់រស់របស់ខ្ញុំនិងគ្រួសារខ្ញុំ ។ ក្នុងឋានៈខ្ញុំជាប្រធានស-២១ ខ្ញុំអត់ប៉ិនគិតគូរកលទ្ធភាពអ្វី ក្រៅពីអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើទេ ។ ទោះបីខ្ញុំដឹងថាការអនុវត្តនោះនាំទៅរកការបាត់បង់អាយុជីវិតមនុស្សរាប់ពាន់ៗនាក់ក៏ដោយ ។ បច្ចុប្បន្ននេះ ខ្ញុំមានវិប្បដិសារីសោកស្តាយយ៉ាងជ្រាលជ្រៅ ព្រមទាំងខ្មាសអៀន ព្រមទាំងមានសភាពរអៀសក្នុងឋានៈជាអ្នកមានខ្លួន មានទោស ដឹងថាខ្លួនជាអ្នកមានទោសចំពោះជាតិប្រជាជនកម្ពុជាទាំងមូល ។

ចំពោះគ្រួសារជនរងគ្រោះទាំងអស់ ដែលបានបាត់បង់ជីវិតនៅស-២១ ព្រមទាំងចំពោះក្រុមគ្រួសារខ្ញុំផ្ទាល់ ដែលមានសមាជិកមួយចំនួនបាត់បង់ជីវិតទៅក៏ដោយ ។

[១៣:៣៨:៥៣]

**វិធានការដោះស្រាយខាង-- ពេលបច្ចុប្បន្ននេះរបស់ខ្ញុំ**

ខ្ញុំបានសម្រេចចិត្តសហការជាមួយអង្គ អ.វ.ត.ក ដោយហេតុថា ទុក្ខទោសទាំងប៉ុន្មានដែលខ្ញុំបានប្រព្រឹត្តទៅលើប្រជាជនខ្ញុំ មានតែផ្លូវនេះតែមួយប៉ុណ្ណោះគត់ដែលអាចរំលែកទុក្ខសោកទាំងអស់ដែលបង្កឡើងដោយឧក្រិដ្ឋកម្មរបស់ស-២១ និយាយដោយឡែក និងឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជានិយាយជារួម ។

ខ្ញុំសូមបញ្ជាក់ថា ស-២១ និងវិនាសកម្មគួរឲ្យរន្ធត់ទាំងប៉ុន្មានដែល ស-២១ បង្កើតឡើងជាបាតុ-ភាពជាក់ស្តែងដែលខ្ញុំសូមប្រគល់ខ្លួនជូនអង្គ អ.វ.ត.ក ជំនុំជម្រះខ្ញុំដោយផ្លូវច្បាប់ដ៏ស្មោះនិងយ៉ាងឱនលំទោនជានិច្ច ។

នៅចុងបញ្ចប់នេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំពិតជាសហការតទៅទៀតជាមួយអ.វ.ត.ក នៅពេលសវនាការ ដោយខ្ញុំពិតជាឆ្លើយសំណួររបស់លោកនិងលោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ។ ឆ្លើយសំណួររបស់លោកនិងលោកស្រីសហព្រះរាជអាជ្ញា ឆ្លើយសំណួររបស់ដើមបណ្ដឹងរបស់រដ្ឋប្បវេ-ណីទៅតាមការចង់ដឹង និងដោយឈរលើឯកសារជាភស្តុតាង ។

លោកប្រធានជាទីគោរព!

តទៅនេះខ្ញុំសូមលោកមេត្តាអនុញ្ញាតឲ្យខ្ញុំថ្លែងអំពីវិប្បដិសារីដែលខ្ញុំមានប្រចាំជីវិតជូនដូចតទៅៈ

ខ្ញុំអត់ពេញចិត្តទេ ក្នុងការធ្វើការងារនេះ ។ ខ្ញុំបានសុំចេញទៅសហកម្មនៅ ខែ៥ ឆ្នាំ១៩៧៥ តែមិនបានសម្រេច ។ គេចាត់ឲ្យខ្ញុំធ្វើមន្ទីរស-២១ ខ្ញុំក៏បានធូរចិត្តម្យ៉ាងដែរ ដោយខ្ញុំធ្វើអនុប្រធានគេ ។ បន្ទាប់មកខ្ញុំធ្វើប្រធាន ខ្ញុំតវ៉ាទៀត សុំយកអ្នកផ្សេងមកធ្វើប្រធាន ខ្ញុំធ្វើអនុប្រធាន ខ្ញុំត្រូវគេកំហែង ។ ខ្ញុំក៏ព្រមធ្វើតទៅទៀត ។

រឿងដែលខ្ញុំចាប់ផ្ដើមតក់ស្លុត ចាប់ផ្ដើមនឹកឃើញគឺ ថ្ងៃ៣១ មករា ១៩៧៧ នៅពេលដែល សុន សេន គាត់បញ្ជាឲ្យចាប់កម្មាភិបាលភូមិភាគឧត្តរចាស់ មកជាចំនួនច្រើនៗម្ដង ខ្ញុំតក់ស្លុតណាស់ ។ ខ្ញុំសាកល្បងសុំយោបល់គាត់ថាបង មនុស្សនេះដូចជាមិនមែន ។ គាត់កំហែងខ្ញុំពីខាងម្ខាងទូរស័ព្ទមកថា “យើ ឌុច! ចម្លើយអាធួនណា!” ។ ខ្ញុំលែងហ៊ានមាត់ ។ ខ្ញុំគិតក្នុងចិត្ត “ឱ! អ្នកដែលបានប្ដូរផ្ដាច់អាយុជីវិតដើម្បីរំដោះជាតិ ប្រជាជនខ្លួន ឥឡូវធ្លាក់មកស្លាប់ ធ្លាក់មកជាប់គុកក្នុងឋានៈជាជនក្បត់បក្ស” ។

ខ្ញុំសូមបញ្ជាក់ជូនជាតិប្រជាជន តាមរយៈអង្គជំនុំជម្រះសាលាដំបូងនេះថា ខ្ញុំនិងកម្មាភិបាលឧត្តរ មានមនោសញ្ចេតនាជ្រាលជ្រៅនឹងគ្នាណាស់ ។ ខ្ញុំជាប់គុកកាលពីឆ្នាំ១៩៦៨ ភាគច្រើនជាមួយពួកអស់នេះដែរ ។ ការរន្ធត់តក់ស្លុតរបស់ខ្ញុំចេះតែបន្តទៅទៀតនៅពេលដែលគេចាប់មនុស្សពីភូមិភាគផ្សេងៗ ចុងបញ្ចប់គេចាប់បង ង៉ែត ញូ ហៅ ហុង មកនៅថ្ងៃ១៣ មីនា ១៩៧៨ ។ ខ្ញុំគិតថា “អីយ៉ាស់! អាយុជីវិតខ្ញុំជិតដល់ពេលហើយ” ។ ដូច្នេះ ការតក់ស្លុតចំពោះការត្រូវគេចាប់ចងវាម្យ៉ាង ការតក់ស្លុតចំពោះអាយុជីវិតខ្លួនឯងក្រែងមិនរស់នេះក៏ម្យ៉ាងទៅទៀត ។

[១៣:៥២:០៨]

ដល់ចុងបញ្ចប់ មេធំរបស់ខ្ញុំ គឺបងទី២ បញ្ជាឲ្យខ្ញុំបញ្ចេញជនរងគ្រោះពីស-២១ ឲ្យអស់ទៅជើងឯក ។ ខ្ញុំថា “ដល់ពេលហើយជីវិតខ្ញុំ” ពេលនោះខ្ញុំធ្វើការអត់កើតទេ ។ ខ្ញុំដេកនៅផ្ទះទាំងយប់ទាំងថ្ងៃ សួរចុះអ្នកដែលខ្ញុំធ្លាប់ទៅអង្គុយនៅកន្លែងគូរធ្លាក់ គេអត់ឃើញមុខខ្ញុំទៅទីនោះទៀតទេ ។

ចុងបញ្ចប់ ម៉ោង១១ ថ្ងៃ៧ មករា រថក្រោះគេបរមុខកាត់មុខផ្ទះខ្ញុំ ខ្ញុំចប់លែងដឹងធ្វើអី ។ ម៉ោង២ ខ្ញុំនាំគ្នាចេញពីកន្លែងទីតាំងស-២១ ទៅនៅកន្លែងសន្សំកុសល ចាំយប់ព្រលប់ៗបានខ្ញុំចេញទៅទៀត ។

ក្នុងមួយឆ្នាំនៃការរត់គៀសសឹក ខ្ញុំបាត់បង់អស់អាយុជីវិតមនុស្សដែលនៅជុំវិញខ្លះ ដែលទៅជាមួយខ្ញុំទាំងប៉ុន្មាន ប្អូនខ្ញុំ២នាក់ស្លាប់, ក្មួយខ្ញុំ៦នាក់ស្លាប់, ប្រពន្ធមិត្តប៉ុន រួមទាំងមិត្តប៉ុនទៀត ទាំងកូនមិត្តប៉ុន ទៀតស្លាប់, ប្រពន្ធបង ម៉ម ណៃ ស្លាប់, មិត្តយើងផ្សេងទៀតស្លាប់ៗគ្មានសល់ ចុងបញ្ចប់នៅសល់តែខ្ញុំម្នាក់ឯង ។ គ្នាបួននាក់មិនមែនម្នាក់ឯងទេ ។ ខ្ញុំ ហើយនិងប្រពន្ធខ្ញុំ ហើយនិងកូនពីរនាក់ ។ នៅពេលនោះខ្ញុំចង់សុំចេញពី មិនព្រមនៅជាមួយនឹងបង សារុន ឈ្មោះដើម រៀង ឯម អនុលេខាភូមិភាគពាយព្យថ្មី ។ គាត់តាមទៅឱ្យគេទៅហៅខ្ញុំមកវិញ កាំភ្លើងបើកសោ *(ឮមិនច្បាស់)* ខ្ញុំថា “អើស! មនុស្សជាងមួយលាននាក់ស្លាប់ទៅហើយ ខ្ញុំបួននាក់ទៀតអត់អីទេ ស្លាប់ទៅចុះ!” ។ ដូច្នេះចំពោះអាយុជីវិតមនុស្ស និងអាយុជីវិតប្រជាជន កាលណានឹកដល់អាយុជីវិតមនុស្សដែលស្លាប់បាត់បង់ទៅក្នុងរបបនេះ អាយុជីវិតខ្ញុំមួយអត់ការ ។ *[១៣:៣៥:៤៧-៥៦ ជនជាប់ចោទនិយាយភាសាបារាំង]* ខ្ញុំគិតអ៊ីចឹង ។

នេះចំពោះអាយុជីវិតខ្ញុំ ខ្ញុំឱ្យតម្លៃប៉ុណ្ណឹង ។ ដូច្នេះ ក្នុងមួយឆ្នាំហ្នឹងខ្ញុំធ្វើអីអត់កើតទេ រហូតៗដេកសំកុក ។ ចុងបញ្ចប់ខ្ញុំនឹកឃើញវិធីមួយគឺសែនសុំទោសជនរងគ្រោះ សែនសុំទោសឪពុកម្តាយដែលបង្កើតខ្ញុំមកប្រាថ្នាឱ្យកូនល្អ ខ្ញុំខ្លួនឯងក៏ប្រាថ្នាសងគុណមាតាបិតា រកផ្លូវល្អ ដល់ចុងបញ្ចប់ធ្លាក់ទៅលើផ្លូវអាក្រក់ ។

ខ្ញុំបង្កើតវិធីមួយ ដើម្បីលួងអារម្មណ៍ខ្លួនឱ្យបានស្ងប់បន្តិច គឺសែនសុំទោស មុនដំបូងគ្រាន់តែសុំទោសម្តាយឪពុកខ្ញុំ ហើយនិងគ្រូបាអាចារ្យខ្ញុំទេ ដល់យូរទៅវាជាការសែនសុំទោសជាតិប្រជាជនទាំងមូល ។ រាល់ថ្ងៃ១៧ វិច្ឆិកា ដែលជាថ្ងៃកំណើតខ្ញុំ រាល់ឆ្នាំឱ្យតែថ្ងៃ១៧ វិច្ឆិកា ខ្ញុំមិនដែលធ្វើអីកើតទេ ។ ខ្ញុំតែងធ្វើស្អីមួយបន្តិចបន្តួច សម្រាប់ជាការរំឭកនឹកដល់វិប្បដិសារីរបស់ខ្ញុំ ។ ក្នុងឆ្នាំនេះ ខ្ញុំបានគូរគំនូរមួយ ប្រសិនបើលោកប្រធាន និងអង្គជំនុំជម្រះសាលាដំបូងលោកអនុញ្ញាត ខ្ញុំលើកបង្ហាញជូន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញជនជាប់ចោទ, អង្គជំនុំជម្រះអនុញ្ញាត ។

**ជនជាប់ចោទ៖**

ថ្ងៃអង្សាររបស់បក្សកុម្មុយនីស្តកម្ពុជា ។

**ប្រធានអង្គជំនុំ៖**

ឲ្យដាក់-- រៀបចំដាក់បញ្ហាំងបានទេ?

អញ្ជើញក្រោកឈរឃើញ-- ជនជាប់ចោទអញ្ជើញក្រោកឈរ ។

អាចមើលឃើញទេផ្ទៀងអ៊ីចឹង?

**ជនជាប់ចោទ៖**

ថ្ងៃអង្សារ, ពាក្យថ្ងៃអង្សារនេះជាពាក្យ អក្សរផ្លូវការទេ ភាសានិយាយគេថា ថ្ងៃអន្សារ ។ ហើយតាមពិតមែន បក្សកុម្មុយនីស្តកម្ពុជាធ្វើបុណ្យខួបថ្ងៃ៣០ កញ្ញា ១៩៧៨ ជាថ្ងៃចុងក្រោយបក្សកុម្មុយនីស្តកម្ពុជាលែងធ្វើបានទៀតហើយ ។

ហើយចំណងជើងខ្ញុំដាក់ពីលើ ខ្ញុំដាក់ជារូបកណ្តាលមួយ ដាក់ថា "អបអរសាទីខួបឆ្នាំទី១៨ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជា" ។ រួចខាងលើហ្នឹងខ្ញុំដាក់រូបកៅអីបី ។ កៅអីកណ្តាលគឺតំណាងឲ្យប៉ុល ពត, កៅអីខាងស្តាំតំណាងឲ្យបងទីពីរ នួន ជា, ហើយកៅអីខាងឆ្វេងខ្ញុំដាក់តំណាងឲ្យតាម៉ុក ។ តាម៉ុកទើបនឹងឡើងអង្គុយកៅអីកិត្តិយសក្នុងពិធីបុណ្យខួបបក្សនៅពេលហ្នុងឯង១ ។

ពីលើកមុនមក ពេលខួបបក្សមានតែនួន ជា នៅពីស្តាំ, ប៉ុល ពត គាត់នៅពីឆ្វេង ហើយគាត់ឧទ្ទេសនាម ។ ក្នុងនេះសម្តីពិតមានតែមួយទេគឺសម្តី ប៉ុល ពត "មាគ៌ាត្រូវគឺឈ្នះ" ។ ក្រៅពីនោះជាពាក្យដែលខ្ញុំវិភាគអំពីការស្រមៃរបស់មនុស្សម្នាក់ៗ ។

[១៣:៥៨:៣៦]

ខ្ញុំសរសេរការសមៃរបស់ តាម៉ុក ។ ខ្ញុំសរសេរថា "គ្មានអីនៅពីលើអីអញបានទេ, នៅពីលើម៉ុកមានមួក នៅពីលើមួកមានមេឃ" ។ តាម៉ុក គាត់ចូលចិត្តលេងណាស់ លេងអា*កុងសូណង់* បារាំងគេថា *កុងសូណង់ស៍* ម៉ៗៗជូនគ្នា ។

ឯចំណែក ប៉ុល ពត វិញ ខ្ញុំគូរហើយ ខ្ញុំដាក់ការស្រមៃរបស់ប៉ុល ពតថា "សន្តតិវង្ស *ឌីណាស្ទី* របស់ ប៉ុល ពត ឈរយ៉ាងរឹងមាំនៅលើកម្លាំងរបស់ ម៉ុក" ។

ឯចំណែក នួន ជា វិញខ្ញុំដាក់ថាគាត់ស្រមៃ "អាណាធ្វើស្តេច ក៏អញនៅតែឧបរាជ" ។ នេះខ្ញុំតំណាងឲ្យអារម្មណ៍របស់មនុស្សម្នាក់ៗ ហើយនៅខាងក្រោមខ្ញុំគូសក្បាលខ្មោច សុទ្ធតែក្បាលខ្មោច ។ ហើយលើកទំនាយរបស់ចាស់ទុំម្នាក់ដែលគាត់ប្រាប់ខ្ញុំ អង្កាល់ដែលខ្ញុំទៅធ្វើទស្សនកិច្ចនៅតានេស ។ តានេស ហ្នឹងជាភូមិមួយ នៅក្នុងឃុំសឹង្ហ ស្រុក-- បើមិនស្រុកគោកមន ខ្ញុំមិនច្បាស់ទេ គឺស្រុកបន្ទាយ

អំពិល ។ អ្នកដែលនៅចាំដែរ តុលាការលោកអាចសួរបាន វរសេនីយ៍ នាក់ វង់ នៅប្រចាំការនៅបន្ទាយអំបិលរាល់ថ្ងៃនេះ ឮពាក្យហ្នឹងទាំងអស់គ្នាជាមួយនឹងខ្ញុំ ។ ហើយរូបដែលខ្ញុំគូរកណ្តៀវបីផ្គុំគ្នាហ្នឹង តុលាការលោកមើលចុះ កណ្តៀវបីផ្គុំគ្នាហ្នឹងទៅជាអក្សរ "បក្ខ" បានន័យថា បក្សកុម្មុយនីស្តកម្ពុជានេះ ខ្ញុំជៀលយូរហើយ តាំងពី៧៤មកមិនមែនជាអ្នកអនុវត្តផ្តាច់ការវណ្ណៈអធន គឺអ្នកអនុវត្តផ្តាច់ការកសិករដ៏ងងឹតងងុល ហើយខាងខ្នង លោកប្រែខាងខ្នង ខ្ញុំមានអត្ថាធិប្បាយជូនជាអក្សរខ្មែរច្បាស់លាស់ ហើយសូមចប់ប៉ុណ្ណេះ។

[១៤:០១:២១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សម្រេចយកឯកសារដែលជាគំនូរ និងបទបង្ហាញកំណត់សម្គាល់របស់ជនជាប់ចោទ ដែលបានបង្ហាញអង្គជំនុំអម្បាញ់មិញនេះ ដាក់បញ្ចូលទៅក្នុងសំណុំរឿង ។

ជាបន្ត គឺសូមអញ្ជើញមេធាវីការពារក្តី សូមឡើងធ្វើសេចក្តីសន្និដ្ឋានតប ទៅនឹងបទចោទប្រកាន់ដោយសង្ខេប ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ។ សូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមគោរព ប្រធាន សូមគោរព អង្គសវនាការទាំងមូល ។

ខ្ញុំជាមេធាវី ការពារជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅឌុច ដែលត្រូវជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពាន់យ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការរំលោភបំពារទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

សវនាការទីគោរព! ក្រោយពីបានតាមដានយកចិត្តទុកដាក់បំផុតនូវសេចក្តីសន្និដ្ឋានរបស់ចោទប្រកាន់របស់សហព្រះរាជអាជ្ញា មេធាវីការពារ សូមលើកឡើងនូវមតិមួយចំនួនជូនតុលាការ ក៏ដូចជាជូនអង្គសវនាការទាំងមូល ដើម្បីធ្វើការពិចារណាថ្លឹងថ្លែងរកយុត្តិធម៌តាមច្បាប់ដូចតទៅ៖

តើមានគោលបំណងយ៉ាងណាខ្លះ បានជាមានការកាត់ទោសមេដឹកនាំខ្មែរក្រហម ? ក្នុងការការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ គឺរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានគោលបំណងធំៗបីយ៉ាងគឺ គោលបំណងទីមួយ គឺដើម្បីរកយុត្តិធម៌ជូនដល់វិញ្ញាណក្ខន្ធ អ្នកដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលនៅរស់នៅសេសសល់ពីការកាប់សម្លាប់ ។ គោលបំណងទីពីរ គឺដើម្បីកុំរបបដ៏ឃោរឃៅនេះ កើតមាននៅលើទឹកដីកម្ពុជាជាលើកទីពីរ ។ គោលបំណងទីបី គឺក្នុងការរក

យុត្តិធម៌នេះ គឺឲ្យគោរពអធិបតេយ្យភាពជាតិខ្មែរ ។ អ៊ីចឹង ដើម្បីឲ្យវិញ្ញាណក្ខន្ធអ្នកដែលស្លាប់អាចទទួលយកបាន ហើយអ្នកដែលនៅរស់សល់ពីការកាប់ស្លាប់ក៏គេអាចទទួលយកបាន លុះត្រាតែការរកយុត្តិធម៌បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ ព្រោះច្បាប់តម្រូវឲ្យយកមកកាត់សេចក្តីនេះ តែមនុស្សពីរជំពូកប៉ុណ្ណោះទេ ។

ជំពូកទីមួយ គឺមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ តើអ្នកណាខ្លះជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ? អ៊ីចឹង មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមានប៉ុន្មាន ? ត្រូវយកមកកាត់ទោសឲ្យអស់កុំឲ្យសល់ នោះទើបវិញ្ញាណក្ខន្ធអ្នកដែលស្លាប់អាចទទួលបាន ហើយអ្នកដែលនៅរស់សល់ពីការកាប់សម្លាប់ក៏គេអាចទទួលយកបាន ។ បើនៅសេសសល់ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ មិនយកមកកាត់ទោសឲ្យអស់ទេ គឺកុំកាត់សេចក្តីទាំងអស់គ្នា វាល្អជាង ព្រោះកាត់ខ្លះអត់ខ្លះ វាមិនមានយុត្តិធម៌ទេ ហើយវិញ្ញាណក្ខន្ធអ្នកដែលស្លាប់បាត់ក៏ពុំអាចទទួលបាន ហើយអ្នកដែលនៅរស់សល់ពីការកាប់សម្លាប់ក៏គេពុំអាចទទួលយកបាន ។ ដូច្នេះ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមានចំនួនប៉ុន្មាននាក់ត្រូវរៀបរាប់ឈ្មោះឲ្យអស់កុំឲ្យសល់ ។ រួចចោទប្រកាន់ទាំងអស់យកមកកាត់សេចក្តីទាំងអស់ ទាំងអស់នេះ ជាភារកិច្ចរបស់សហព្រះរាជអាជ្ញា មេធាវីការពារសុំឲ្យសហព្រះរាជអាជ្ញាបំពេញភារកិច្ចនេះឲ្យបានល្អ ។ ម្យ៉ាងទៀត មតិជាតិក៏ដូចជាមតិអន្តរជាតិមួយចំនួន គេមិនបានដឹងថាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមានចំនួនប៉ុន្មាននាក់ ? ហើយមានឈ្មោះអ្វីខ្លះនោះទេ ? ដែលត្រូវយកមកកាត់សេចក្តី ។ ចំពោះមេដឹកនាំកម្ពុជាប្រជាធិបតេយ្យណាដែលបានស្លាប់មុនពេលកាត់សេចក្តីនេះ គឺសុំឲ្យតុលាការចេញសាលក្រមរំលត់បណ្តឹងអាជ្ញា អ្នកដែលត្រូវយកមកដែរគឺជំពូកទីពីរ ។ ជំពូកទីពីរគឺជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ ។ តើអ្នកណាខ្លះជាជនទាំងឡាយដែលទទួលខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ ? អ៊ីចឹង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះមានប៉ុន្មាននាក់ ? ត្រូវយកមកកាត់ទោសឲ្យអស់កុំឲ្យសេសសល់ នោះទើបវិញ្ញាណក្ខន្ធដែលស្លាប់អាចទទួលយកបាន ហើយអ្នកដែលនៅរស់សេសសល់ពីការកាប់សម្លាប់ ក៏គេអាចទទួលយកបាន ។ បើយកមកកាត់សេចក្តីមិនអស់ទេ នៅមានសេសសល់ខ្លះ ដូចខ្ញុំជម្រាបអម្បាញ់មិញ កុំកាត់សេចក្តីទាំងអស់គ្នា វាល្អជាង ព្រោះកាត់ខ្លះអត់ខ្លះ វាមិនមានយុត្តិធម៌ទេ ហើយវិញ្ញាណក្ខន្ធដែលស្លាប់បាត់ក៏គេមិនមកទទួលយក ឯអ្នកដែលនៅរស់សល់ពីការកាប់សម្លាប់ ក៏គេពុំអាចទទួលយកបានដែរ ។

ជារួមបើយកមនុស្សក្រៅពីរជំពូកនេះ មកកាត់សេចក្តី ក៏វិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទទួលយកពុំបាន ហើយអ្នកដែលនៅរស់សល់ពីការកាប់សម្លាប់ ក៏គេទទួលយកពុំបាន ព្រោះច្បាប់ពុំតម្រូវឲ្យមនុស្សក្រៅពីរជំពូកនេះមកធ្វើការកាត់សេចក្តីនោះទេ ។ ម៉្យាងទៀត ការមិនបានកំណត់ឈ្មោះ មិនបានរៀបរាប់ឈ្មោះជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិឲ្យអស់ទេ គឺជាការមួយមិនច្បាស់លាស់ នាំឲ្យមានការសង្ស័យដល់អ្នកដែលធ្លាប់ធ្វើខ្មែរក្រហម នាំឲ្យលេចឮថា ចង់ចាប់នេះទៀត តិចទៅថាចង់ចាប់នោះទៀត ទាំងអស់នេះជាហេតុមួយនាំឲ្យអ្នកដែលធ្លាប់ធ្វើខ្មែរក្រហម នៅមានការព្រួយបារម្ភយ៉ាងខ្លាំង ។

[១៤:០៨:៤៩]

ដូច្នេះ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ផ្សេងៗនោះ ត្រូវរៀបរាប់ឈ្មោះឲ្យអស់តែម្តងកុំឲ្យសល់ រួចត្រូវចោទប្រកាន់ទាំងអស់យកមកកាត់សេចក្តីទាំងអស់ ទាំងអស់នេះ ជាភារកិច្ចរបស់សហព្រះរាជអាជ្ញា តែសហព្រះរាជអាជ្ញាមិនបានបំពេញភារកិច្ចនេះទេ ។ ម៉្យាងទៀត ដូចខ្ញុំជម្រាបអម្បាញ់មិញ មតិជាតិ ក៏ដូចជាមតិអន្តរជាតិ គេមិនបានដឹងថាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះ ចំពោះការរំលោភ និងចំពោះការបំពានច្បាប់ជាតិ និងច្បាប់អន្តរជាតិនោះ វាមានប៉ុន្មាននាក់ ? មានឈ្មោះអីខ្លះដែលត្រូវយកមកកាត់សេចក្តីនោះទេ ។ ចំពោះជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ដែលបានស្លាប់មុនពេលកាត់សេចក្តីនេះ គឺសុំឲ្យចេញសាលក្រមរំលត់បណ្តឹងអាជ្ញា ។

ចំណុចទីបីធំ គឺខ្ញុំជម្រាបអំពីចំនួនមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវបំផុតចំពោះឧក្រិដ្ឋកម្ម និងចំពោះការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងច្បាប់អន្តរ-ជាតិ ។ តើមានចំនួនទាំងអស់ប៉ុន្មាននាក់ ? មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬហៅថាមេខ្មែរក្រហម និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ មានចំនួនទាំងអស់តែដប់បួននាក់គត់ ហើយក្នុងចំណោមដប់បួននាក់នេះ ឥតមានឈ្មោះ កាំង ហ្កេកអ៊ាវ ហៅឌុច ថ្វីដ្បិតតែអម្បាញ់មិញនេះ កាំង ហ្កេក អ៊ាវ ហៅ ឌុច បានទទួលកំហុសរបស់ខ្លួនក៏ពិតមែន តែខ្ញុំជាមេធាវីការពារ ខ្ញុំត្រូវតែស្វែងរកយុត្តិធម៌ជូនវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ក៏ដូចជាអ្នកដែលនៅរស់។ ដូច្នេះ ការយកមនុស្សក្រៅពីដប់បួននាក់នេះមកធ្វើការកាត់សេចក្តីគឺជាការបំពារទៅលើមាត្រា១នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រោះមាត្រា១នៃ

ច្បាប់នេះ ឲ្យកាត់សេចក្តីតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលមានចំនួនតែដប់បួននាក់តែប៉ុណ្ណោះ ។ ម៉្យាងទៀត ការយកមនុស្សក្រៅពីដប់បួននាក់នេះមកធ្វើការកាត់សេចក្តីក៏វិញ្ញាណក្ខន្ធដែលស្លាប់ពុំអាចទទួលយកបាន ហើយអ្នកដែលនៅរស់សល់ពីការកាប់សម្លាប់ ក៏គេពុំអាចទទួលយកបាន ។

ចំណុចទីបួន ការយកកាំង ហ្កេក អ៊ាវ ហៅ ឌុច មកកាត់សេចក្តីតែម្នាក់ឯង តើជាការត្រឹមត្រូវតាមច្បាប់ឬទេ ? យុត្តិធម៌ឬទេ ? ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានគុកទាំងអស់១៩៦គុក ខ្ញុំសុំអនុញ្ញាតកន្លែងហ្នឹង ជម្រាបថា១៩៦គុកហ្នឹង បើតាមខ្ញុំចាំ តាមខ្ញុំមើល ខ្ញុំពិនិត្យមើលទៅ គឺនៅបាត់គុកក្នុងស្រុកបាភ្នំ ខេត្តព្រៃវែងមួយទទេ អត់មាននិយាយ ព្រោះខ្ញុំមេធាវីហ្នឹង វាជាប់គុកនៅកន្លែងហ្នឹង ដល់ខ្ញុំមកមើលហ្នឹង វាបាត់អាស្រុកហ្នឹងតែម្តង បាត់នៅស្រុកបាភ្នំមានប៉ុន្មានគុក គឺបាត់ទាំងអស់ អ៊ីចឹងវាមិនអាចមិនមែន១៩៦ វាអាចដល់២០០គុក ។

មនុស្សដែលគេចាប់បញ្ជូនមកក្នុងគុក មេគុកនីមួយៗមានភារកិច្ចគ្នា ទទួលបញ្ជាពីអង្គការថ្នាក់លើដូចៗគ្នា គឺឲ្យទទួលខុសត្រូវនៅស-២១ ក៏ដូចនៅគុកទូទាំងប្រទេស ឲ្យទទួលខុសត្រូវដូចគ្នា ទីមួយកុំអ្នកដែលគេចាប់មកហើយរត់រួច ទីពីរ អ្នកដែលចាប់យកមកហើយ ត្រូវយកចម្លើយឲ្យបាន រួចអាចម្លើយនោះឲ្យឆ្លើយថាម៉េច ? ធ្វើទារុណកម្មឲ្យឆ្លើយ អ្នកឯងជា *សេ.អ៊ី.អា(CIA)* ឬជា*កា.សេ.បេ (KGB)* ឬក៏ជាកិញ្ជឿន តែបើហ្នឹងគេយកទៅសម្លាប់បានហើយ គុកណាដូចគុកណាម៉ាស្រុកខ្មែរគេឲ្យឆ្លើយអ៊ីចឹងដូចគ្នា អ្នកឯងមិនឆ្លើយគេវាយទល់តែឆ្លើយ តែឆ្លើយបានចម្លើយហ្នឹង គេយកទៅសម្លាប់ដូចគ្នា ។ ចំណុចទីបួន ក្នុងការធ្វើការទារុណកម្មដូចគ្នា កន្លែងណាក៏ដូចកន្លែងណា ធ្វើទារុណកម្មដូចគ្នាក្នុងគុក មិនដែលគុកណាមួយ កន្លែងគេយក ចាប់យកទៅហើយឲ្យយើងសប្បាយទេ ។ ទីមួយគេឲ្យធ្វើ សួរចម្លើយទៅគេឲ្យធ្វើទារុណកម្មតាមបែបត្រជាក់ តាមបែបត្រជាក់អ្នកឯងមិនឆ្លើយ គេធ្វើទារុណកម្មតាមបែបក្តៅ គឺវ៉ៃ។ ទារុណកម្មត្រជាក់ផងក្តៅផង ដែលគេហៅថាទារុណកម្មបែបអង្កៀមតាមរបៀបអង្កៀម ឃើញទេ? នេះជាចំណុចទីបួន ។ ទីប្រាំ កាលណាសួរចម្លើយរួចហើយ ត្រូវកម្ទេចឲ្យបានគេ អត់មានត្រូវការលែង តែចូលគុកហើយត្រូវសម្លាប់ឲ្យគេឲ្យបាន នេះភារកិច្ចទាំងអស់ហ្នឹងគុកណាក៏ដូចជាគុកណាដែរ ។ ដូច្នេះ ចោទប្រកាន់ ឌុច ជាមេគុក ត្រូវចោទប្រកាន់មេគុកទាំង១៩៦ ឬក៏២០០នោះ ហើយជនទាំងឡាយដែលធំជាងមេគុកនោះ មានប៉ុន្មាននាក់ត្រូវចាប់យកមកទាំង

អស់មកកាត់សេចក្ដី ព្រោះត្រឹមគុកគេយកមក អ៊ីចឹង ធំជាងមេគុករឹតតែយកមកទៀត ត្រូវយកមកទាំងអស់អាហ្នឹងទើបស្មើភាពគ្នា ។ ព្រោះមាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ថា ប្រជាពលរដ្ឋខ្មែរមានស្មើភាពគ្នាចំពោះមុខច្បាប់ ឥឡូវស្មើភាពគ្នាទេ ? គុកនីមួយៗទទួលបញ្ជាពីអង្គការតែមួយដូចគ្នា ។ គុកនីមួយៗសុទ្ធមានធ្វើទារុណកម្មដូចគ្នា មានកាប់សម្លាប់ដូចគ្នា ហេតុអ្វីក៏យកតែ ឌុច តែម្នាក់មកកាត់សេចក្ដី ? ឲ្យ ឌុច ទទួលថ្នបាក់តែម្នាក់ឯង ជំនួស១៩៥គុកទៀតនេះឬជាយុត្តិធម៌របស់ អ.វ.ត.ក? ដែលមាន *យូអ៊ិន* ដែលមានអង្គការសហប្រជាជាតិនៅក្នុងនេះដែរ? ដូច្នេះ ការយកតែ ឌុច តែម្នាក់មកកាត់សេចក្ដីដោយពុំយកមេគុកដទៃទៀត ១៩៥គុកទៀតមកកាត់សេចក្ដី គឺជាការសម្រេចមួយផ្ទុយពីខ្លឹមសារជាគោលការណ៍ចម្បងរបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផង ត្រង់មាត្រា៣១ ។ នេះហើយជាការមិនគោរពអធិបតេយ្យភាពជាតិខ្មែរ ពីព្រោះការកាត់សេចក្ដីនេះគេឲ្យគោរពអធិបតេយ្យជាតិខ្មែរ ។ ឥឡូវគោរព ឬហើយនៅ ?

[១៤:១៥:៤៤]

តាមគោរពបំណងទីបីរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺការកាត់សេចក្ដីនេះ គឺថាឲ្យគោរពអ៊ីចឹង នេះឲ្យគោរព ។ ឥឡូវនេះ អធិបតេយ្យជាតិខ្មែរត្រូវបានគេជាន់ឈ្លីចោល ឬមិនជាន់ឈ្លីចោល? បើគេមិនគោរពមាត្រា៣១ យ៉ាងដូច្នេះ ។ រដ្ឋធម្មនុញ្ញជាបណ្ដុំក្បាលរបស់ប្រជារាស្ត្រខ្មែរ ឥឡូវត្រូវគេជាន់ឈ្លីចោល ។ សូមពិចារណា ។

ហេតុនេះមេធាវីការពារមិនអាចទទួលយកបានទេ ។ សូមឲ្យសហព្រះរាជអាជ្ញាមេត្តាពិចារណាសាជាថ្មីលើចំណុចនេះ ។ លោកសហព្រះរាជអាជ្ញាជាអ្នកទទួលបន្ទុកនៃការចោទប្រកាន់នេះ ត្រូវពន្យល់ប្រាប់តុលាការហេតុអ្វីក៏យកតែ ឌុច ម្នាក់មកជំនុំជម្រះ ។ មិនយកមេគុក១៩៥ទៀត មកកាត់សេចក្ដី ហើយមិនយកអ្នកដែលធំជាងមេគុកហ្នឹងមកកាត់សេចក្ដីទាំងអស់ ។ ត្រូវពន្យល់ប្រាប់តុលាការឲ្យបានច្បាស់ មុននឹងយក ឌុច ដាក់គុកត្រូវឲ្យគេអស់ចិត្តគេ ។

ដូច្នេះយកតែ ឌុច ម្នាក់មកកាត់ទោស ។ មកពីថាមាន ឌុច នេះជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងអន្តរជាតិ ? សូមបញ្ជាក់ឲ្យច្បាស់ ។

ដូច្នេះ សហព្រះរាជអាជ្ញាត្រូវពន្យល់តុលាការឲ្យបានច្បាស់ ។ តើ ឌុច ជាមេដឹកនាំជាន់ខ្ពស់ ឬជាមេដឹកនាំខ្ពស់បំផុត? មានឯកសារអីដែលបញ្ជាក់ឲ្យច្បាស់លាស់? រឿងមេធាវីគាត់-- ខ្ញុំមានឯកសារ

ថា ១៤នាក់ ។ ខ្ញុំមាន១៤នាក់ ។ ហើយព្រះរាជអាជ្ញាមានឯកសារអី ដែលថា ឌុច ហ្នឹងដែលត្រូវយកមកកាត់ទោស ? ឬក៏អាដែលថាហ្នឹងចេញតែពីមាត់ ? វាអត់មានច្បាប់អាន ? អាហ្នឹងសូមបញ្ជាក់គ្នាឲ្យច្បាស់ ។

[១៤:១៧:៤៤]

**ទី៥) អំពីគុកទាំង១៩៦**

គុកទាំង១៩៦ នេះ យើងឃើញថា ១៣២ គុកគ្មានតួលេខសម្លាប់ទេ ។ ហើយល្បីដែលសម្លាប់ច្រើន គឺគុកដូចជានៅខេត្តពោធិ៍សាត់ នៅមាច ប៉ុន្តែអត់មានតួលេខ ។ អ៊ីចឹង មានតួលេខតែ៦៤ គុក ទេ ដែលមានតួលេខសម្លាប់ ។ អ៊ីចឹង ក្នុងចំណោម ៦៤ គុក ដោយមានតួលេខបញ្ជាក់ពីចំនួនមនុស្សដែលបានស្លាប់ គឺ ស-២១ ស្ថិតនៅក្នុងលំដាប់លេខ១០ ។ ក្នុងចំណោម៦៤ ហ្នឹង ស-២១ ស្ថិតនៅលំដាប់ថ្នាក់លេខ១០ទេ ។ បើយក ស-២១ ទៅប្រៀបធៀបនឹងគុកចុងជ្រោយ ។ គុកចុងជ្រោយ គឺនៅភូមិឈើត្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ក្នុងគុកហ្នឹង សម្លាប់បានដល់ទៅដប់ប្រាំម៉ឺននាក់ ។ ដប់ប្រាំម៉ឺននាក់ គឺស-២១ គុណនឹងដប់ដងមិនទាន់ស្មើនឹងគុកចុងជ្រោយផង ។ មើលគុកចុងជ្រោយមកទាន់ត្រូវបានយកមកធ្វើការកាត់សេចក្ដីទេ ។ ហេតុអីសូមព្រះរាជអាជ្ញាបញ្ជាក់ប្រាប់តុលាការឲ្យបានច្បាស់?

សូមអនុញ្ញាតបើវង្វង់ក្រចកបន្តិច ដែលខ្ញុំទាមទារនេះ មិនមែនទាមទារឲ្យយកគុកទាំង ១៩៥ មកកាត់ទោសនេះទេ ។ គឺខ្ញុំទាមទារពិចារណារកហេតុផលប្រៀបធៀបដើម្បីធ្វើយ៉ាងណាឲ្យ តាឌុច នេះ គាត់បានរួចខ្លួនដូច១៩៥ មេគុកដែរ ។

សូមចូលមករឿងវិញ ។ សូមមេត្តាពិចារណាថ្លឹងថ្លែងអំពីទំហំព្យសនកម្ម ទំហំនៃការខូចខាត ទំហំនៃការអន្តរាយ ទំហំនៃវិនាសសកម្ម ទំហំនៃឧក្រិដ្ឋកម្ម តើវាខុសប៉ុន្មាន គ្នាប៉ុន្មានរវាងជីវិតមនុស្សមួយម៉ឺនពីរពាន់បីរយប៉ែតសិបនាក់នៅស-២១ និងប្រាំម៉ឺននាក់នៅចុងជ្រោយ? បើគុកចុងជ្រោយសម្លាប់ដប់ប្រាំម៉ឺននាក់ត្រូវបានរួចខ្លួន ។ អ៊ីចឹង នៅស-២១ តែមួយម៉ឺនពីរពាន់ប្រាំបីរយប៉ែតសិបនាក់ត្រូវតែបានរួចខ្លួន ដោយស្វ័យប្រវត្តិដូចមេគុកទាំង១៩៥ ដទៃទៀត ។ ហ្នឹងទើបយុត្តិធម៌ ហ្នឹងទើបនឹងស្របតាមមាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ ។ នែ៎! បើរួចទាំងអស់គ្នាអ៊ីចឹង អាហ្នឹងបានស្មើភាពចំពោះមុខច្បាប់ ។ មេគុកដូចគ្នា ។ គុកនីមួយៗមានសម្លាប់ដូចគ្នា ។ បើរួចខ្លួនត្រូវរួចទាំងអស់គ្នា បើជាប់គុកត្រូវជាប់គុកទាំងអស់ ។ នោះវា

ទើបយុត្តិធម៌ ដែលអាចទទួលយកបាន ។ មេគុកដូចគ្នា ។ នៅក្នុងគុកនោះមានសម្លាប់ដូចគ្នា ។ មេគុក ១៩៥នាក់ ត្រូវរួចខ្លួន ។ វាជាប់តែ ឌុច តែម្នាក់ឯង ។ តើយុត្តិធម៌នៅត្រង់ណា? សូមព្រះរាជអាជ្ញាមេត្តាបញ្ជាក់ឲ្យច្បាស់ជូនតុលាការ ។

[១៤:២០:៥៣]

ម៉្យាងទៀត គោលបំណងទីពីររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងការកាត់សេចក្តីនេះ គឺដើម្បីកុំឲ្យរបបដ៏ឃោរឃៅនេះកើតមាននៅលើទឹកដីកម្ពុជាជាលើកទីពីរ ។ ចុះបើសម្លាប់បានតិចត្រូវជាប់គុក! ឯអ្នកសម្លាប់បានច្រើនត្រូវរួចខ្លួន ។ អ៊ីចឹង បើមានរបបនេះកើតទៀតក៏ត្រូវសម្លាប់ឲ្យបានច្រើនទើបរួចខ្លួន ។ បើសម្លាប់បានតិចមុនជាត្រូវជាប់គុកដូច តាឌុច អ៊ីចឹង ។

ហ៎! តាឌុច ជាប់គុកមកពីស្អី? មកពីគាត់សម្លាប់តិចជាងគេ ។ បើសម្លាប់ច្រើមដូចគេដប់ប្រាំម៉ឺនរួចខ្លួន ។ នេ៎ះជាមេរៀន១ ។ ស-២១ ជាគុកពិសេសដែលនៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនទៅជម្រះថាមានលក្ខណៈពិសេស វាពិសេសត្រង់ហ្នឹង វាពិសេសត្រង់សម្លាប់ជាងគេត្រូវជាប់គុក ។ អាច្រើនរួចខ្លួន អាហ្នឹងពិសេសមែន ។

ដូច្នេះ ការយក ឌុច មកកាត់សេចក្តីតែម្នាក់ឯង ជាការបំពានលើគោលបំណងទីពីររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផង និងជាការបំពានលើមាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផង ។ ហើយជាការបំពានផងដែរ ទៅលើមាត្រា១ នៃច្បាប់ អ.វ.ត.ក ព្រោះ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនមែនជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ។

ចំណុចមួយទៀត ខ្ញុំសូមឆ្លើយ ។ គឺទីប្រាំមួយ គឺឆ្លើយទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងថា កងទ័ពវៀតណាម ប្រជាជនវៀតណាម ដែលគេចាប់បញ្ជូនមកទួលស្លែងនេះ ត្រូវបានស-២១ សម្លាប់អស់ ។ ចោទថាប្រធាន ស-២១ ឧក្រិដ្ឋកម្មសង្គ្រាម ។

សូមតុលាការពិចារណាមើល បាញ់ដូចគ្នា! វៀតណាមចូលមកស្រុកខ្មែរនាពេលនោះ ។ វៀត-ណាមសួរថា តើបើបាចទឹកដាក់គ្នា វាទទឹកទាំងសង្ខាងហើយ? ចុះ! សួរថាទាហានខ្មែរ មានវៀតណាមសម្លាប់ដែរឬទេ? ប្រជាជនខ្មែរ មានវៀតណាមសម្លាប់ដែរឬទេ? បើវាសម្លាប់ដូចតែគ្នាទៅវិញទៅមក ។ ម៉េចក៏វៀតណាមមិនឧក្រិដ្ឋកម្មសង្គ្រាម? វាឧក្រិដ្ឋកម្មឃួនតែ តាឌុច មួយហ្នឹង? នែ៎! ថ្លឹងថ្លែងពិចារណារកយុត្តិធម៌ជូនជនដែលត្រូវចោទ ។

[១៤:២៣:៤២]

**ចំណុចទី៧**

ឃើញថា ឧក្រិដ្ឋកម្មនៅ ស-២១ ឌុច ឥតប្រកែកទេ ។ កំពុងសហការជាមួយតុលាការ ។ អ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង អត់ប្រកែកទេ ស្វាគមន៍ដែពីរយកទាំងអស់ ។ តែបញ្ហាផ្លូវច្បាប់ យក ឌុច មកកាត់សេចក្តី តើវាមានបបញ្ហាជាមួយនឹង ១៩៥ គុកទៀតទេ? បើគេប្រធានគុកដូចគ្នាគេរួចខ្លួននោះ? នេះជាចំណោមមួយដែលត្រូវតែដោះស្រាយ ។

មួយទៀត លោកស្រីខាងព្រះរាជអាជ្ញាបានមានប្រសាសន៍ថា "ការកាត់ក្តីនេះទុកឲ្យមនុស្សជាតិរៀនសូត្រតាម" ។ មនុស្សជាតិនោះមិនមែនតែខ្មែរទាំងអស់មួយពិភពលោកឲ្យរៀនសូត្រតាម ។ ហើយឲ្យរៀនសូត្រតាមកើតដែរៗ ? អ្នកតិចជាប់គុក អ្នកសម្លាប់ច្រើនរួចខ្លួន ។ រៀនសូត្រម៉េចទៅ! នែ៎ សូមឲ្យពិចារណាកន្លែងហ្នឹង ។

ហើយមួយទៀត លោកព្រះរាជអាជ្ញាអន្តរជាតិ លោក រ៉ូប៊ឺត ពេទីត ដែលថាទ្រឹស្តីសហកម្ម ឧក្រិដ្ឋកម្មរួម គួរតែយកមកអនុវត្តនៅទីនេះ យកមកអនុវត្តនៅស-២១ ។ ខ្ញុំអត់មានប្រកែកទេ អនុវត្តចុះ ។ ក៏ប៉ុន្តែត្រូវអនុវត្តទៅគុក១៩៥ ទៀត ។ ពីព្រោះគុក១៩៥ ទៀត ខ្លះសម្លាប់ដប់ប្រាំម៉ឺន ម្ភៃម៉ឺន អាហ្នឹងវាអត់សហកម្មឧក្រិដ្ឋកម្មរួមទេ? រួមអីតែស-២១ មួយ ? សូមពិចារណា ។

អ៊ីចឹង យោងតាមស្មារតី ចំណុចទីបញ្ចប់ហ្នឹង គឺយោងតាមស្មារតីមាត្រា២ នៃច្បាប់ អ.វ.ត.ក គឺសាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះតែមេដឹកនាំជាន់ខ្ពស់ប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិប៉ុណ្ណោះ ។ ឯ កាំង ហ្គេកអ៊ាវ ហៅ ឌុច មិនមែនជាមេដឹកនាំយជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភច្បាប់ទាំងនោះដែរ ។ គឺជាមេគុកដូចមេគុកទាំង១៩៥ ទៀតដែរ ។ ដែលមិនត្រូវបានយកមកកាត់សេចក្តី ។

ជាទីបញ្ចប់ខ្ញុំសង្ឃឹមថា តុលាការក្នុងនាមអង្គការសហប្រជាជាតិនិងក្នុងនាមប្រជារាស្ត្រខ្មែរមិនយក ឌុច មកឲ្យទទួលថ្នបាក់តែម្នាក់ឯង ជំនួសមេគុកទាំង១៩៥ នោះទេ ។

[១៤:២៦:៤៨]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តីអន្តរជាតិ លោក ហ្វ្រង់ ស្វ័រ រូ តើលោកមានការ-- ឆ្លើយតបទៅនឹងបទចោទប្រកាន់ដោយសង្ខេបដោយលើកឡើងដោយសហព្រះរាជអាជ្ញាតពីមេធាវី ការ សាវុត្ត ដែរឬទេ?

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធានប្រសិនបើអង្គជំនុំជម្រះសម្រេចថា សម្រាកឥឡូវនេះ ខ្ញុំមានការរីករាយហើយខ្ញុំនឹងយកវេទិការនេះបន្ទាប់ពីការសម្រាក ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជៀសវាងមានការរអាក់រអួលដោយរាំងស្កាត់ដោយសារសម្រាកនោះ ។ ឥឡូវនេះ យើងប្រកាសសម្រាកសាមសិបមីនុតរហូតដល់ម៉ោងបីខ្វះប្រាំនាទីសូមអញ្ជើញចូលវិញ ។

មានការអីទៅ?

[១៤:២៨:២០]

**លោក រ៉ូប៊ឺត ពើទីត៖**

លោកប្រធានសូមអរគុណដែលអនុញ្ញាតឲ្យខ្ញុំនិយាយ ។ ខ្ញុំសូមជម្រាបតុលាការថា បន្ទាប់ពីសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តី ។ ខ្ញុំសូមធ្វើសេចក្តីសង្កេតមួយចំនួនដែលកើតចេញពីសេចក្តីសន្និដ្ឋានទាំងពីរនោះ ។ ដូច្នេះ ខ្ញុំសូមរក្សាសិទ្ធិធ្វើការសន្និដ្ឋានតបទៅវិញ ។

*[សវនាការសម្រាកពីម៉ោង១៤:២៨នាទី ដល់ម៉ោង ១៤:៥៧នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមអញ្ជើញលោកមេធាវីការពារក្តីលោក ហ្រ្វង់ស្វ័រ រូ ឡើងធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានសង្ខេបដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា តពីលោកមេធាវី ការ សាវុត្ថ ។ សូមអញ្ជើញ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ លោក លោកស្រីចៅក្រមជាទីគោរព! ដូចដែលលំដាប់មកដល់ខ្ញុំនោះ ខ្ញុំបានដឹងថា អំពីសារសំខាន់នៃខណៈពេលដែលខ្ញុំទទួលបាន ដែលខ្ញុំនឹងពណ៌នាថាជាហេតុការណ៍ប្រវត្តិសាស្ត្រមួយ មិនមែនជាប្រវត្តិសាស្ត្រចំពោះកម្ពុជាតែមួយប៉ុណ្ណោះទេ ហើយនិងជនរងគ្រោះនៃសោកនាដកម្មប៉ុណ្ណោះទេ ប៉ុន្តែចំពោះសហគមន៍អន្តរជាតិក៏ដូច្នោះដែរ ។ ហើយក្នុងវិស័យយុត្តិធម៌

ព្រហ្មទណ្ឌអន្តរជាតិនោះផងដែរ ដែលក្នុងន័យនេះយើងត្រូវស្វែងរកឲ្យឃើញនូវយុត្តិធម៌ដែលថា តុលាការនេះធ្វើសវនាការ ហើយនៅទីនេះនៅភ្នំពេញ ដែលធ្វើសវនាការក្នុងរឿងក្តីរបស់ ឌុច ។ ហើយសវនាការនេះនឹងផ្តល់វិភាគទានមួយទៅដល់វិស័យព្រហ្មទណ្ឌអន្តរជាតិ ។

ពេលវេលាដ៏សមស្របនៃការស្វែងរកយុត្តិធម៌បែបនេះ ឬក៏យុត្តិធម៌នេះដែលថា ក្នុងពេលថ្មីៗ ឬក៏ជាដំណឹងដែលយើងបានដឹង រំឭកឲ្យយើងដឹងថា គឺជាការងារមួយដ៏លំបាក ។ ថ្ងៃនេះយើងបានធ្វើសវនាការ ប្រមុខរដ្ឋមួយត្រូវបានកោះ ចេញដីកាកោះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយប្រមុខរដ្ឋមួយនោះត្រូវបានបដិសេធទៅនឹងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ការបដិសេធចំពោះប្រព័ន្ធយុត្តិធម៌អន្តរជាតិនោះ ក៏បានកើតនៅទីនោះដែរ ។

នៅទីនេះក្នុងប្រទេសកម្ពុជា លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំបានឈរនៅទីនេះនៅចំពោះលោក លោកស្រីនៅទីនេះ ខ្ញុំមានសេចក្តីរីករាយណាស់ដែលថាទោះបីជាមានការលំបាក ឬក៏ឧបសគ្គទាំងឡាយដែលមានមុនពេលការបង្កើតតុលាការនេះក៏ដោយ ។ ខ្ញុំមានសេចក្តីរីករាយណាស់ថ្ងៃនេះ លោក លោកស្រីបាននៅទីនេះ ហើយឌុច ក៏បាននៅទីនេះដែរ ដែលគាត់បានអង្គុយនៅចំពោះមុខ លោក លោកស្រីចៅក្រម ។ ជនរងគ្រោះក៏បាននៅទីនេះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាងរបស់គេ ។ នៅក្នុងសវនាការខ្លួនឯងនេះ យើងក៏បានពិនិត្យឃើញដែរ ហើយខ្ញុំក៏បានគាំទ្រ ហើយនិងសេចក្តីប្រកាសរួមរបស់ទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជានៅថ្ងៃទី៣០ ខែមីនា ដែលចែងថា នៅថ្ងៃទី៣០ ខែមីនា គឺជារបត់ថ្មីដ៏សំខាន់មួយឆ្ពោះទៅរកការជោគជ័យនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនឯងក្នុងការជំនុំជម្រះរឿងក្តីឌុច ហើយនិងអតីតមេដឹកនាំខ្មែរក្រហម ។

សេចក្តីប្រកាសរួមនោះ បានប្រកាសថា ការជោគជ័យ គឺឆ្លុះបញ្ចាំងពីភាពជាដៃគូរវាងអង្គការសហប្រជាជាតិ ហើយនិងរដ្ឋាភិបាលកម្ពុជា ។ កម្ពុជាជារដ្ឋសមាជិកមួយនៃអង្គការសហប្រជាជាតិ ដោយហេតុថា កម្ពុជាបានឯកភាពថាឲ្យយើងមានអង្គជំនុំជម្រះមួយនាថ្ងៃនេះ ហើយមិនមានអ្វីខុសគ្នានោះទេរវាងចៅក្រមជាតិ ហើយនិងចៅក្រមអន្តរជាតិ ដែលកំពុងវត្តមានក្នុងសវនាការនេះ ហើយក៏មិនមានភាពខុសគ្នារវាងមេធាវីការពារជាតិនិងអន្តរជាតិ ហើយនិងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិនោះដែរ ។ នៅក្នុងសាលសវនាការនេះ អ្វីដែលយើងមានទាំងអស់គ្នានៅទីនេះ គឺចៅក្រមទាំងឡាយ ហើយនិងមន្ត្រីតុលាការ ដែលជាអ្នកធ្វើការដើម្បីធានាឲ្យមានយុត្តិធម៌ ហើយយុត្តិធម៌ត្រូវបានរកឃើញ។

លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រមជាទីគោរព! លោកសហព្រះរាជអាជ្ញានៅក្នុងសេចក្តីសន្និដ្ឋានបើករបស់ខ្លួន បានពឹងផ្អែកយ៉ាងសំខាន់ទៅលើឯកសារទាំងឡាយដែលបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ ហើយអស់លោក លោកស្រីអាចនឹងពិនិត្យឃើញថា ដែលថា ភាគច្រើននៃឯកសារទាំងអស់នោះ ឌុច គឺបានឯកភាព ។ ដំណាក់កាលទៅមុខទៀត នៅក្នុងរឿងក្តីនេះយើងនឹងពិនិត្យមើលទាក់ទងទៅនឹងការទទួលស្គាល់ពីការកើតឡើងនៃអង្គហេតុដោយជនជាប់ចោទ ពេលនោះលោក លោកស្រីចៅក្រមនឹងកត់សម្គាល់ថា អង្គហេតុភាគច្រើនបំផុតដែលដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយនោះ គឺជាកម្មវត្ថុដែលជនជាប់ចោទបានឯកភាព ។ ដូច្នេះ លោក រូបឺតពេទីត នៅពេលដែលលោកបានបញ្ចប់នៅក្នុងសេចក្តីសន្និដ្ឋានបើករបស់គាត់ គាត់បញ្ជាក់ថា តាមពិតលោក លោកស្រីចៅក្រមនៅទីបំផុតនោះនៃដំណាក់កាលនីតិវិធីនេះ លោក លោកស្រីចៅក្រមនឹងចេញនូវសេចក្តីសម្រេចដើម្បីកំណត់ ថាតើការទទួលស្គាល់បទឧក្រិដ្ឋដោយជនជាប់ចោទ គឺពិតជាការសារភាពដ៏ស្មោះត្រង់ ឬក៏ជាការសារភាពដែលស្របគ្នាជាមួយនឹងភារកិច្ចដែលគាត់ពិតជាបានអនុវត្ត ។ ចំណុចនោះតាមពិតវានឹងមានលក្ខណៈថាជាចំណុចមួយដែលថា ដំណើរការនីតិវិធីជាសាធារណៈនេះនឹងបង្ហាញឲ្យឃើញច្បាស់ ពោលគឺតើកម្រិតនៃស្វ័យភាពប៉ុនណា តើកង្វះស្វ័យភាពប៉ុនណាដែល ឌុច មិនមាននៅក្នុងភារកិច្ចរបស់គាត់ក្នុងឋានៈជាប្រធាននៃស-២១ ។ ហើយនៅពេលដែលយើងបានពិនិត្យមើលចំណុចនោះ យើងនឹងប្រាកដជាបានស្តាប់មតិរបស់អ្នកជំនាញ យើងខ្ញុំបានស្នើអ្នកជំនាញមួយចំនួនជូនអង្គជំនុំជម្រះ ហើយសហព្រះរាជអាជ្ញាក៏បានស្នើអ្នកជំនាញរបស់ខ្លួនដែរ ហើយយើងក៏មានបំណងនឹងស្តាប់មតិអស់អ្នកទាំងនោះ តាមទស្សនៈរបស់ខ្ញុំគឺមានធាតុផ្សំដ៏សំខាន់មួយដែលមិនមាន នៅក្នុងសេចក្តីសន្និដ្ឋានមួយរបស់សហព្រះរាជអាជ្ញា ឬក៏ខ្វះចំណុចពីរ ដែលមិនបានបញ្ជាក់អំពីអំពើរន្ធត់ ឬក៏ភាពសម្ងាត់ ហើយយើងក៏បានឯកភាពដែរថា ភាពផ្តាច់ការ អំណាចផ្តាច់ការមួយនេះដែលបានធ្វើប្រតិបត្តិការក្នុងរវាងចំណុចមួយដែលថា ជាអំពើភ័យរន្ធត់ ហើយនិងការសម្ងាត់ គឺដោយសារភាពរន្ធត់ដែលវាមានផ្សារភ្ជាប់ទំនាក់ទំនងអំពីខ្សែរយៈនៃការបញ្ជា ដែលធ្វើឡើងដើម្បីបំពេញទៅតាមសេចក្តីពេញចិត្តរបស់ថ្នាក់លើដែលជាអ្នកចេញបញ្ជាទាំងនោះ ។ នេះហើយជាមូលហេតុដែលថា ឌុច ជម្រាបជូនលោក លោកស្រីចៅក្រម ហើយបានជម្រាបជូនលោកសហចៅក្រមស៊ើបអង្កេត គឺជាខ្ញុំដែលជាអ្នកបានបញ្ជាទៅឲ្យអ្នកក្រោមបង្គាប់របស់ខ្ញុំ ខ្ញុំទទួលការខុសត្រូវក្នុងរឿងហ្នឹង ។ ហើយខ្ញុំសូមជម្រាបលោក លោកស្រីចៅក្រមថា មិនមែនមានមនុស្សច្រើនប៉ុន្មានទេ ដែលនៅក្នុងប្រទេសនេះថ្ងៃនេះ ដែល

នឹងទទួលស្គាល់ថា ពួកគេខ្លួនឯងជាអ្នកបានផ្តល់បញ្ជា ប្រគល់បញ្ជារបស់ខ្លួនទៅឲ្យអ្នកដទៃ ។ តើចំណុចនេះមានន័យដែរឬទេថា យើងត្រូវពិនិត្យមើលភាពស្ងប់ស្ងាត់នៅក្នុងអង្គហេតុមួយដែលថា គាត់តាមពិតគាត់បានទទួលបញ្ជា ។ អ្វីដែលយើងបានឯកភាពថា កើតមានឡើងនៅខាងក្រោមគាត់ គឺកើតឡើងដូចគ្នាពីខាងលើគាត់នោះដែរ។

ប៉ុន្តែគាត់បាននិយាយថា ខ្ញុំបានទទួលបញ្ជាទាំងឡាយ ខ្ញុំបានបញ្ជូនបញ្ជាទាំងនោះ ខ្ញុំទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានកើតឡើងនោះ ។ យើងនឹងត្រឡប់ទៅរកបញ្ហាមួយដែលថា ជាការបញ្ជាដែលមិនមែនជាធាតុផ្សំដោះបន្ទុកនោះទេ ប៉ុន្តែ ដោយហេតុថាអង្គជំនុំជម្រះនៅ *នូរឹមប៊ឺក* នោះបានចាត់ថា ជាស្ថានសម្រាលទៅវិញ ។ លោកសហព្រះរាជអាជ្ញានៃការិយាល័យសហព្រះរាជអាជ្ញា និងបានធ្វើកិច្ចការល្អ ដែលបានយកទៅដែលយោងទៅរកសារព័ត៌មាន*កាដែត* ឈ្មោះលោក *សាកឡង់តូ* នៅខែមីនា ឆ្នាំ២០០៨នោះ ។ ដូច្នេះ យើងបានស្តាប់មតិសន្និដ្ឋាន របស់ការិយាល័យសហព្រះរាជអាជ្ញាពីបញ្ហានេះ ហើយលោកព្រះរាជអាជ្ញា លោកមេធាវី សហមេធាវីរបស់ខ្ញុំ ការ សាវុត្ថ ក៏បានបញ្ជាក់ផងដែរថា សូមអនុញ្ញាតឲ្យខ្ញុំនិយាយជាសាធារណៈ ថាតើខ្ញុំមានការគោរពកម្រិតខ្ពស់ប៉ុនណា ចំពោះលោក ការ សាវុត្ថ ដែលគាត់ក៏ជាអតីតអ្នកទោសរបស់ខ្មែរក្រហមនោះដែរ ហើយគាត់ក៏បានការពារកូនក្តីរបស់គាត់ម្នាក់ ហើយគាត់ប្រកាន់អាជីពរបស់គាត់ដ៏ល្អ ។ លោក ការ សាវុត្ថ តាំងពីចាប់ផ្តើមនៃទសវត្សរ៍ទី៨០មក នៅពេលដែលគាត់បានធ្វើជាគ្រូបង្រៀន គាត់បានយកកូនសិស្សរបស់គាត់មួយចំនួនទៅធ្វើទស្សនកិច្ចនៅស-២១ ថាតើគាត់អាចស្រមៃឃើញទេ ថាតើថាថ្ងៃមួយគាត់នឹងក្លាយទៅជាមេធាវីដែលការពារ ឬក៏តំណាង ឬក៏តំណាងឲ្យប្រធាននៃស-២១នោះ ។ ជោគវាសនាមួយនេះ គឺវាមានលក្ខណៈជាចរិតលក្ខណៈដែលបានកើតមានឡើងជាក់ស្តែងនៅទីនេះនោះឯង ។ ដូចដែលគាត់បានជម្រាបជូន លោក លោកស្រីចៅក្រម ដែលថា លោកសហព្រះអាជ្ញា លោកស្រីសហព្រះរាជអាជ្ញា បានលើកឡើងជូនលោកសហព្រះរាជអាជ្ញានោះគឺថា គឺមានតែអ្នកដឹកនាំខ្ពស់បំផុតដែលនឹងត្រូវជំនុំជម្រះ ហើយលោក ការ សាវុត្ថ នោះបានបញ្ជាក់ថា សូមកុំឲ្យចាត់ទុក លោក ឌុច ជាអ្នកទទួលថ្នាក់ក្នុងរឿងក្តីនេះ ។ ហើយក្នុងករណីនោះ លោក លោកស្រីចៅក្រម ឬយើងទាំងអស់គ្នាបានស្តាប់ហើយថា ឌុចគាត់បានជម្រាបជូនតុលាការ ។ ខ្ញុំសូមអរគុណអង្គជំនុំជម្រះដែលអនុញ្ញាតឲ្យខ្ញុំបានចូលរួមក្នុងដំណាក់-កាលជំនុំជម្រះនេះ ។ លោក លោកស្រីចៅក្រម ត្រូវតែជឿខ្ញុំគឺថា គឺមិនមែនជាការងាយស្រួលនោះទេដើម្បីឲ្យយើងជួបគ្នាទីនេះជាសាធារណៈក្នុងសាលសវនាការប្រឈមមុខជាមួយជនរងគ្រោះ ហើយនិង

សាធារណជន ដែលមកកាន់ទីនេះ ដើម្បីនិយាយបញ្ជាក់ថា ខ្ញុំទទួលស្គាល់ ខ្ញុំមានការខ្មាស់អៀននឹងអ្វីដែលខ្ញុំបានធ្វើ តើលោកគិតឃើញទេ ថាតើ គឺជាការសាមញ្ញដែលគាត់អាចធ្វើបានដូចដែលគាត់និយាយនោះដែរឬទេ? គឺជាផ្លូវមួយដ៏វែង ដែលយើងត្រូវធ្វើដំណើរ គឺជាផ្លូវមួយដ៏វែងឆ្ងាយដែលត្រូវធ្វើដំណើរម្នាក់ឯងក្នុងរយៈពេលជាច្រើនឆ្នាំ ។ នេះហើយ ជាគំនិតដែលខ្ញុំបានពិនិត្យ ខ្ញុំយល់ពីគំនិតគាត់តាំងពីការជួបគ្នាដំបូង ។ គាត់បាននិយាយមកខ្ញុំថា គាត់បាននិយាយថា ខ្ញុំទទួលស្គាល់ ខ្ញុំមានបំណងនឹងទទួលស្គាល់ ហើយនិងនិយាយជម្រាបជូនចៅក្រមទាំងឡាយ ខ្ញុំចង់និយាយចំពោះមុខជនរងគ្រោះ ។

[១៥:១៥:១៤]

ដោយមានការឯកភាពយល់ព្រមពីគាត់ យើងក៏បានអនុវត្តធ្វើការសម្តែងឡើងវិញ ចំពោះអស់លោក លោកស្រី ដែលមិនថិតនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡទេ ។ ការសម្តែងឡើងវិញ នៅក្នុងរឿងក្តីគឺជាករណីដែលចាំបាច់ ដែលត្រូវលើកឡើងនៅក្នុងដំណើរការរឿងក្តី ប៉ុន្តែក្នុងករណីនេះ គឺជានីតិវិធីដ៏ចម្បងមួយ ថាតើអ្នកណាដែលអាចនឹងនឹកឃើញថា ឌុច ជាអតីតប្រធាន ឬក៏មេដឹកនាំនៃស-២១ នឹងត្រឡប់មកស-២១វិញ ដើម្បីប្រឈមមុខទៅនឹងអ្នកយាមទាំងអស់ដែលរួចរស់ជីវិតនៅក្នុងចន្លោះនគរបាលពីររូប ហើយនិងសហចៅក្រមស៊ើបអង្កេតពីររូប តើអ្នកណាអាចគិតថារឿងហ្នឹងនឹងកើតមានបាននោះ ?

តាមសំណើរបស់មេធាវី គាត់បានឯកភាព ហើយគាត់ក៏បានប្រាប់មកយើងថា គាត់បានថា បាទ ខ្ញុំនឹងទៅជើងឯកជាមួយលោកចៅក្រម ហើយនិងសហព្រះរាជអាជ្ញា ។ បាទ ខ្ញុំនឹងទៅស-២១ ប៉ុន្តែខ្ញុំស្នើចំណុចពីរ ។ ទីមួយ ខ្ញុំសូមអនុញ្ញាតសុំពេលខ្លះសម្រាប់ខ្លួនឯងផ្ទាល់ បើមិនមានអ្នកណានឹងបង្ហាញនូវទស្សនៈអ្វីៗនោះទេ ហើយសហចៅក្រមស៊ើបអង្កេតក៏បានអនុញ្ញាតឲ្យគាត់ថិតនៅម្នាក់ឯងក្នុងរយៈពេលមួយ ហើយគាត់ក៏បាននិយាយតទៅទៀតថា ខ្ញុំសុំឲ្យផ្តល់សិទ្ធិដើម្បីខ្ញុំនិយាយទៅជនរងគ្រោះនៅពេលដែលគេវត្តមាន ជាពិសេស ជាអតីតអ្នកយាម ហើយនិងជនរងគ្រោះនៅស-២១ ។

ឥឡូវនេះ លោក លោកស្រីចៅក្រមនឹងពិនិត្យឃើញហើយថាជនរងគ្រោះដែលថា មិនបានវត្តមាននៅក្នុងការសម្តែងឡើងវិញនោះទេ ក្នុងដំណើរការនីតិវិធីនេះ លោក លោកស្រីចៅក្រមនឹងបានពិនិត្យឃើញនូវខ្សែភាពយន្តដែលបានថតពីការសម្តែងនេះឡើងវិញ ។ ហើយយើងនឹងមានឱកាសក្នុងការពិនិត្យមើលនៅក្នុងដំណាក់កាលដែលបានអនុវត្តជាជំហានៗ ។ ដោយឃើញថា មានទឹកភ្នែកដែល

ឯកសារដើម

បានស្រក់នៅចំពោះមុខ ឌុច ហើយនិងជនរងគ្រោះដែលបាននិយាយគ្នាទៅវិញទៅមកដែលថា នៅពេលនោះមិនមានអ្នកណាម្នាក់ គឺស្មោះត្រង់ ហើយក៏នេះជាទិដ្ឋភាពមួយ ដែលគឺជាគុណប្រយោជន៍ដ៏ចម្បងនៃដំណើរការនីតិវិធីច្បាប់ ។ ថាតើអ្វីដែលមានកំពស់ខ្ពស់ជាងយុត្តិធម៌ ដែលថានីតិវិធីផ្លូវច្បាប់អ្វីដែលអាចប្រសើជាងនេះ ដែលធ្វើឲ្យ ឌុច ហើយនិងអតីតអ្នកក្រោមបង្គាប់ជាជនរងគ្រោះជួបគ្នាបាននោះ ។

មិនថាអ្វីគឺជាភាពសោកសៅដូចដែលលោកបានលើកឡើង ។ សហព្រះរាជអាជ្ញាបានលើកឡើងព្រឹកនេះគឺភាពសោកសៅដែលជាការពិតទៅកើតឡើងចំពោះជនរងគ្រោះដែលស្លូតត្រង់មិនថាការសោកសៅនោះយ៉ាងម៉េចទេនោះ ។ សាមសិបឆ្នាំក្រោយមក ខ្ញុំចង់ឲ្យយើងគិតថា បុគ្គលម្នាក់នៅថ្ងៃនេះ គាត់ប្រឈមមុខនៅទីនេះ ខ្ញុំសូមនិយាយឡើងវិញ វាមានភាពចាំបាច់ក្នុងការមានភាពក្លាហានមួយ ហើយយើងត្រូវតែធ្វើឲ្យបានចំពោះភាពក្លាហាននេះ ។ អ្វីដែលអនុញ្ញាតឲ្យបុរសមួយរូបដែលគាត់ប្រឈមមុខនឹងបញ្ហាទាំងអស់នេះ អ្វីដែលអនុញ្ញាតឲ្យគាត់ធ្វើដូច្នេះ មិនមែនគាត់មានភាពជឿជាក់ថា គាត់មានតួនាទីយ៉ាងសំខាន់នៅក្នុងមនុស្សធម៌ប៉ុណ្ណោះទេ គឺគាត់សុំឲ្យមានការអភ័យទោសពីជនរងគ្រោះ ហើយគាត់ថ្លែងសេចក្តីថ្លែង ចំពោះប្រជាជន ហើយគាត់ធ្វើសេចក្តីថ្លែងជូនប្រជាជនជំនាន់ក្រោយថា អានេះគឺអ្វីដែលពួកយើងបានធ្វើ អ្វីដែលយើងធ្លាក់ចូលទៅក្នុងរណ្តៅនេះ ចំណុចនេះគឺ អ្វីដែលយើងមិនគួរដើរតាមគន្លងនេះឡើយ ។ ដូច្នេះ ជាការពិតណាស់ លោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញាជាទីគោរព! ក្នុងនាមជាមនុស្សធម៌ គឺយើងមានចំណុចមួយដែលវាជាបញ្ហា ហើយគាត់ទទួលស្គាល់ទៅលើចំណុចមួយចំនួន ។ ជាការពិតណាស់ ប្រហែលជាយើងទាំងអស់គ្នាផងដែរ យើងមានបញ្ហាមួយចំនួនទើបយើងសារភាពក្នុងនាមរបស់យើង ។ សវនាការនេះប្រហែលជាបង្ហាញថា យើងក៏មានតួនាទីណាមួយនៅក្នុងអង្គជំនុំជម្រះនេះ យើងចង់បង្ហាញអំពីសៀវភៅដែល ឌុច សរសេរ គឺជាការងាររបស់គាត់ទាំងអស់នៅក្នុងសៀវភៅនោះ ។ យើងនឹងយល់អំពីការងារទាំងអស់នោះ គឺគាត់មិនមែនសរសេរសៀវភៅទាំងអស់នោះទេ គឺថាមានគេផ្សេង អ៊ីចឹង យើងអាចយល់ខុសទៅលើបញ្ហាមួយចំនួន អ៊ីចឹងយើងអាច គឺយើងក៏អាចមានបញ្ហាក្នុងការទទួលស្គាល់បញ្ហាមួយចំនួន ដែលវាមានភាពឈឺចាប់ចំពោះយើងទាំងអស់គ្នា ។

ដូច្នេះ ខ្ញុំសូមលើកឡើងម្តងទៀតសាជាថ្មី សវនាការមួយនេះ គឺនឹងអនុញ្ញាតឲ្យយើងពិចារណាបានជ្រៅជាងនេះ ។ យើងមានឱកាសនៅក្នុងតុលាការនេះជាលើកទីមួយ នៅចំពោះមុខយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ដែលយើងមានដើមបណ្តឹងរដ្ឋប្បវេណីចូលរួម ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី

លោកមានតួនាទីនៅក្នុងសវនាការនេះ ។ លោក លោកស្រី នឹងសួរសំណួរទៅកាន់ ឌុច ដែលលោក លោកស្រី ចង់ចោទសួរ ហើយដូចដែលរដ្ឋមន្ត្រីបានលើកឡើង គឺវាជាកិត្តិយសណាស់ក្នុងការស្វែងរកយុត្តិធម៌នៅទីនេះ ដែលយើងអនុញ្ញាតឲ្យមានការអនុវត្តនូវដំណើរការនីតិវិធីនៅទីនេះ ។

[១៥:២៣:៣២]

ជាអកុសល ខ្ញុំសូមធ្វើការបញ្ជាក់ថា សំណួរទាំងអស់ហ្នឹងមិនត្រូវបានទទួលចម្លើយគ្រប់បែបយ៉ាងនោះទេ គឺខ្ញុំដឹងទៅលើបញ្ហាហ្នឹង ហើយលោក លោកស្រី នឹងដឹងទៅលើចំណុចនេះ ។ ហេតុអ្វីបានជាយើងមិនឆ្លើយសំណួរទាំងអស់នោះ ? ខ្ញុំមិនប្រាកដនោះទេ ដែលថា ឌុច ខ្លួនឯងគាត់មានចម្លើយចំពោះសំណួរទាំងអស់ ហើយសំណួរដែលមានលក្ខណៈបត់បែន ដែលវានឹកស្មានមិនដល់ ហើយយើងមិនអាចទ្រាំបាននៅមន្ទីរស-២១ ។ ហេតុអ្វីបានជាទីកន្លែងទាំងអស់នោះ គឺធ្វើអំពើទៅលើជនរងគ្រោះ ហើយបុគ្គលទាំងអស់នោះរងគ្រោះនៅពេលនោះ ហើយគឺថានរណាគេដែលគាត់ប្រព្រឹត្តអំពើដ៏សាហាវទាំងអស់នេះ ថាតើយើងអាចនៅពេលបញ្ចប់សវនាការនេះ តើយើងអាចផ្តល់ជូនជនរងគ្រោះនូវមនុស្សជាតិទាំងអស់ដែរឬទេ? យើងអាចអនុញ្ញាតឲ្យបុគ្គលទាំងឡាយឬក៏បុគ្គលគ្រប់ទាំងអស់ដែលគាត់ទទួលបានមនុស្សធម៌ ត្រូវតែទទួលបានមនុស្សធម៌ ។ នេះគឺជាដំណាក់កាលនៃនីតិវិធីយើង ដែលយើងត្រូវឲ្យមាននៅក្នុងដំណើរការតុលាការរបស់យើងនៅទីនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបថា កាលដែលសហព្រះរាជអាជ្ញាស្នើសុំធ្វើការកត់សម្គាល់តបទៅនឹងសេចក្តីសន្និដ្ឋាន តបដោយសង្ខេបរបស់មេធាវីការពារក្តីនោះ អង្គជំនុំជម្រះមិនអនុញ្ញាតតាមការស្នើសុំទេ ដោយហេតុផ្អែកតាមខ្លឹមសារនៃវិធាន៨៩ ស្ទួន២ និងសេចក្តីណែនាំស្តីពីកម្មវិធីសវនាជំនុំជម្រះរបស់អង្គជម្រះ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ពេលនេះវាមិនមែនកិច្ចដំណើរការសវនាការដេញដោលពិនិត្យភស្តុតាងនោះទេ ។ វាគ្រាន់តែជាដំណាក់កាលមួយនៃការផ្តើមសួរសេចក្តីថ្លែងបើកសវនាការតែប៉ុណ្ណោះ ។

ជាកិច្ចបន្ត ដល់ចំណុចមួយទៀតអំពីការ អង្គហេតុដែលមានការព្រមព្រៀង ដល់ចំណុចនេះអង្គជម្រះសុំសួរទៅសហព្រះរាជអាជ្ញាថា តើមានអង្គហេតុបានព្រមព្រៀងគ្នារវាងសហព្រះរាជអាជ្ញា និងមេធាវីការពារជនជាប់ចោទដែរឬទេ?

**លោក រ៉ូប៊ឺត ពេទីត៖**

អរគុណលោកប្រធាន ។ ដោយការអនុញ្ញាតរបស់លោកចៅក្រម ខ្ញុំសូមធ្វើការកែប្រែទៅលើយោបល់របស់ខ្ញុំ គឺខ្ញុំសូមមិនធ្វើសិទ្ធិឆ្លើយតបទេ ចំពោះសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី ។ អ្វីដែលខ្ញុំស្នើសុំ គឺសិទ្ធិក្នុងការធ្វើសេចក្ដីសង្កេត ។ អ្វីដែលខ្ញុំជឿថា លើកឡើងមុននេះគឺ ការបង្ហាញ ឬក៏សេចក្ដីបង្ហាញ ឬក៏ញត្តិរបស់សហមេធាវីការពារក្ដី ដែលតតាំងទៅនឹងយុត្តាធិការរបស់តុលាការ ឬក៏ទៅជនជាប់ចោទ ហើយនិងបញ្ហាធម្មនុញ្ញភាពរបស់តុលាការនេះ ។ ហើយគឺបានលើកឡើងថា វាផ្ទុយទៅនឹងអធិបតេយ្យភាពរបស់ប្រទេសនេះ ។ វប្បធម៌របស់ខ្ញុំ ដែលខ្ញុំលើកឡើងនៅទីនេះ គឺយើងសន្និដ្ឋានថា--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានបដិសេធមិនទទួលសូមណ្ឌមពរនេះហើយ អ៊ីចឹងឲ្យចូលទៅបញ្ហាអំពីអង្គហេតុដែលបានព្រមព្រៀង ។ សូមលោកសហព្រះរាជអាជ្ញាយល់ឲ្យបានច្បាស់ ហើយចាប់ផ្ដើមតាំងពីចំណុចទៅ ។

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណ ហើយខ្ញុំបានឃើញអំពីការដាក់កំណត់របៀបវារៈ ហើយខ្ញុំនឹងត្រឡប់ទៅលើចំណុចទាំងអស់នេះវិញ ។ ជាការពិតយើងមានការព្រមព្រៀងគ្នា ប្រសិនជាអនុញ្ញាតឲ្យខ្ញុំលើកឡើង ឆ្លើយតបទៅនឹងសំណើរបស់លោកចៅក្រមនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩ គឺសហព្រះរាជអាជ្ញានៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ ។ យើងមានបញ្ហាបច្ចេកទេស ។

ខ្ញុំសូមអភ័យទោស ដោយសារតែខ្ញុំដាក់កាស់ស្ដាប់ត្រចៀករបស់ខ្ញុំជិតមីក្រូហ្វូន ។ ដូចដែលខ្ញុំលើកឡើងថ្ងៃ១១ ខែកុម្ភៈ ឆ្នាំ២០០៩ គឺយើងបានផ្ដល់ខាងសហមេធាវីទៅលើការវិភាគទៅលើការចោទប្រកាន់ចំនួន៣៥១ចំណុច ដែលវាបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានការកែប្រែដោយអង្គបុរេជំនុំជម្រះ ។ យើងបានផ្ដល់អង្គហេតុទាំងនេះជាភាសាខ្មែរ អង់គ្លេស និងបារាំង ។ ផ្នែកទីមួយ គឺបានលើកឡើងអំពីសេចក្ដីសង្ខេបទៅលើអង្គហេតុ ។ ផ្នែកទីពីរ គឺអំពីលក្ខណៈនៃច្បាប់ អំពីអង្គហេតុ ហើយទីបី គឺអត្តចរិតរបស់ជនជាប់ចោទ ។

នៅពេលដែលយើងនិយាយថា អង្គហេតុទាំងអស់លេចចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺអង្គហេតុគឺបានដកពាក្យតែម្ដង គ្រប់ពាក្យគ្រប់បែបយ៉ាងពីដីកាដំណោះស្រាយ ។ ហើយនៅក្នុងករណីមួយចំនួន គឺយើងបានដកបញ្ចេញនូវសេចក្ដីយោងទៅលើភស្តុតាង ហើយយើងដកចំណុចមួយចំនួន

ដែលសហព្រះរាជអាជ្ញាមិនស្រប ហើយនិងមានការការប្រែបន្តិចបន្តួចទៅលើចំណុចទាំងអស់នោះ ។ លោក លោកស្រីចៅក្រម នឹងកត់សម្គាល់ឃើញថា លើកលែងតែមានភាពវិជ្ជមានមួយចំនួននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ គឺដីកានេះគឺមាន១៧១ចំណុច ហើយ១៥៦ចំណុចបានដាក់ជូនសហមេធាវីការពារក្តី ហើយកថាខណ្ឌនីមួយៗ រួមមានអង្គហេតុជាច្រើន ។ ហើយពេលខ្លះមានអង្គហេតុច្រើនមែនទែន ។ ដូច្នេះ កថាខណ្ឌទាំងអស់នោះ គឺយើងបានធ្វើការបែងចែកទៅជាការចោទប្រកាន់ទៅលើការវិភាគចំណុចទាំងអស់នេះ ដើម្បីឲ្យសហមេធាវីការពារក្តីធ្វើការឆ្លើយតបការចោទប្រកាន់ដែលបានវិភាគទាំងអស់នោះ ។

អង្គហេតុដែលបានព្រមព្រៀង ដែលយើងស្នើឡើងហើយខ្ញុំបានដាក់ជូនខាងមេធាវីការពារក្តីជាបីភាសា ។ ហើយខាងសហមេធាវី គាត់បានកត់សម្គាល់ថា តើគាត់បានយល់ស្របទាំងស្រុងយល់ស្របខ្លះ ឬក៏គាត់បានជំទាស់ដែលឬទេចំពោះអង្គហេតុទាំងអស់នោះ ? មេធាវីការពារបានបញ្ជូនមក ហើយសហព្រះរាជអាជ្ញាបានទទួលបាននូវថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ ។ ហើយក្រោយមកទៀតក្នុងខែមីនា យើងទទួលបានជាភាសាខ្មែរ គឺនៅក្នុងសេចក្តីឆ្លើយតបដែលលើកឡើងនៅក្នុងចំណុចចំនួនពីរ ។ ហើយខាងសហមេធាវីការពារក្តីមិនបានឆ្លើយតបទៅនឹងចំណុចទីពីរ ទាក់ទងទៅនឹងលក្ខណៈនៃច្បាប់។ ហើយទាក់ទងទៅនឹងដីកានេះ គឺអង្គហេតុមានការចោទប្រកាន់ចំនួន២៦២ ហើយមេធាវីបានឆ្លើយតបទៅលើចំណុចនេះ ចំពោះជំហរនោះគឺចំនួន៣៦១ ។ ដូច្នេះហើយ គឺនៅក្នុងការចោទប្រកាន់នោះ គឺវាមានចំណុចច្រើន ហើយគាត់បានឆ្លើយតបទៅលើចំណុចនីមួយៗ ។ ហើយជាសរុបមក គឺសហមេធាវីបានលើកឡើងឆ្លើយតបទៅលើអង្គហេតុ ហើយគាត់មិនបានផ្តល់យោបល់ផ្សេងៗ ។ ហើយចំពោះការឆ្លើយចំពោះលក្ខណៈកំណត់ទាំងអស់នោះ ការចោទប្រកាន់ចំនួន១៥៧ ក៏ព្រមព្រៀងដោយមេធាវីការពារក្តី ហើយ៨១មិនមានការជំទាស់ ហើយការចោទប្រកាន់២១ ត្រូវបានទទួលយល់ព្រម ។

ហើយបើសិនជាខ្ញុំមានលើកខុសទៅលើចំនួនសូមឲ្យមេធាវីការពារក្តីជួយកែប្រែ ដើម្បីសរុបសហព្រះរាជអាជ្ញា ហើយមេធាវីការពារក្តីបានយល់ស្របគ្នាចំពោះចំណុច១៥៧ ក្នុងចំណោម៣៥១ ។ ហើយមេធាវីមិនបានតវ៉ាចំពោះចំពោះ៨១ចំណុចនោះទេ ។ ដូច្នេះហើយ យើងឃើញមានចំណុចមួយចំនួនចំនួន៣៨មិនមានការជំទាស់ពីមេធាវីការពារក្តី ។ ចំនួន១១២ចំណុច គឺមិនមានការយល់ស្រប ហើយយើងឃើញមានចំណុចខ្លះមានការយល់ស្របមួយផ្នែកនិងផ្នែកមួយចំនួន ។

ដោយការកំណត់របស់មេធាវីការពារក្តី គឺសហព្រះរាជអាជ្ញាមិនមានជំហរក្នុងការយល់ស្រប ចំពោះការកំណត់ទៅលើអង្គហេតុទាំងអស់នោះរបស់មេធាវីការពារក្តីឡើយ ។ ហើយជាក់ស្តែងអង្គហេតុណាក៏ដោយ ឬក៏ការចោទប្រកាន់វិភាគផ្សេងៗ គឺត្រូវតែអនុវត្តនិងវិភាគដោយអង្គជំនុំជម្រះនៅក្នុងដំណាក់កាលផ្សេងៗ ដែលលោកបានកំណត់ ។ ខ្ញុំមិនស្នើសុំឲ្យមានការបញ្ចូលទៅលើអង្គហេតុទាំងអស់នេះនៅក្នុងកំណត់ហេតុនេះ ប៉ុន្តែវាអាស្រ័យទៅលើលោកចៅក្រមថា តើអនុញ្ញាតដែរឬអត់?

ខ្ញុំសន្និដ្ឋានថា មេធាវីការពារក្តីអាចនឹងដាក់ជូន ដោយសង្ខេបទៅក្នុងសំណុំរឿងអំពីព័ត៌មានពិស្តារថា តើការចោទប្រកាន់អង្គហេតុណាខ្លះ ដែលគាត់យល់ស្រប គាត់មិនស្រប និងគាត់ផ្តល់យោបល់ និងចំណុចផ្សេងៗទៀត? ដូចដែលខ្ញុំបានលើកឡើងអ្វីដែលយើងបានដាក់ជូន គឺបានយល់ស្រប ឬក៏មិនជំទាស់ ហើយនិងផ្តល់យោបល់ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះ ដោយមានភាគីដែលមិនមានការតវ៉ាពីភាគី ។ យើងខ្ញុំបានដឹងថា ការមិនយល់ស្របគ្នារវាង ឬការយល់ស្របរវាងសហព្រះរាជអាជ្ញា និងមេធាវី គឺមិនចងកាតព្វកិច្ចរបស់អង្គជំនុំជម្រះនោះទេ គឺចំណុចនេះគឺបញ្ជាក់ច្បាស់ ។ ការព្រមព្រៀងគ្នា គឺបានដាក់ជូននៅក្នុងការរៀបចំសវនាការ ដែលមានការតតាំងនិងពិភាក្សាគ្នារវាងភាគីនៅពេលនោះ ។

យើងនឹងមានអ្វីភ្ញាក់ផ្អើលទេ ខ្ញុំសន្និដ្ឋានថា មេធាវីនឹងដាក់ជូនចំពោះអង្គហេតុដែលមានភាពជំទាស់មួយចំនួន ដែលវាមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដែលតវ៉ាដោយជនជាប់ចោទ ។ ប៉ុន្តែ អង្គហេតុចោទប្រកាន់មួយចំនួន គឺបានដាក់ជូន ប៉ុន្តែមិនមានការផ្តល់យោបល់ ។ ហើយចំពោះការដាក់ឯកសារ ខ្ញុំសូមសន្និដ្ឋានថា គឺឯកសារ E៥/១១/២ ហើយខ្ញុំសូមបញ្ជាក់យើងនឹងធ្វើការពិចារណាឲ្យបានលឿនបំផុតដាក់ចូលទៅក្នុងសំណុំរឿង ដើម្បីឲ្យអង្គជំនុំជម្រះបានដឹងអំពីអង្គហេតុដែលយល់ស្របគ្នា ។ ដូច្នេះហើយខ្ញុំសូមបញ្ជាក់ថា ខ្ញុំនឹងឆ្លើយតបសំណួរផ្សេងៗបើសិនជាអង្គជំនុំជម្រះមានសំណួរណាមួយចង់សួរមកកាន់យើងខ្ញុំ ។

*[ពី ១៥:៣៧ ដល់ ១៥:៤២:០០ ចៅក្រមពិភាក្សាគ្នា]*

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តគឺសូមអញ្ជើញខាងមេធាវីការពារក្តី ដែលអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាទាក់ទិននឹងបញ្ហាអង្គហេតុដែលមានការព្រមព្រៀងនេះ តើសហមេធាវីមានអ្វីឆ្លើយតប ឬក៏កត់សម្គាល់អំពីបញ្ហានេះដែរឬទេ? បើមានសូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំឯកភាពជាមួយមតិយោបល់របស់សហសេវិកនៅខាងសហព្រះរាជអាជ្ញា ហើយយើងនឹងបន្តការងារនេះទៀតនៅថ្ងៃស្អែក ។ ការងារដែលបានបញ្ចប់ដោយមេធាវី ហើយនិង ឌុច ខ្លួនឯងនោះ ទាក់ទងទៅនឹងការទទួលស្គាល់នូវអង្គហេតុដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានោះ ។ យើងបានធ្វើការនៅក្នុងដំណាក់ការដូចខាងក្រោមនេះ ពេលនេះនៅពេលនីមួយៗ ជនជាប់ចោទបានឯកភាពជាមួយនូវកថាខណ្ឌមួយ យើងបានបញ្ជាក់ថាជាក្រហមថា យើងឯកភាព ហើយគឺមានកថាខណ្ឌមួយចំនួនដែលជនជាប់ចោទចង្អុលបង្ហាញថា គាត់ឯកភាពមួយផ្នែក ហើយគាត់បានពន្យល់ហេតុអ្វីដែលគាត់ឯកភាពតែមួយផ្នែកនោះ?

លោក លោកស្រីចៅក្រមនឹងបានឃើញផងដែរ ចំណុចមួយចំនួនមិនមានការតទល់ទេ ហើយយើងនឹងលើកឡើងនៅពេលជំនុំជម្រះចំណុចនោះ ហើយក្នុងករណីមួយទៀត គ្រប់ពេលនីមួយៗនៅក្នុងកថាខណ្ឌដែលយើងគូសបញ្ជាក់ជាពណ៌ពណ៌ខៀវ ដែលរាប់បញ្ចូលនូវកថាខណ្ឌដែលនិយាយអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ កថាខណ្ឌនោះដូចជាឯកសារដែលវាផ្ទុះបញ្ចាំងឆ្លើយឆ្លងគ្នាទៅវិញទៅមកដែលថា សហព្រះរាជអាជ្ញាបានពិនិត្យមើលដីកាបញ្ជូនទៅរឿងទៅជំនុំជម្រះ ហើយនិងដីកាដំណោះស្រាយ ។ ហើយចង់ឲ្យមានបញ្ជាក់ច្បាស់ថែមទៀតនោះ យើងបានបញ្ជាក់ជូនលោក លោកស្រីចៅក្រមថា តើកថាខណ្ឌណាដែលនៅក្នុងដីកាដំណោះស្រាយ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះបានលើកឡើងនោះ? ហើយយើងបានបន្ថែមនៅក្នុងពណ៌បៃតង ដែលយើងបញ្ជូនទៅសំណុំឯកសាររបស់យើង ហើយយើងក៏បានចង្អុលបង្ហាញ ។ យើងបានចង្អុលបង្ហាញនៅក្នុងគំនិតមួយដែលថា សហព្រះរាជអាជ្ញាមិនបានមានបំណងនឹងបញ្ជាក់ដូច្នោះ ដែលថាសហព្រះរាជអាជ្ញានៅក្នុងការងាររបស់ខ្លួនបានធ្វើសេចក្តីសង្ខេបមកពីដីកាដំណោះស្រាយ ហើយមិនបានបន្ថែមក្នុងអត្ថបទខ្លួនឯងនៅក្នុងដីកាដំណោះស្រាយ ហើយយើងបានបញ្ជាក់ជូននៅក្នុងឯកសារនោះជាពណ៌បៃតង ។

[១៥:៤៥:៥២]

ដើម្បីឲ្យមានភាពច្បាស់លាស់នោះ ឌុច ចង់បញ្ជាក់ថាភាពទាំងស្រុងនៃកថាខណ្ឌនៃដីកាដំណោះស្រាយនោះគប្បីតែបញ្ជាក់ ហើយយើងក៏បានបញ្ជាក់ជូននៅក្នុងឯកសារ ។ ហើយយើងខ្ញុំសូមស្នើថានឹងជូនលោកស្រីចៅក្រមនូវឯកសារនេះនៅក្នុងពេលក្រោយ ដើម្បីលើកយកមកពិភាក្សានៅពេលក្រោយ ហើយហ្នឹងគឺថាសហសេវិកខាងព្រះរាជអាជ្ញា លោក រ៉ូបឺត ពើទីត គឺថាចំណុច គឺថាធាតុផ្សំនៅក្នុង

អង្គហេតុត្រូវបានឯកភាព ហើយយើងមានការមិនឯកភាពគ្នាមួយចំណុចមួយចំនួនដែលថា សវនាការនឹងត្រូវធ្វើសវនាការ ហើយយើងនឹងខ្ញុំបញ្ជូនលោកស្រីទៅក្រមតាមមធ្យោបាយជាផ្លូវការរបស់តុលាការ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា សូមអញ្ជើញ ។

**លោក រ៉ូប៊ឺត ពើទីត៖**

អរគុណលោកប្រធាន ។ វាជាការពិតណាស់ ដូចដែលសហមេធាវីបានបង្ហុលបង្ហាញ គឺបញ្ហានោះ គឺយើងមិនទាន់បានយល់ស្របគ្នានៅឡើយ គឺយើងចង់ពិភាក្សា ។ ជនជាប់ចោទគាត់ចង់ផ្តល់យោបល់ ហើយគាត់បានធ្វើដែរនៅក្នុងដំណាក់កាលនេះ ហើយគឺគាត់មិនធ្វើជាលាយលក្ខណ៍អក្សរ ។ ដូច្នេះយើងអាចធ្វើការដេញដោល ។ ហើយនៅចំពោះមុខតុលាការ វាអាចដែលថា យើងគួរតែធ្វើការពិចារណាទៅលើអង្គហេតុនៃការចោទប្រកាន់មួយចំនួនដែលមិនបានតវ៉ា ហើយយើងនឹងចំណាយពេលរយៈពេលពីរម៉ោង ។

ដូច្នេះហើយខ្ញុំសូមបញ្ជាក់ថា យើងជាសហព្រះរាជអាជ្ញាពិចារណាថាវាជាបញ្ហាមួយសមស្របក្នុងការប្រើប្រាស់ពេលវេលារបស់សវនាការ ដែលថាយើងនឹងដាក់មកជាលាយលក្ខណ៍អក្សរ ។ ឯក-សារនេះគឺវាគ្រាន់តែសរសេរឡើងវិញនូវអ្វីដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ហើយខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការពិចារណាចំពោះនីតិវិធីដំណើរការរបស់យើង ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអាចប្រាប់ដល់អង្គជំនុំជម្រះបានទេថា ឯកសារដែលមានការប៉ុនប៉ងព្រមព្រៀងគ្នាដែលកំពុងតែរៀបចំដំណើរការនេះ តើអាចផ្តល់ជូនមកអង្គជំនុំជម្រះនៅពេលណាបាន? ឯកសារដែលពាក់ព័ន្ធជាមួយនឹងជាមួយនឹងអង្គហេតុដែលបានព្រមព្រៀងគ្នា ដែលមានកំពុងតែរៀបចំជាមួយនឹងមេធាវីការពារក្តីនេះ តើអាចផ្តល់មកអង្គជំនុំជម្រះបាននៅពេលណា ?

[១៥:៤៨:៥៨]

**លោក រ៉ូប៊ឺត ពើទីត៖**

ខ្ញុំសូមអភ័យទោសបើសិនជាខ្ញុំនិយាយមិនច្បាស់ ។ ឯកសារដំបូងដែលយើងបានដាក់ជូនទៅមេធាវីការពារក្តីឲ្យធ្វើការពិនិត្យសើរៗនោះ គឺបានដាក់នៅក្នុងខែមករា ជូនតុលាការនេះ ហើយនិងនោះជាឯកសារនៅក្នុងរង្វង់ក្រចកដែលខ្ញុំបានលើកឡើង ។ ហើយឆ្លើយតបទៅនឹងការដាក់ឯកាសារបានន័យ

ថា ជំហរចុងក្រោយរវាងអង្គហេតុយល់ស្របគ្នានោះអាចដាក់នៅត្រឹមថ្ងៃស្អែកព្រលឹម ។ ដូច្នេះហើយ នៅក្នុងសំណុំរឿងនៅថ្ងៃស្អែក លោក លោកស្រីចៅក្រមនឹងមានឯកសារដែលមានចំនួនសែសិបជាង ទំព័រ ដែលចែងអំពីអង្គហេតុ ដែលសហព្រះរាជអាជ្ញានិងមេធាវីការពារក្តីបានយល់ស្រប ហើយមិន បានជំទាស់គ្នា ។

ដូច្នេះហើយនៅព្រឹកស្អែក លោក លោកស្រីចៅក្រមនឹងមានជាលាយលក្ខណ៍អក្សរក្នុងបីភាសា ចំពោះអង្គហេតុទាំងឡាយដែលយើងបានយល់ស្របគ្នា ។ ជាថ្មីម្តងទៀតដូចខ្ញុំសូមលើកឡើងគឺថា ឯក-សារទាំងអស់នេះគឺយើងគួរតែបញ្ចូលទៅក្នុងសំណុំរឿង ហើយសុំឲ្យមានការបកប្រែ ។ ដូច្នេះខ្ញុំប្រាកដ ថា គឺខាងផ្នែកបកប្រែនៅពេលដែលយើងបានដាក់ចូលឯកសារនេះ នៅមានការងារច្រើនទាក់ទងនឹង ការបកប្រែចំពោះឯកសារទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

លោកស្រីចៅក្រមសូមអញ្ជើញ ។

**ចៅក្រម ស៊ីលយ៉ា ខាត់វ៉ាយច៍៖**

សូមអរគុណលោកប្រធាន ។ សហព្រះរាជអាជ្ញាហើយនិងមេធាវីការពារជនជាប់ចោទ គឺថា ការលំបាករបស់តុលាការយើងនោះ គឺថាយើងគំរោងនឹងធ្វើការសួរសំណួរនៅថ្ងៃស្អែក ប្រសិនបើយើង មិនដឹងថា អ្វីជាអង្គហេតុដែលយើងឯកភាពគ្នាទេ ថាតើយើងអាចនឹងធ្វើម៉េចនឹងបានទទួលឯកសារហ្នឹង ឲ្យបានឆាប់នោះ ?

**លោក រ៉ូបឺត ពើទីត៖**

ខ្ញុំផ្ទាល់ គឺខ្ញុំអត់ឃើញមានបញ្ហាអីទេ គឺលោក លោកស្រីចៅក្រមនឹងទទួលបានក្នុងរយៈពេល ប៉ុន្មាននាទីនោះទៀត គឺលោក លោកស្រី នឹងទទួលបានជាភាសា ជាភាសាបារាំង ភាសាអង់គ្លេស ហើយប្រហែលជាអាចជាភាសាខ្មែរ ។ ហើយខ្ញុំអត់ដឹងថាតើខាងមេធាវីការពារក្តីជំទាស់ ឬក៏ភាគី ជំទាស់ឬក៏យ៉ាងម៉េចទេ ? ប៉ុន្តែ ខ្ញុំសូមលើកឡើងចំពោះបញ្ហាដែលថាយើងអាចផ្តល់ជូនក្នុងរយៈពេល ប៉ុន្មាននាទីទៀតនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ តើលោកមានចង់មានយោបល់អ្វីទេទាក់ទិនទៅនឹងបញ្ហានេះ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

មេធាវីនឹងថា សុំឱ្យបញ្ជូនឯកសារនេះទៅចៅក្រមនៅចុងបញ្ចប់នៃសវនាការនេះ ។ អត្ថបទរបស់យើងជាភាសាបារាំងហើយនិងភាសាខ្មែរ ។ ប៉ុន្តែ ពេលដែលយើងចប់ យើកផ្អាកសវនាការនេះហើយយើងនឹងបញ្ជូនសំណើនេះដើម្បីឱ្យលោក លោកស្រីចៅក្រមបានទទួលឯកសារនេះជាបារាំង និងខ្មែរ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ចង់មានយោបល់អ្វីទៅ ?

**លោក រ៉ូបឺត ពើទីត៖**

ដោយការគោរព គឺថាឯកសារថតចម្លងនេះ មើលទៅវាមិនជាមិនសូវស្អាតបាតប៉ុន្មានទេ ប៉ុន្តែយើងនឹងផ្តល់ជូននូវឯកសារសមរម្យ ហើយវាត្រឹមត្រូវទាំងអស់ជូនលោកចៅក្រម ។

*[ពី១៥:៥២:៥៦ ដល់ ១៥:៥៥:00 ចៅក្រមពិភាក្សាគ្នា]*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ចំណុចមួយទៀត ហើយក៏ជារបៀបវារៈចុងក្រោយសម្រាប់ដំណើរការសវនាការថ្ងៃនេះដែរ គឺចំណុចអំពីសំណើរបស់ភាគី ហើយចាប់ផ្តើមបើកសវនាការចំនួនពីរថ្ងៃមកហើយ ហើយរហូតដល់ពេលនេះ តើមានភាគីណាមានសំណើអ្វីសម្រាប់ដាក់មកចំពោះមុខអង្គជំនុំជម្រះដែរឬទេ ? ប្រសិនបើមានសូមអញ្ជើញ ។

**លោក រ៉ូបឺត ពើទីត៖**

សូមអរគុណលោកប្រធាន តាមពិតខ្ញុំមានសំណើបីដើម្បីជម្រាបជូន លោក លោកស្រីចៅក្រមដើម្បីធ្វើសេចក្តីសម្រេច ។ ទីមួយ ទាក់ទងទៅនឹងចំណុចដែលបានលើកឡើងថ្មីៗនេះ ហើយខ្ញុំបានពិភាក្សាជាមួយសហសេវិកខ្ញុំ ហើយខ្ញុំប្រកាន់ជំហរមួយ បើសិនខ្ញុំមិនយល់ច្រឡំទេ ហើយបើសិនខ្ញុំយល់ច្រឡំ សូមឱ្យអង្គជំនុំជម្រះមេត្តាកែ ហើយខ្ញុំយល់ច្បាស់ថា អង្គជំនុំជម្រះ គឺថាថ្ងៃស្អែកនេះ នឹងចាប់ផ្តើមសួរសំណួរទៅជនជាប់ចោទ ។ ហើយប្រសិនបើដូច្នោះមែន តើហើយយើងសូមឱ្យមានសេចក្តីបញ្ជាក់ទាក់ទងទៅនឹងបញ្ហានោះ ដោយសារខ្ញុំមើលទៅក្នុងដីកា ការបង្គាប់នោះយើងបានលំដាប់លំដោយគឺថាការសួរសំណួរទៅជនជាប់ចោទនៅម៉ោង២១នោះ គឺថាយើងនឹងធ្វើនៅថ្ងៃទី៦ ថ្ងៃទី៧ នៃខែ៤ហើយខ្ញុំសូមទទួលការណែនាំប្រសិនបើលោក លោកចៅក្រមមានមតិរឿងនេះ ។ សំណួរទីពីរ សំណើទីពីររបស់ខ្ញុំសូមទទួលការណែនាំពីអង្គជំនុំជម្រះនេះទាក់ទងទៅនឹងការបង្ហាញ បញ្ជាក់ភស្តុតាងដោយ

សាក្សីមួយចំនួន តើយើងអាចមានការចង្អុលបង្ហាញពីអង្គជំនុំជម្រះនេះ ថាតើខ្លួនមានចេតនានឹងជួបជាមួយសាក្សីដែលថា ដែលផ្អែកទៅលើភស្តុតាងនៅក្នុងសំណុំរឿង គឺថាភស្តុតាងដែលទាក់ទងទៅនឹងអង្គហេតុដែលស្របទៅតាមកាលនុវត្តដូចខាងក្រោមនេះ៖

ជាភាសារដែលយើងប្រើជាសាមញ្ញនោះ យើងថា ចំពោះខ្ញុំៗ គិតថាសាក្សីខ្លះអាចនឹងត្រូវទទួលសំណួរទាក់ទងនឹងប្រធានបទ ឬក៏ថ្ងៃណាមួយទៀត ហើយក៏អាចនឹងអញ្ជើញមកនៅថ្ងៃណាផ្សេងទៀត ដើម្បីពិនិត្យមើលសាក្សីក្នុងប្រធានបទមួយផ្សេងទៀត ។ ជាថ្មីម្តងទៀត ដែលខ្ញុំសុំការណែនាំថាតើយើងធ្វើម៉េចដើម្បីឲ្យយើងខ្ញុំបានជាប្រយោជន៍ក្នុងការជួយដល់លោកចៅក្រមក្នុងការងារនោះ ។

សំណើរទី៣របស់ខ្ញុំសម្រាប់ថ្ងៃនេះនោះ គឺអង្គជំនុំជម្រះនេះ គឺសុំឲ្យមេធាវីការពារឲ្យបំភ្លឺថាតើនីតិវិធីនេះ មកដល់ពេលនេះ នៅចំណុចនេះ ឬក៏ចំណុចណាមួយត្រូវឲ្យមានការតទល់អំពី នីត្យានុកូល-ភាពដែរឬទេ ? ខ្ញុំសុំស្នើថា អង្គជំនុំជម្រះ គឺថាមិនអាចបន្តទៅមុខបានទេ បើមិនមានការបញ្ជាក់ឲ្យច្បាស់ពីមេធាវីរបស់ជនជាប់ចោទ បានទាក់ទងទៅនឹងនីត្យានុកូលភាពនៃការចោទប្រកាន់នូវបុគ្គលមួយនេះ ។ ដូចដែលខ្ញុំជម្រាបជូននៅព្រឹកនេះ យើងបានឮពាក្យដែលថា ការធ្វើបែបនេះមិនស្របនឹងរដ្ឋធម្មនុញ្ញ យើងបានឮពាក្យមួយចំនួនថា ដូចជាការបំពារបំពានទៅលើអធិបតេយ្យភាព ហើយយើងក៏បានឮដែរថាៗ ត្រចៀករបស់ខ្ញុំនៅក្នុងអាជីពជាអ្នកទទួលការអប់រំនោះ គឺថា ដូចជា ការធ្វើបែបនេះដូចជាយករដ្ឋធម្មនុញ្ញមកបំពានលើសិទ្ធិរបស់ជនជាប់ចោទឈ្មោះ ឌុច នេះ ។

ឥឡូវនេះ ដូចដែលខ្ញុំបានបញ្ជាក់គឺជាបទពិសោធន៍របស់ខ្ញុំ ដែលថាគោលជំហររបស់មេធាវីគឺមានចំណុច២ ដែលត្រូវលើកឡើង គាត់និយាយក្នុងនាមកូនក្តីរបស់គាត់ តាមការណែនាំ ហើយតាមការឯកភាពរបស់កូនក្តីរបស់គាត់ ។ ចំណុចទី២ គាត់មិនមែននិយាយឲ្យតែបាននិយាយនោះទេ ដូច្នេះពាក្យរបស់គាត់ត្រូវតែថ្លឹងថ្លែង ហើយនឹងចាត់វិធានការស្របទៅតាមនោះ ។ ចំពោះខ្ញុំពាក្យទាំងអស់នោះ ដែលខ្ញុំទើបតែបានលើកអម្បាញ់មិញនេះ គឺជាពាក្យធ្ងន់ធ្ងរណាស់តាមពិតទៅនោះ ។ ឥឡូវនេះខ្ញុំសូមជម្រាបជូនដល់អស់លោកថា អង្គជំនុំជម្រះសុំស្នើឲ្យមេធាវីការពារបញ្ជាក់ ឬក៏ធ្វើ ឲ្យបញ្ជាក់ឲ្យបានច្បាស់ តាមពិតតើខ្លួនមានចេតនាដូចម្តេចឥឡូវនេះ ឬដំណាក់កាលណាមួយក្នុងនីតិវិធី ចង់ប្រឆាំងនឹងយុត្តាធិការនៃតុលាការនេះ ឬក៏សមត្ថកិច្ច ឬក៏ភាពស្របច្បាប់នៃតុលាការនេះ ពីព្រោះច្បាប់និយាយថាឲ្យភាគីនោះត្រូវធ្វើដូច្នោះ ។ វិធាន៨៩ បានចែងយ៉ាងច្បាស់ថា តម្រូវឲ្យភាគីនីមួយៗដែលចាប់ដាក់ការជំទាស់ ឬក៏អញ្ញត្រកម្មរបស់ខ្លួនទាក់ទងទៅនឹងយុត្តាធិការរបស់ខ្លួន ខ្លួនត្រូវតែគោរពវិធានមួយចំនួន

ដែលថាលោកមេធាវីបានបញ្ជាក់លើកឡើងថា វិធានមានចែងនៅត្រង់ហ្នឹងបានបញ្ជាក់ ហើយគឺថាដើម្បីការពារភាពយុត្តិធម៌នៃដំណើរការនីតិវិធី ដែលជាមូលហេតុមួយដែលខ្ញុំនិយាយថា ខ្ញុំទទួលពាក្យនេះមកខ្ញុំរន្ធត់ណាស់ ដែលថាពីរឆ្នាំ ហើយនៅក្នុងនីតិវិធីទាំងអស់នេះ ។ ចាប់ពីថ្ងៃដែលថាសវនាការលើអង្គសេចក្តីបានចាប់ផ្តើមនោះ បន្ទាប់ពីបានស្តាប់ឮលើកាលៈទេសៈមួយចំនួន ដោយការងារដ៏សមស្របមួយចំនួនហើយ ថាតើជនជាប់ចោទចង់ឲ្យដំណើរការនេះទៅមុខទេ ខ្លួនទទួលស្គាល់ថាអំពីពិរុទ្ធភាពរបស់ខ្លួនដែលចង់បាននូវការជំនុំជម្រះដែលយុត្តិធម៌ ហើយនិងការកាត់ទោសដោយយុត្តិធម៌។ ថាតើបន្ទាប់ក្រោយគាត់បានទទួលការ រងការចោទប្រកាន់ពីរឆ្នាំហើយតាមច្បាប់នៃតុលាការនេះ ។

ដីកាដំណោះស្រាយបានឃោងយ៉ាងជាក់លាក់ចំពោះគាត់ដែលថា គាត់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃកន្លែងមួយ ប៉ុន្តែមេធាវីផ្តល់ការណែនាំច្បាស់នោះទេ ដែលថាយើង នៅខែមករា យើងបានណែនាំថាតើគាត់មានចេតនានឹងលើកឡើងនូវអញ្ញត្រកម្មនោះទេ ត្រូវធ្វើតាមលំដាប់លំដោយ ដែលត្រឹមត្រូវមួយ ហើយខ្លួនបានធ្វើបែបនោះ នៅថ្ងៃទី២៨ ខែមករា ដោយខ្លួននិយាយថា តាមពិតខ្លួន មានចេតនានឹងលើកឡើងបញ្ហានោះជាយថាហេតុ ចំណុចមួយនិយាយអំពីអាជ្ញាយុកាលនៃបទឧក្រិដ្ឋ ថ្នាក់ជាតិ ។ ប៉ុន្តែ មិនមានពាក្យណាមួយដែលបញ្ជាក់ថាដំណើរការនីតិវិធីនេះវាផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬថាតើជនជាប់ចោទ គឺថាខ្លួនមិនចង់ចូលរួមក្នុងការជំនុំជម្រះនោះទេ ដើម្បីនឹងលាក់នូវការពិត ហើយនឹងការទទួលនូវការអភ័យទោស ឬក៏ថាខ្លួននឹងចង់ទៅជាមានសេរីភាព ដែលថាតុលាការនេះមិនមានយុត្តាធិការ ។ ប៉ុន្តែ រាល់ជនជាប់ចោទចំពោះតុលាការនេះក៏ត្រូវតែលើកឡើងនូវការការពារខ្លួនដែលមានចំពោះខ្លួនដោយស្របច្បាប់ ។

ដូច្នេះហើយនេះជាភាគីមួយ ហើយខ្ញុំនឹងសូមស្វាគមន៍នូវការលើកឡើងនេះ ថាតើគាត់ជាអ្នកទទួលខុសត្រូវនៅក្នុងខ្ពស់បំផុតដែលថាមេធាវីនោះ បានលើកឡើងអំពីចំណុចមួយអំពីការចោទប្រកាន់មួយនៅក្នុងតុលាការនេះ ក៏ប៉ុន្តែមានវាក្យស័ព្ទមួយ គឺថាយើងមិនអាចគ្រាន់តែយកនំមួយ ហើយមកពិសានោះទេ ហើយខ្ញុំសុំស្នើថា តាមពិតគឺជនជាប់ចោទបានណែនាំទៅមេធាវីដែលថា តុលាការនេះមិនមានយុត្តាធិការចំពោះគាត់ទេ ហើយគាត់នឹងមិនត្រូវចោទប្រកាន់ចំពោះគាត់ទេ គឺថាវាផ្ទុយទៅអធិបតេយ្យភាព ហើយផ្ទុយនឹងគោលការណ៍រដ្ឋធម្មនុញ្ញ ។ បើសិនជាការនោះជនជាប់ចោទបានណែនាំទៅមេធាវី ខ្ញុំគិតថានៅក្នុងវិសាលភាពនៃគោលជំហររបស់ជនជាប់ចោទនោះ ប្រហែលជាការមួយអាចនឹងឆ្លើយតបបាន ។ ដូច្នេះហើយខ្ញុំនឹងទទួលការកែតម្រូវប្រសិនបើវាមានការកែប្រែ ឬក៏ការបក

ប្រែដែលធ្វើយើងមានការយល់មិនច្បាស់នោះ ។ ដូច្នេះអ្វីដែលយើងបានលើកឡើង ស្តាប់ព្រឹកនេះ គឺតាមពិតខ្ញុំគិតថាជាចំណុចសំខាន់ណាស់សម្រាប់តុលាការដើម្បីឲ្យសួរទៅខាងមេធាវីការពារឲ្យបាន ឲ្យគាត់បញ្ជាក់ឲ្យច្បាស់ថាតើគាត់មានគោលជំហរដូចម្តេចទាក់ទងទៅនឹងប្រធានបទនេះ ។

សូមលោកប្រធានជាទីគោរព នេះហើយជាសំណើររបស់ខ្ញុំទាំងបីនោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ភាគីដទៃ តើមានបញ្ហា ឬក៏សំណូមពរអ្វីចង់ឲ្យអង្គជំនុំជម្រះដោះស្រាយទេ ?

សូមអញ្ជើញមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី ។ ណាមួយនៅលោកពីរនាក់នោះ ?

[១៦:០៥:៣៧]

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមដាក់សំណើមួយ ប៉ុន្តែខ្ញុំត្រូវការរយៈពេល១០ ទៅ ១៥នាទីដើម្បីផ្តល់ហេតុផលថា ហេតុអ្វីបានជាយើងស្នើសុំដូច្នេះ ។ ឥឡូវនេះ គឺយើងម៉ោង៤ និង១០នាទីរួចទៅហើយ ខ្ញុំចង់ដឹងពីលោក លោកស្រីចៅក្រម ថាតើលោក លោកស្រីចៅក្រម ផ្តល់ឱកាសនេះនៅថ្ងៃនេះ ឬក៏ចាំដល់ថ្ងៃស្អែក ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះពេលវេលាក៏កាន់តែខិតជិតដល់ត្រូវពេលវេលាត្រូវសម្រាកហើយ ហើយអង្គជំនុំជម្រះនៅពេលនេះគ្រាន់តែចង់ដឹងថាតើភាគីណាខ្លះដែលមានបញ្ហា ឬសំណូមពរ សុំឲ្យអង្គជំនុំជម្រះដោះស្រាយតែប៉ុណ្ណោះ ? ចំពោះបញ្ហាជាក់ស្តែង គឺទុករង់ចាំដល់ថ្ងៃស្អែក ក៏ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកថា បញ្ហាដែលបានដាក់ជូនអង្គជំនុំជម្រះម្តងហើយ ហើយអង្គជំនុំជម្រះសម្រេចរួចហើយ បញ្ហាដដែលមិនអាចយកមកលើកនៅទីនេះម្តងទៀតទេ នេះសូមបញ្ជាក់ឲ្យបានច្បាស់លាស់ ។

ហើយបន្តទៀតតើមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាទៀតដែលមានការប៉ុនប៉ងក្នុងការដាក់នូវបញ្ហាផ្សេងៗដើម្បីឲ្យអង្គជំនុំជម្រះដោះស្រាយនោះ ?

**លោក អាឡាំង វែនណឺ៖**

លោកប្រធាន លោកចៅក្រម ខ្ញុំទាក់ទងទៅនឹងអំពីការកំណត់កាលវិភាគនៃការជំនុំជម្រះ ហើយយើងនឹងលើកឡើងនៅថ្ងៃស្អែក ខ្ញុំនឹងមានស្នើសំណើនៅថ្ងៃស្អែក ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក ព្យែរ អូលីវីយេ ស័រៈ**

អរគុណលោកប្រធាន វាមិនមែនជាការស្នើសុំទេ នៅថ្ងៃស្អែកទេ ខ្ញុំសុំបង្ហាញការសោកស្តាយដែលថា ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនអនុញ្ញាតឲ្យនិយាយក្រៅពីអ្វីដែលសហព្រះរាជអាជ្ញា ជនជាប់ចោទ និងសហមេធាវីកាត់ក្តីបានលើកឡើង ។ យើងខ្ញុំគួរតែគិតថាចំណុចនេះគួរតែផ្តល់ឲ្យមានសមភាពរវាងភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីគួរតែផ្តល់ឱកាសឲ្យឆ្លើយតបទៅលើបញ្ហាទាំងអស់នោះ ។

ថ្ងៃនេះយើងនិយាយក្នុងនាមប្រជាជនកម្ពុជា ក្នុងនាមអង្គការសហប្រជាជាតិ ។

**ប្រធានអង្គជំនុំៈ**

សំណើនេះ ហើយជាសំណើចាស់ ដែលអង្គជំនុំជម្រះបានសម្រេចជាលាយលក្ខណ៍អក្សរបដិសេធរួចហើយ ដោយយោងហេតុផលសព្វគ្រប់នៅក្នុងលិខិតដីកាសម្រេចរបស់អង្គជំនុំជម្រះ ដែលសំអាងទៅលើវិធាន៨៩.២ ដែលមិនមានវិធានណាផ្សេងទៀតដើម្បីគាំទ្រឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឡើងធ្វើសេចក្តីសន្និដ្ឋានសង្ខេបពាក់ព័ន្ធជាមួយនឹងគាំទ្រដល់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញានោះទេ ។ អ៊ីចឹង នេះយើងបានបញ្ជាក់ហើយអម្បាញ់មិញថាជាសំណើចាស់ដែលអង្គជំនុំជម្រះបានសម្រេចបដិសេធហើយ មិនអាចលើកឡើងម្តងទៀតទេ ។

សូមអញ្ជើញលោកស្រី ជា លាង ។

**លោកស្រី ជា លាងៈ**

សូមអរគុណលោកប្រធាន ហើយខ្ញុំជាសហព្រះរាជអាជ្ញានេះគ្រាន់តែបន្ថែមទៅលើចំណុចទី៣ ក្នុងសំណើរបស់ខាងសហព្រះអាជ្ញានោះ ។ ក្រោយពីបានស្តាប់នូវការឆ្លើយតបមេធាវីការពារជនជាប់ចោទ ខ្ញុំគ្រាន់តែសុំរំឭកថាអ្វីដែលគាត់លើកឡើងនោះ គឺគាត់មានសិទ្ធិក្នុងការលើកតាំងពីសវនាការបឋម ប៉ុន្តែនៅក្នុងសវនាការបឋមនោះ មេធាវីរបស់ជនជាប់ចោទមិនបានលើកចំណុចនេះបញ្ជាក់អង្គសវនាការទេ ។ អ្វីដែលខ្ញុំបានចាំកន្លងមកហ្នឹង គឺគាត់បានលើកអំពីអាជ្ញាយុកាលនៃបណ្តឹង រលត់បណ្តឹងអាជ្ញា ឬក៏អាជ្ញាយុកាលនៃបណ្តឹងដែលទាក់ទង ដូចថាបទល្មើសហ្នឹងបានផុតកំណត់ក្នុងរយៈពេល ។ ដោយឡែកចំណុចថា ច្បាប់ដែលជនជាប់ចោទនឹងទទួលនោះមិនស្ថិតក្នុងយុត្តាធិការ គឺថាអ្វីដែលខ្ញុំចាំនោះ គឺមិនបានលើកទេ ដូច្នេះតាមវិធានផ្ទៃក្នុងមាត្រា៨៩ អំពីអញ្ញត្រកម្មនោះគឺបានបញ្ជាក់យ៉ាងច្បាស់ហើយថាមិនត្រូវទទួលយកទេ ។ ដូច្នេះ ខ្ញុំគ្រាន់តែរំឭកទៅលើចំណុចនេះតែប៉ុណ្ណោះ ។ អរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវី ហុង គីមសួន ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក ជាទីគោរព! ខ្ញុំបាទមានជាសំណើពីរ ។ ទីមួយទាក់ទងជាមួយនឹងការលើកឡើង ឬក៏ថ្លែងបើកពីម្សិលមិញនេះដោយលោកស្រី និងលោកក្រឡាបញ្ជីអំពីលេខសម្គាល់របស់សាក្សីដោយខ្ញុំបាទមើល និងស្ដាប់ឃើញថា មានខុសគ្នាជាមួយនឹងលេខសម្គាល់របស់ព្រះរាជអាជ្ញា ឬក៏ខាងយើងខ្ញុំជាដើមបណ្ដឹងរដ្ឋប្បវេណីកាលពីថ្ងៃសវនាការរៀបចំនោះ អ៊ីចឹងខ្ញុំបាទសូមស្នើថា តើតទៅមុខទៀតលេខសម្គាល់របស់ខាងលោកក្រឡាបញ្ជីអាន និងលេខសម្គាល់ខាងព្រះរាជអាជ្ញា យើងខ្ញុំនឹងយកចំណុចមួយណាឲ្យដូចគ្នាស្រួលនឹងខ្ញុំបាទ និងយើងខ្ញុំនេះរៀបចំឯកសារឲ្យត្រូវគ្នា នេះមួយ ។ ទីពីរ អំពីរបៀប ឬក៏ការសួរតទល់តើលោកប្រធាននឹងណែនាំឲ្យធ្វើការសួរដោយសំណួរចំហ ជា *ដាយរិច អិចហ្សាមីណេសិន (Direct Examination)* ឬក៏ជាសំណួរប្រឆាំង អង់គ្លេសហៅថា *ក្រោះ អិចហ្សាមីណេសិន (Cross Examination)* ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**លោកស្រី ម៉ាទីន ហ្សាកហ្វីន៖**

សូមអរគុណ ។ ទាក់ទងទៅនឹងចំណុចក្រោយមួយដែលទាក់ទងទៅនឹងអំពីការឯកភាពលើអង្គហេតុ ដោយយើងមានការឯកភាពរវាងសហព្រះរាជអាជ្ញានិងមេធាវី ដែលថាមានបញ្ជីមួយចំនួននឹងដាក់ចូលក្នុងសំណុំរឿង ហើយនឹងបញ្ជូនយប់នេះ ឬក៏ថ្ងៃស្អែក ខ្ញុំខ្លួនឯងជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីខ្ញុំមានការសោកស្ដាយណាស់ដែលថាចំណុចនេះ គឺថាមិនបានលើកឡើងជាផ្ទាល់មាត់អំពីចំណុចបីអំពីគោលការណ៍នៃការបញ្ជាក់ដោយមាត់នោះទេ ។ ចំណុចមួយទៀត គឺថាភាគីត្រូវបានដឹងពីចំណុចនេះដោយផ្ទាល់ប្រសិនបើមេធាវីអាចបើកមើលបាននោះ គឺថា ហើយនិងចំណុចមួយទៀត ហើយអ្នកដែលវត្តមានក្នុងសាលសវនាការនេះគឺសំខាន់ណាស់ដើម្បីឲ្យគេអាចយល់បានដែលថាចំណុចមួយចំនួនសំខាន់ៗនោះដែលត្រូវដឹង គឺថាៗ ប្រហែលជា១០០ ឬក៏១៨០ចំណុចនោះ មិនត្រូវបានជំទាស់ គឺថាបើសិនជាធាតុផ្សំនៃអង្គហេតុនោះ គប្បីតែលើកឡើង ហើយនិងៗ បញ្ជាក់ឲ្យឃើញថាតើចំណុចណា

ឯកភាព មិនឯកភាពគ្នារវាងព្រះរាជអាជ្ញា និងមេធាវីការពារ ហើយបើមិនដូច្នេះទេ យើងនឹងមានការភ័ន្តច្រឡំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបំភ្លឺ ខ្ញុំមិនចង់លើកឡើងសំណើខ្ញុំសាជាថ្មីនោះទេ បន្ថែមទៅលើចំណុចហ្នឹង លោក លោកស្រីចៅក្រមគួរតែឆ្លើយតបមកយើងខ្ញុំនៅថ្ងៃហ្នឹង ប្រសិនបើលោក លោកស្រីចង់កែប្រែទៅលើរបៀបវារៈ ដូចដែលលោក រ៉ូបឺ ពើទីត បានស្នើសុំឲ្យលោក លោកស្រីចៅក្រមរួចមកហើយនោះ ថាតើលោក លោកស្រីចៅក្រមចង់ធ្វើការដេញដោលនៅថ្ងៃស្អែកទៅលើជនជាប់ចោទ ឬក៏យ៉ាងម៉េច ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបរំឭកឡើងវិញថា នាពេលនេះអង្គជំនុំជម្រះប្រមូលព័ត៌មានទាំងឡាយដែលជាសំណូមពររបស់ភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះដើម្បីកត់ត្រាយកទៅពិនិត្យពិចារណានៅល្ងាចនេះ ហើយនឹងឆ្លើយតបនៅថ្ងៃស្អែក នេះជាតាមអ្វីដែលបានគ្រោងទុកនៅក្នុងដំណើរការប្រព្រឹត្តទៅនៃសវនាការ នៅថ្ងៃនេះ ។ អ៊ីចឹងអង្គជំនុំជម្រះរក្សាសិទ្ធិមិនទាន់ឆ្លើយតបនូវសំណួរ ឬក៏សំណូមពរផ្សេងៗនេះទេ គឺនឹងឆ្លើយតបនៅវេលាថ្ងៃស្អែក ។

មេធាវីការពារមានសំណូមពរអ្វីទេ ?

**លោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកចៅក្រម គឺថាមេធាវីការពារនឹងទាក់ទងទៅនឹងការឃុំខ្លួននោះ ខ្លួននឹងមានសំណើមួយ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលត្រូវឈប់សម្រាកនៅល្ងាចនេះហើយ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសផ្អាកសវនាការនៅថ្ងៃនេះ ត្រឹមនេះ ។ សវនាការនឹងបន្តនៅព្រឹកថ្ងៃស្អែកចាប់ពីម៉ោង៩តទៅ ។ ដូច្នេះមួយបង្គាប់អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទ កាំង ហ្គេក អ៊ាវ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ

និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់សាលសវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោង៩ជាកំហិត ។

សូមជម្រាបដល់អ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងសាធារណជនដែលមានបំណងចូលរួមក្នុងសវនាការ សូមអញ្ជើញមកកាន់សាលសវនាការឲ្យបានមុនម៉ោង៩ ព្រឹក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២០:០០នាទី]*